សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់នៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក. ផុង តិតុន**
**ក. ឈាង ខៀនឈាង**

សាស្ត្រាចារ្យណែនាំ
**បណ្ឌិត អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២០

ឆ្នាំចូលរៀន ២០១៦
ឆ្នាំសរសេរសារណា ២០២០

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់នៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ក. ផុន តិតុន**
**ក. ឈាង ងៀនឈាង**

សាស្ត្រាចារ្យណែនាំ
**បណ្ឌិត អ៊ុន សកក្កដា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២០

ឆ្នាំចូលរៀន ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **ផុង តិគុន** និងនាងខ្ញុំ **ឈាង ខៀនឈាង** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្រ្តឆ្នាំទី៤ ថ្នាក់សិក្សាបង់ថ្លៃ ជំនាន់ទី២០ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច សូមថ្លែងនូវការដឹងគុណដ៏ជ្រាលជ្រៅបំផុត និងកត្តញ្ញូធម៌ជូនចំពោះ៖

**លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើត តស៊ូអត់ធ្មត់ ចិញ្ចឹមបីបាច់ ថែរក្សា និងអប់រំទូន្មានប្រៀបប្រដៅកូនប្រកបដោយព្រហ្មវិហារធម៌ តាំងពីបាតជើងក្រហម រហូតដល់កូនធំមកដល់ថ្ងៃនេះ នៅក្រោមម្លប់ដ៏ត្រជាក់របស់អ្នកមានគុណទាំងពីរ។ គុណទាំងនេះ ជាបុព្វហេតុដែលជំរុញឱ្យការសិក្សារៀនសូត្ររបស់កូនបានទទួលជោគជ័យតរៀងមក រហូតបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនាថ្ងៃនេះ។

**ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រងសាលា ព្រមទាំងសាស្ត្រាចារ្យ និងបុគ្គលិក** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង ក្នុងការអប់រំបណ្តុះបណ្តាលទាំងក្នុងបរិបទនៃការអប់រំវិជ្ជាជីវៈ និងចំណេះដឹងសង្គម បទពិសោធន៍ សីលធម៌ ព្រមទាំងគុណធម៌ដល់និស្សិតគ្រប់រូប ឱ្យក្លាយទៅជានិស្សិតដែលប្រកបដោយមូលធនផ្នែកបញ្ញាស្មារតី និងជាពលរដ្ឋដ៏ល្អនៅក្នុងសង្គមក៏ដូចជាធនធានមនុស្សរបស់កម្ពុជាម្នាក់ដែលជាសសរទ្រូងរបស់ប្រទេសកម្ពុជា ស្របទៅតាមកាលានុវត្តភាពនៃការអភិវឌ្ឍរបស់ប្រទេសជាតិ។

ជាពិសេស **លោកសាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា** ដែលបានលះបង់អស់កម្លាំងកាយចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការដឹកនាំស្រាវជ្រាវសារណាបញ្ចប់នេះ ដោយលោកបានចង្អុលបង្ហាញទិស ផ្តល់ជាគំនិត មតិយោបល់ ធ្វើការវាយតម្លៃ និងកែលម្អដែលជាកត្តាមួយក្នុងចំណោមកត្តាចម្បងៗ ដែលជំរុញឱ្យសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំបានសម្រេចជោគជ័យជាស្ថាពរ។

ជាទីបញ្ចប់ យើងខ្ញុំសូមប្រសិទ្ធពរជ័យសិរីមង្គល ជូនចំពោះលោកដ៏មានគុណទាំងអស់ សូមឱ្យទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច មានកម្លាំងពលំមាំមួនខ្លាំងក្លា បញ្ញាស្មារតីភ្លឺថ្លាវាងវៃ អាយុយឺនយូរ រកទទួលទានមានបាន និងសូមជួបប្រទះតែនឹងសេចក្តីសុខ គ្រប់ប្រការ ព្រមទាំងជួបនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ការសិក្សាមួយដែលជោគជ័យ គឺមិនមែនគ្រាន់តែទទួលបានការសិក្សា ឬក៏ទទួលបានការអប់រំពីសំណាក់សាស្ត្រាចារ្យប៉ុណ្ណោះនោះទេ ចាំបាច់គឺត្រូវមានការអនុវត្តផងដែរទើបការសិក្សានោះទទួលបានការជោគជ័យយ៉ាងពេញលេញ។ ជាក់ស្តែង បន្ទាប់ពីនាងខ្ញុំទាំងពីរនាក់បានទទួលការសិក្សាថ្នាក់បរិញ្ញាបត្រនៅក្នុងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែកនីតិសាស្ត្រអស់រយៈពេលបួនឆ្នាំកន្លងមកនេះ និងដោយការខិតខំប្រឹងប្រែងសិក្សារៀនសូត្ររបស់នាងខ្ញុំទាំងពីរនាក់ ជាលទ្ធផលគឺនាងខ្ញុំទាំងពីរនាក់បានទទួលនូវឱកាស ក៏ដូចជាលទ្ធភាពក្នុងការសរសេរសារណាបញ្ចប់ការសិក្សាមួយទុកជាឯកសារសម្រាប់ជំនួយស្មារតីដល់និស្សិតជំនាន់ក្រោយទៀត។ ជាមួយគ្នាផងដែរ សារណាបញ្ចប់ការសិក្សាមួយនេះ គឺជាស្នាដៃមួយដែលអាចវាស់ស្ទង់សមត្ថភាព និងចំណេះដឹងរបស់នាងខ្ញុំទាំងពីរនាក់ដែលមានតាំងពីមុនមក បូករួមជាមួយការសិក្សាស្រាវជ្រាវបន្ថែម។

នាងខ្ញុំទាំងពីរនាក់បានសជ្រើសរើសប្រធានបទស្តីអំពី **ការត្រួតពិនិត្យគុណភាព សុវត្ថិភាពសំណង់នៅកម្ពុជា** ហើយមូលហេតុដែលនាងខ្ញុំទាំងពីរនាក់សម្រេចជ្រើសរើសនូវប្រធានបទនេះ ដោយសារប្រទេសកម្ពុជាយើងមានការរីកចម្រើនខ្លាំងគួរឱ្យកត់សម្គាល់ ដែលយើងអាចសង្កេតឃើញលើគ្រប់វិស័យដូចជាសេដ្ឋកិច្ច សង្គមកិច្ច នយោបាយ រួមទាំងការកសាងឡើងនូវហេដ្ឋារចនាសម្ព័ន្ធ រូបវន្តសាធារណៈ និងសំណង់ជាដើម។ ទិដ្ឋភាពទាំងអស់នេះបានបង្ហាញឱ្យឃើញថា ប្រទេសជាតិមួយរីកចម្រើនទៅបានក៏ព្រោះតែមានអ្នកដឹកនាំល្អដែលប្រៀបដូចជាគ្រឹះដ៏រឹងមាំរបស់ប្រទេស បូករួមជាមួយការចូលរួមរបស់ប្រជាជនដែលសុទ្ធសឹងជាធនធានសម្រាប់ការអភិវឌ្ឍប្រទេស ដែលប្រៀបបានទៅនឹងអគារធំៗនៅក្នុងទីក្រុង ដែលសំណង់អគារនីមួយៗរឹងមាំមហិមាដោយសារតែមាននូវគ្រឹះដ៏រឹងមាំ ដោយសារការសាងសង់ស្របទៅតាមក្បួនខ្នាតនៃនគរូបនីយកម្ម ក៏ដូចជាស្របទៅតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិផ្សេងៗទៀតទាក់ទងទៅនឹងសំណង់។

ជាចុងក្រោយ ដោយក្តីគោរព នាងខ្ញុំទាំងពីរនាក់សូមគោរព និងទទួលយកដោយរីករាយនូវរាល់មតិរិះគន់ក្នុងន័យស្ថាបនាចំពោះកំហុសឆ្គងដែលកើតឡើងដោយចេតនាក្តី ឬអចេតនាក្តី ឬនៅមានការខ្វះចន្លោះនៅត្រង់កន្លែងណាមួយ សូមមេត្តាខន្តីអភ័យទោស ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំទាងពីរនាក់។ ជាមួយគ្នានេះផងដែរ នាងខ្ញុំទាំងពីរនាក់សូមទទួលនូវរាល់មតិរិះគន់ កែតម្រូវនូវរាល់ចំណុចខ្វះខាតទាំងឡាយពីសំណាក់សាស្ត្រាចារ្យ និងនិស្សិតទាំងអស់ដើម្បីជាការកែលម្អធ្វើឱ្យប្រសើរឡើងនៅក្នុងការសរសេរសារណាក្រោយៗទៀត។

*ដោយសេចក្តីគោរព និងសូមអរគុណ!*

# មាតិកា ទំព័រ

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ការផ្តល់លិខិតអនុញ្ញាតសាងសង់**

**១.១. មូលហេតុនៃការផ្តល់លិខិតអនុញ្ញាតសាងសង់** ........ ៤

១.១.១.ការការពារសណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាព ........ ៤

១.១.២. ការយល់ដឹងរបស់ប្រជាពលរដ្ឋលើវិស័យច្បាប់ ........ ៥

**១.២.ការកំណត់ប្រភេទសំណង់ក្នុងការផ្តល់លិខិតអនុញ្ញាតសាងសង់** ........ ៥

១.២.១ សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ជាមុន ........ ៥

១.២.២. សំណង់ដែលពុំចំណុះក្រោមលិខិតអនុញ្ញាតសាងសង់ ........ ៦

**១.៣. ការត្រួតពិនិត្យ និងការរៀបចំសំណុំឯកសារផ្តល់លិខិតអនុញ្ញាតសាងសង់** ........ ៧

១.៣.១. ការត្រួតពិនិត្យសំណុំឯកសារចាំបាច់ ........ ៧

១.៣.១.១.សំណុំឯកសារ និងបណ្តាប្លង់ចាំបាច់ ........ ៧

១.៣.១.២. គោលការណ៍ពីរដ្ឋាភិបាល ........ ៩

១.៣.២. ការពិនិត្យលក្ខខណ្ឌចាំបាច់ ........ ១០

១.៣.២.១. ប្លង់ជួរតម្រង់ ........ ១០

១.៣.២.៣. ប្រភេទ ការកំណត់ទីតាំង និងបណ្តាញផ្លូវពាក់ព័ន្ធ ........ ១៣

**១.៤. សមត្ថកិច្ចក្នុងការផ្តល់លិខិតអនុញ្ញាសាងសង់** ........ ១៣

១.៤.១. អាជ្ញាធរថ្នាក់ជាតិ ........ ១៤

១.៤.២. អាជ្ញាធរថ្នាក់ក្រោមជាតិ ........ ១៤

**១.៥. ការផ្សព្វផ្សាយលិខិតអនុញ្ញាតសាងសង់ និងអង្កេតសាធារណៈ** ........ ១៥

**១.៦. រយៈពេលនៃការពិនិត្យសម្រេចលើពាក្យសុំលិខិតអនុញ្ញាសាងសង់** ........ ១៥

១.៦.១. សមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត ........ ១៦

១.៦.២.សមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ........ ១៦
១.៦.៣. នីតិវិធីត្រួតពិនិត្យ និងសម្រេចលើសំណុំឯកសារផ្តល់លិខិតអនុញ្ញាតសាងសង់ ........ ១៦
១.៦.៤.ការផ្តល់លិខិតអនុញ្ញាតសាងសង់ ........ ១៧
**១.៧. សោហ៊ុយលើសេវា និងសុពលភាពនៃលិខិតអនុញ្ញាតសាងសង់ ........ ១៧**
១.៧.១.សោហ៊ុយលើសេវា ........ ១៧
១.៧.២. សុពលភាពនៃលិខិតអនុញ្ញាតសាងសង់ ........ ១៨

## ជំពូកទី២

## ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់

**២.១ អាជ្ញាធរមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ ........ ១៩**
២.១.១ អាជ្ញាធរថ្នាក់ជាតិ ........ ២០
២.១.១.១ សមាសភាព ........ ២០
២.១.១.២ តួនាទីនិងភារកិច្ច ........ ២០
២.១.២ អាជ្ញារធរថ្នាក់ក្រោមជាតិ ........ ២១
២.១.២.១ សមាសភាព ........ ២១
២.១.២.២ តួនាទី និងភារកិច្ច ........ ២៤
**២.២ ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ ........ ២៤**
២.២.១. ការចុះត្រួតពិនិត្យទីតាំងស្នើសុំលិខិតអនុញ្ញាតសាងសង់ ........ ២៤
២.២.១.១ ទីតាំងដែលមានគម្រោងសាងសង់ ........ ២៥
២.២.១.២ សំណង់ដែលកំពុងដំណើរការសាងសង់ ........ ២៥
២.២.២ ការត្រួតពិនិត្យក្នុងពេលសាងសង់ ........ ២៨
២.២.២.១ លិខិតអនុញ្ញាត ........ ២៨
២.២.២.២ ការរៀបចំការដ្ឋាន ........ ៣០
២.២.២.៣ ដំណើរការដ្ឋានសំណង់ ........ ៣២
២.២.៣ ការត្រួតពិនិត្យពេលបញ្ចប់ការសាងសង់ ........ ៣៣

**សេចក្តីសន្និដ្ឋាន** ........................................ ៣៤
**អនុសាសន៍** ........................................ ៣៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា

សំណង់កាន់តែធំ កាន់តែខ្ពស់ កាន់តែស្មុគស្មាញ កាន់តែទាមទារឱ្យមានការអនុវត្តឱ្យបានត្រឹមត្រូវទៅតាមបទដ្ឋានគតិយុត្ត បច្ចេកវិទ្យា និងបទប្បញ្ញត្តិបច្ចេកទេស ដើម្បីធានាភាពរឹងមាំ គុណភាព សោភណភាព និងចីរភាពនៃសំណង់ ដែលក្នុងនោះលិខិតអនុញ្ញាតសាងសង់មានសារៈសំខាន់ណាស់ និងចាំបាច់ដែលរាល់រូបវន្ត ឬនីតិបុគ្គលសាធារណៈ ឬឯកជនត្រូវមាន ព្រោះវាជាគ្រឹះនៃភាពស្របច្បាប់របស់សំណង់ និងដើម្បីធានាបាននូវសុខុមាលភាពនៃសំណង់ និងសុវត្ថិភាពសាធារណៈ ព្រមទាំងដើម្បីការពារដីធ្លីសាធារណៈចាំបាច់សម្រាប់ធានាដល់ដំណើរការរៀបចំទីក្រុង និងតំបន់នានាឱ្យបានប្រសើរនឹងមានសណ្តាប់ធ្នាប់ល្អ។ ដូចនេះ ថ្វីត្បិតតែយើងមានសិទ្ធិ កម្មសិទ្ធិនៅលើដីដែលមាន សិទ្ធិប្រើប្រាស់អាស្រ័យផល សិទ្ធិចាត់ចែងដីរបស់យើងតាមការដែលយើងចង់ក៏ពិតមែន តែចំពោះសិទ្ធិក្នុងការសាងសង់អាគារផ្សេងៗនៅលើដីដែលជាកម្មសិទ្ធិរបស់ខ្លួននោះចាំបាច់ត្រូវមានលិខិតអនុញ្ញាតឱ្យសាងសង់ជាមុនដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីឱ្យទទួលបាននូវលក្ខណៈស៊ីជម្រៅ ក៏ដូចជាភាពកាន់តែច្បាស់លាស់ទៅលើប្រធានបទសារណាខាងលើ យើងខ្ញុំទាំងពីរនាក់បានលើកឡើងនូវចំណោទបញ្ហាដើម្បីធ្វើការបកស្រាយដែលបញ្ហាទាំងនោះរួមមាន តើនៅមុនពេលសាងសង់ម្ចាស់សំណង់ត្រូវធ្វើការស្នើសុំដូចម្តេចខ្លះ ដើម្បីទទួលបាននូវសិទ្ធិសាងសង់? តើអាជ្ញាធរពាក់ព័ន្ធណាខ្លះដែលមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់? ក្រៅពីនេះនៅក្នុងដំណើរការនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ តើអាជ្ញាធរធ្វើការត្រួតពិនិត្យទៅលើអ្វីខ្លះ?

## ៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ

គោលបំណងក្នុងការលើកយកប្រធានបទទាក់ទងនឹងនីតិនគរូបនីយកម្មដែលស្តីអំពី ការត្រួតពិនិត្យគុណភាពសុវត្ថិភាពសំណង់នៅកម្ពុជា យកមកសរសេរជាប្រធានបទសម្រាប់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ គឺដោយសាររយៈពេលថ្មីៗនេះ យើងសង្កេតឃើញមាននូវការបាក់រលំអគារជាច្រើនករណីដែលកើតឡើងបន្តបន្ទាប់គ្នា ដែលជាហេតុធ្វើឱ្យក្រុមនាងខ្ញុំចង់សិក្សាស្វែងយល់អំពីហេតុដើមចមដែលបណ្តាលឱ្យកើតមាននូវបញ្ហានេះឡើង និងចង់បង្ហាញអំពីនីតិវិធីផ្សេងៗដែលម្ចាស់សំណង់និងអាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើតាំងពីមុនពេលចាប់ផ្តើមការសាងសង់រហូតដល់ការសាងសង់ត្រូវបានបញ្ចប់និងត្រូវបានធានាថា សំណង់ដែលបានសាងសង់ឡើងជាសំណង់ដែលមានគុណភាព និងធានាដល់សុវត្ថិភាពដល់ម្ចាស់សំណង់ក៏ដូចជាប្រជាពលរដ្ឋដែលរស់នៅជុំវិញសំណង់ដែលគេបានសាងសង់នោះ។ លើសពីនេះទៅទៀត គោលបំណងនៃការបង្កើតស្នាដៃនៃការសិក្សាស្រាវជ្រាវលើប្រធានបទសារណានេះឡើង គឺមានគោលបំណងក្នុងការបង្ហាញអំពីការយកចិត្តទុកដាក់

របស់រាជរដ្ឋាភិបាលទៅលើវិស័យសំណង់ ក៏ដូចជាសុខុមាលភាពរបស់ប្រជាពលរដ្ឋរស់នៅប្រកបដោយសុខសុវត្ថិភាព និងគ្មានភាពភ័យខ្លាច។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវដែលទាក់ទងនឹងការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់នៅកម្ពុជានេះ គឺយើងខ្ញុំនិងផ្តោតទៅលើការស្នើសុំ និងនីតិវិធីនៃការស្នើសុំលិខិតអនុញ្ញាតសាងសង់ដើម្បីឱ្យម្ចាស់សំណង់ទទួលបានសិទ្ធិសាងសង់ ព្រមទាំងការត្រួតពិនិត្យគុណភាពសំណង់របស់អាជ្ញាធរមានសមត្ថកិច្ចនៅអំឡុងពេលនៃការសាងសង់ និងក្រោយពេលដែលការសាងសង់ត្រូវបានបញ្ចប់។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

ក្រោយពេលការស្រាវជ្រាវនេះត្រូវបានបញ្ចប់ នឹងអាចផ្តល់អត្ថប្រយោជន៍មួយចំនួនសម្រាប់ការសិក្សាស្រាវជ្រាវពង្រីកនូវចំណេះដឹងបន្ថែមរបស់ប្អូនៗ មិត្តនិស្សិត និងមិត្តអ្នកអាន និងសាធារណៈជនទាំងអស់ឱ្យបានយល់ដឹងឱ្យកាន់តែច្បាស់អំពីតួនាទីរបស់ម្ចាស់សំណង់នៅក្នុងការសាងសង់អគារឬសំណង់ផ្សេងៗ ក៏ដូចជាតួនាទីរបស់អាជ្ញាធរមានសមត្ថកិច្ចនៅក្នុការត្រួតពិនិត្យគុណភាពសុវត្ថិភាពសំណង់នៅកម្ពុជា។ មិនតែប៉ុណ្ណោះ អត្ថបទសារណានេះក៏បានជួយជំរុញឱ្យមានការចូលរួមគោរពច្បាប់របស់ប្រជាពលរដ្ឋ ម្ចាស់សំណង់ អ្នកប្រកបវិជ្ជាជីវៈ អ្នកសាងសង់ ទៅលើវិធានច្បាប់ជាធរមានផ្សេងៗដែលទាក់ទងទៅនឹងសំណង់ផងដែរ។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

នៅក្នុងការសរសេរសារណាវិធីសាស្ត្រស្រាវជ្រាវ គឺជាផ្នែកមួយដែលលើកយកមកធ្វើការសិក្សាលើប្រធានដើម្បីប្រមូលនូវព័ត៌មាន ជាជំនួយដល់ការស្រាវជ្រាវប្រកបដោយលក្ខណៈត្រឹមត្រូវច្បាស់លាស់។ ដើម្បីឆ្លើយតប ទៅនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវ និងប្រមូលព័ត៌មានឱ្យបានលម្អិតត្រឹមត្រូវ និងឱ្យរឹតតែស៊ីជម្រៅថែមទៀតនោះ យើងខ្ញុំបានធ្វើការជ្រើសរើសយកការស្រាវជ្រាវទៅតាមបែបគុណវិស័យ គឺជាការស្រាវជ្រាវដែលតម្រូវឱ្យយើងខ្ញុំធ្វើការប្រមូលព័ត៌មានលម្អិតជុំវិញប្រធានបទហើយធ្វើវែកញែក និងវាយតម្លៃរាល់លទ្ធផលរាល់ឯកសារទាំងឡាយបន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវតាមរូបភាពផ្សេងៗ ដែលយើងខ្ញុំបានធ្វើការប្រមូលនោះយកមកធ្វើការវិភាគដើម្បីបានលទ្ធផលសម្រេច។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីធ្វើឱ្យការសិក្សាលើប្រធានបទសារណាបញ្ចប់ការសិក្សាកាន់តែល្អប្រសើរ និងច្បាស់លាស់ថែមទៀតនោះ នាងខ្ញុំទាំងពីររូបត្រូវបានបែងចែកជា ២ជំពូកគឺៈ

- **ជំពូកទី១ "ការស្នើសុំ និងការផ្តល់លិខិតអនុញ្ញាតសាងសង់"** នៅក្នុងជំពូកនេះ នាងខ្ញុំនិងបង្ហាញទាក់ទងទៅនឹងលិខិតអនុញ្ញាតសាងសង់ដែលមានដូចជា ការចាប់ផ្តើមនៃលិខិតអនុញ្ញាត

សាងសង់ លក្ខខណ្ឌក្នុងការផ្តល់លិខិតអនុញ្ញាតសាងសង់ ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការផ្តល់លិខិតអនុញ្ញាតសាងសង់ និងរយៈពេលនិងសុពលភាពនៃលិខិតអនុញ្ញាតសាងសង់ជាដើម។

- **ជំពូកទី២ "ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់"** នៅក្នុងជំពូកនេះផងដែរ នាងខ្ញុំនឹងធ្វើការបង្ហាញពាក់ព័ន្ធ ទៅនឹងការត្រួតពិនិត្យគុណភាពរបស់សំណង់ទាំងក្នុងអំឡុងពេលសាងសង់ និងក្រោយពេលសាងសង់ ក៏ដូចជាស្ថាប័នពាក់ព័ន្ធនានាដែលមានសមត្ថកិច្ចក្នុងការចុះត្រួតពិនិត្យផងដែរ។

# ជំពូកទី១

# ការផ្តល់លិខិតអនុញ្ញាតសាងសង់

# ជំពូកទី១ ៖ ការស្នើសុំ និងការផ្តល់លិខិតអនុញ្ញាតសាងសង់

## ១.១. មូលហេតុនៃការផ្តល់លិខិតអនុញ្ញាតសាងសង់

ដោយសារប្រទេសកម្ពុជាធ្លាប់មានការផ្លាស់ប្តូរនូវរបបជាច្រើន ហើយបញ្ហានៃការរៀបចំទឹកដី និងការរៀបចំទឹកដី និងការអភិវឌ្ឍន៍សង្គម ក៏ជួបប្រទះការលំបាក និងបញ្ហាស្មុគស្មាញយ៉ាងខ្លាំង ពិសេសលើការគ្រប់គ្រងវិស័យសំណង់នេះផងដែរ។ ដូច្នេះដើម្បីគ្រប់គ្រងលើវិស័យសំណង់ រាជរដ្ឋាភិបាលតម្រូវឱ្យមានការផ្តល់លិខិតអនុញ្ញាតសាងសង់ជាមុននូវរាល់សំណង់ទាំងអស់ដែលសាងសង់នៅក្នុងទីក្រុង ក៏ដូចជាទីប្រជុំជន។ មកទល់នឹងពេលបច្ចុប្បន្ននេះ វិស័យសំណង់បានដើរតួយ៉ាងសំខាន់ក្នុងការរៀបចំរចនាសម្ព័ន្ធក្នុងប្រទេសឱ្យមានសោភ័ណភាព និងសណ្តាប់ធ្នាប់ល្អ។ វិស័យនេះក៏ជាខឿនមួយទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចជាតិគួរឱ្យកត់សម្គាល់ផងដែរតាមរយៈការបង្កើតការងារដល់ប្រជាពលរដ្ឋ ការវិនិយោគ និងសោហ៊ុយលើសេវាសាធារណៈ។

### ១.១.១. ការការពារសណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាព

ដូចដែលបានដឹងរួចមកហើយថាចាប់តាំងពីឆ្នាំ១៩៧៩ មកដូចជាការចាប់ផ្តើមជីវិតថ្មីរបស់ប្រជាពលរដ្ឋខ្មែរ បន្ទាប់ពីបានបោះបង់ចោលទីលំនៅ រួចហើយក៏វិលត្រលប់មកវិញ បណ្តាលឱ្យដង់ស៊ីតេប្រជាពលរដ្ឋមានការកើនឡើងជាលំដាប់នៅតាមទីក្រុងនីមួយៗ ធ្វើឱ្យផ្នែកទីជម្រក គឺមានការខ្វះខាតដោយសារតែសំណង់ដែលនៅសេសសល់ក្រោយសង្គ្រាមពុំអាចធានាបាននូវ កំណើនប្រជាជនដែលកើនឡើងបានឡើយ។ ដូច្នេះទើបធ្វើឱ្យមានសំណង់ថ្មីបានចាប់ផ្តើមឡើងជាបន្តបន្ទាប់។ ប៉ុន្តែសំណង់ទាំងនោះ សុទ្ធសឹងតែជាសំណង់ដែលមិនមានច្បាប់ទម្លាប់ត្រឹមត្រូវនៅឡើយ ដោយសារពួកគេបានធ្វើការសាងសង់នៅលើដីសាធារណៈ ប្រឡាយ អូរ ចិញ្ចើមផ្លូវ បង្កឱ្យបាត់បង់នូវសំណ្តាប់ធ្នាប់សាធារណៈ អនាម័យ និងសោភ័ណភាព ហើយបង្កើតឱ្យមានអនាធិបតេយ្យនៅក្នុងទៅក្រុង និងទីប្រជុំជន។

ម្យ៉ាងវិញទៀត ដោយឃើញថាសម័យបច្ចុប្បន្ន នៅក្នុងប្រទេសកម្ពុជាមានការសាងសង់នូវអគារជាច្រើនដែលមានលក្ខណៈជា អគារពាណិជ្ជកម្ម ភោជនីយដ្ឋាន ឃ្លាំង រោងចក្រ សំណង់បុរី ផ្ទះល្វែង និងអគារការិយាល័យជាដើម។ ចាប់តាំងពីប្រទេសយើងបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ក៏ដូចជាសមាគមន៍អន្តរជាតិរួចមក យើងឃើញថាមានអ្នកវិនិយោគទុនបរទេសជាច្រើនបានចូលមកបណ្តាក់ទុននៅក្នុងប្រទេសកម្ពុជាដែលអាចធ្វើឱ្យមានការសាងសង់អគារកាន់តែកើនឡើង ដែលជាកត្តាមួយជំរុញឱ្យមាននូវការបង្កើតច្បាប់សំណង់ដើម្បីគ្រប់គ្រង ការពារសណ្តាប់ធ្នាប់ និងសោភ័ណភាពពីការសាងសង់សំណង់ដែលគ្មានរបៀបរៀបរយ និងដោះស្រាយសំណង់ដែលមិនអនុលោមទៅតាមបទប្បញ្ញត្តិសំណង់ ដែលបានធ្វើឱ្យបាត់បង់សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាពទីក្រុង ហើយដើម្បីឈានទៅរកការគ្រប់គ្រងល្អ ទើបរាជរដ្ឋាភិបាលតម្រូវឱ្យមានការផ្តល់លិខិតអនុញ្ញាតសាងសង់នេះជាមុនសិន។

### ១.១.២. ការយល់ដឹងរបស់ប្រជាពលរដ្ឋលើវិស័យច្បាប់

ដោយសារតែប្រទេសយើងទើបតែរួចផុតពីសង្គ្រាម ហើយបន្ទាប់ពីបានរៀបចំប្រទេសឡើងវិញ ធ្វើឱ្យនៅក្នុងប្រទេសយើងមានការខ្វះខាតនូវអ្នកចេះដឹងជាច្រើន ហើយចំពោះវិស័យអប់រំក៏នៅមានកម្រិតនោះឡើយ ដែលធ្វើឱ្យប្រជាពលរដ្ឋភាគច្រើនមិនទាន់បានយល់ដឹងច្បាប់នេះហើយដែលធ្វើឱ្យមានការសាងសង់ ហើយមិនបានផ្តល់ដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ចបានដឹងពីការកសាងនេះ ដែលអាចបង្កឱ្យមានទំនាស់កើតឡើងថែមទាំងបង្កើតជាបញ្ហាពិបាកដល់អ្នកគ្រប់គ្រងទីក្រុងទាក់ទងនឹងវិស័យសំណង់នេះ។

ម្យ៉ាងវិញទៀតដោយសារតែចាប់តាំងពីឆ្នាំ១៩៨៣ មកនៅពេលដែលគេធ្វើឯកជនភាវូបនីយកម្ម គឺដីចាប់ផ្តើមឡើងថ្លៃ ដែលធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនរឹតតែគ្មានលទ្ធភាពទិញដីសម្រាប់សាងសង់លំនៅដ្ឋានពោលគឺមានតែដីតែគ្មានលំនៅដ្ឋានទើបធ្វើឱ្យពួកគេបង្ខំចិត្តប្រព្រឹត្តនូវអំពើល្មើសច្បាប់ទាំងនោះ។ ដោយសារតែការមិនគិតដល់បញ្ហាច្បាប់នេះហើយ ដែលបណ្តាលឱ្យមានទំនាស់ទាក់ទងនឹងការងារសាងសង់នេះកើតឡើង។ ដូចនេះ ដើម្បីធានានូវសិទ្ធិស្របច្បាប់របស់បុគ្គលដែលជាម្ចាស់កម្មសិទ្ធិ និងជៀសវាងការសាងសង់ច្បាប់តទៅទៀត ទើបតម្រូវឱ្យមានការផ្តល់អនុញ្ញាតសាងសង់ជាមុន មុននឹងធ្វើការសាងសង់នូវសំណង់នានា។

ជារួមមកការផ្តល់លិខិតអនុញ្ញាតសាងសង់ គឺធ្វើឡើងដើម្បីជួយឱ្យការរៀបចំក្រុងមាន សោភ័ណភាពល្អ ការពារសណ្តាប់ធ្នាប់សាធារណៈ អនាម័យ ការពារទីធ្លាសាធារណៈ និងការពារតំបន់ហាមឃាត់មួយចំនួនទៀត កុំឱ្យមានការប្រព្រឹត្តអំពើល្មើសច្បាប់ ទៅលើវិស័យសំណង់បន្តទៀត ហើយថែមទាំងមានគោលដៅការពារផលប្រយោជន៍ស្របច្បាប់របស់បុគ្គលផងដែរ គឺទាំងអ្នកស្នើសុំ និងទាំងបុគ្គលដែលពាក់ព័ន្ធ។

## ១.២.ការកំណត់ប្រភេទសំណង់ក្នុងការផ្តល់លិខិតអនុញ្ញាតសាងសង់

ដើម្បីធានាដល់សុវត្ថិភាពសាធារណៈ និងទទួលបាននូវការការពារដីធ្លីសាធារណៈ សម្រាប់ដំណើរការរៀបចំទីក្រុង និងតំបន់កសិកម្មឱ្យមានរបៀបរៀបរយប្រសើរឡើងនោះ មិនមែនរាល់ការសាងសង់ទាំងអស់សុទ្ធតែទាមទារឱ្យមានការផ្តល់លិខិតអនុញ្ញាតសាងសង់ទេ[1]។ ដូចនេះហើយទើបអនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់បានបែងចែកនូវប្រភេទសំណង់ដែលតម្រូវឱ្យមានការផ្តល់លិខិតអនុញ្ញាតសាងសង់ និងសំណង់ដែលពុំចំណុះឱ្យលិខិតអនុញ្ញាតសាងសង់ ។

### ១.២.១ សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ជាមុន

រាល់ការសាងសង់ក្នុងទីក្រុង និងទីប្រជុំជនត្រូវមានលិខិតអនុញ្ញាតសាងសង់រាល់សំណង់ថ្មី សុទ្ធតែត្រូវមានលិខិតអនុញ្ញាតសាងសង់ដែរ។ ការសាងសង់សំណង់ឡើងវិញជាថ្មី ការពង្រីក និងការសាងសង់បន្ថែមពីល

[1] មាត្រា១២ នៃច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លើអគារដែលមានស្រាប់ គឺសុទ្ធតែតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។[2] ការផ្លាស់ប្តូរទ្រង់ទ្រាយអគារដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតសាងសង់ បើការនេះកែប្រែះ

- ការប្រើប្រាស់របស់ផ្នែកអគារ
- ទិដ្ឋភាពនៃអគារ
- ការបង្កើនបង្គន់អនាម័យ និងការបន្តភ្ជាប់ទៅបំពង់លូ
- បង្កើនផ្ទៃក្រឡាកម្រាលសំណង់
- ការធ្វើអាងប្រព្រឹត្តកម្មទឹកកខ្វក់ តភ្ជាប់ទៅបំពង់លូ
- កន្លែងទទួលសាធារណៈជន
- ទំរង់ដី (ចាក់ដីបំពេញ ជីកយកដីចេញ ឬប្រភេទដីស្រែចំការជាដីសាងសង់) ឬប៉ះពារខ្លាំងដល់ទិដ្ឋភាពទីដ្ឋានណាមួយដូចជា លុបបំបាត់បឹង ឬប្រឡាយបង្ហូរទឹក ឬផ្នែកណាមួយនៃប្រព័ន្ធបង្ហូរទឹកចេញ ការកាន់កាប់ដើមឈើដែលមានស្រាប់។ល។[3]

ការសាងសង់ ឬការកែទ្រង់ទ្រាយបបនភណ្ឌផ្សេងៗ ដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គីភ័យ ( ការដាក់ស៊ីទែនកន្លែងស្តុកប្រេងឥន្ទនៈ ឆាងជាងដែលមានផលិតផលគ្រឿងឆេះ កន្លែងទទួលសាធារណៈជន)។ល។ ការប្តូរទ្រង់ទ្រាយអគារឧស្សាហកម្ម ការដាក់ប៉ាណូផ្សាយពាណិជ្ជកម្ម ការដាក់អង់តែនទូរទស្សន៍ និងទូរគមនាគមន៍ ប៉ាណូស្រូបពន្លឺព្រះអាទិត្យ ក៏ដូចជារាល់គ្រឿងដទៃទៀត ដែលបំពាក់ទៅនឹងអគារ ហើយស្ថិតនៅជិតផ្លូវ ឬតាំងចំទិសដែលគេអាចមើលឃើញ សាលាក្រុង និងសាលាខេត្ត នឹងធ្វើការណែនាំដោយឡែក។[4]

### ១.២.២. សំណង់ដែលពុំចំណុះក្រោមលិខិតអនុញ្ញាតសាងសង់

សំណង់ជាលំនៅដ្ឋានប្រជាពលរដ្ឋដែលស្ថិតនៅទីជនបទ ឬតំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និងឆ្ងាយពីតំបន់រមនីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌជាតិ តំបន់រក្សាទុកការពារដោយពុំគិតពីទំហំ ឬសម្ភារៈសំណង់ប្រើប្រាស់។ ការជួសជុល និងថែរក្សាទាំងឡាយដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ឬទិដ្ឋភាពសំណង់ លើកលែងតែការជួសជុលនោះអាចបណ្តាលឱ្យប៉ះពាល់ដល់អ្នកជិតខាង។

បណ្តាសំណង់ដូចខាងក្រោមនេះ ដោយគ្រាន់តែជូនដំណឹងអំពីគំរោងសាងសង់ទៅអាជ្ញាធរមូលដ្ឋានដូចតទៅះ

- ទីសក្ការៈបូជា

[2] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា២

[3] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា២

[4] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា២

- សាលាសំណាក់សាធារណៈ
- និងបណ្តាការសិល្បៈរបស់រដ្ឋសម្រាប់សេវាសាធារណៈ ដែលរដ្ឋជាម្ចាស់កិច្ចការ។[5]

## ១.៣. ការត្រួតពិនិត្យ និងការរៀបចំសំណុំឯកសារផ្តល់លិខិតអនុញ្ញាតសាងសង់

ដើម្បីឱ្យការរៀបចំ និងការពិនិត្យសំណុំឯកសារផ្តល់លិខិតអនុញ្ញាតសាងសង់ចំពោះការសងសង់មួយមានភាពរលូនទៅមុខ ហើយប្រកបដោយប្រសិទ្ធភាព សុក្រឹត្យភាព និងតម្លាភាពទាន់ពេលវេលា និងត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសនោះ ក្រសួងបានធ្វើការរៀបចំឱ្យអាជ្ញាធរមានសមត្ថកិច្ច មុនផ្តល់លិខិតអនុញ្ញាតសាងសង់ត្រូវរៀបចំការត្រួតពីនិត្យនូវសំណុំឯកសារឱ្យបានច្បាស់លាស់ និងដើម្បីចៀសវាងកំហុសឆ្គងដោយប្រការណាមួយ។

### ១.៣.១. ការត្រួតពិនិត្យសំណុំឯកសារចាំបាច់

សំណុំឯកសារនៃពាក្យសុំផ្តល់លិខិតអនុញ្ញាតសាងសង់ ចំពោះក្រុងភ្នំពេញត្រូវយកពាក្យទៅដាក់នៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីក្រុងភ្នំពេញ។ ចំពោះខេត្តក្រុងដទៃទៀត ត្រូវយកទៅដាក់នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកខណ្ឌ។ តាមគោលការណ៍គ្មានលិខិតអនុញ្ញាតសាងសង់ណាមួយត្រូវបានផ្តល់ឱ្យទេ ប្រសិនបើលិខិតអនុញ្ញាតសាងសង់នោះមិនគោរពតាមច្បាប់ប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី និងសំណង់។

ប៉ុន្តែដោយសារប្រទេសយើង មិនទាន់មានការអនុម័តប្លង់ទាំងពីរនេះនៅឡើយ ទើបរាល់ការត្រួតពិនិត្យសំណុំឯកសារផ្តល់លិខិតអនុញ្ញាតសាងសង់ ត្រូវអនុវត្តតាមការកំណត់នៅក្នុង អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ តែត្រូវតាមប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី[6]។

#### ១.៣.១.១.សំណុំឯកសារ និងបណ្តាប្លង់ចាំបាច់

រាល់សំណុំឯកសារនៃពាក្យស្នើសុំ ម្ចាស់សំណង់ត្រូវធ្វើលើគំរូជាផ្លូវការដោយមានភ្ជាប់នូវវិញ្ញាបនបត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់អចនវត្ថុ ឬលិខិតកាន់កាប់បណ្តោះអាសន្ន និងសាលាកបត្រដីឡូត៍ ជាប្លង់ដីធ្វើឡើងដោយភ្នាក់ងារ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ឬធរខាគណិតឯកជនដែលមានការទទួលស្គាល់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហើយត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយអ្នកវាស់វែង ហើយអនុម័តដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រុង ហើយក្នុងប្លង់នោះ ត្រូវមានបញ្ជាក់អំពីប្លង់សំខាន់ៗមួយចំនួនទៀត ដែលពាក់ព័ន្ធនឹងសំណង់។ ម្យ៉ាងវិញទៀត សាលាខេត្តក្រុងអាចសុំឱ្យម្ចាស់សំណង់ ផ្តល់នូវសំណុំឯកសារបន្ថែមទៀតដោយ

[5] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា៣

[6] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់, លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា៧

មូលហេតុផ្នែកធរាសាស្ត្រ ផ្នែកការការពារបេតិកភណ្ឌ និងទេសភាព។ ហើយករណីមានការផ្លាស់ប្តូរទ្រង់ទ្រាយ ពង្រីកទំហំទៅលើបន្ថែមទៀត ម្ចាស់សំណង់ត្រូវបង្ហាញឱ្យឃើញពីភាពខុសគ្នារវាងប្លង់មុន និងប្លង់ថ្មីដែលសហគ្រាសធ្វើឡើងវិញ។

ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើលើគំរូលិខិតផ្លូវការ ហើយត្រូវមានភ្ជាប់សំណុំលិខិត ដែលមានយ៉ាងតិចបំផុតនូវបណ្តាប្លង់ដូចបញ្ជាក់ជា ១០ច្បាប់ បត់ទំហំ( ២១×២៩,៧ស.ម)៖

- វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់អចលនវត្ថុ ឬលិខិតកាន់កាប់ដីជាបណ្តោះអាសន្ន
- សាលាកប័ត្រដីឡូត៍: ប្លង់ដីនេះធ្វើឡើងដោយភ្នាក់ងារមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្ត។ នៅលើប្លង់នេះមានបញ្ជាក់អំពី៖
    - ទីតាំងនៃដីឡូត៍ដែលជាកម្មវត្ថុនៃពាក្យសុំ ទីតតាំងនៃដីឡូត៍ដែលនៅជាប់គ្នា ផ្លូវចូលទៅដីឡូត៍នោះ ហើយនឹងលក្ខណៈរបស់ផ្លូវនោះ (សាធារណៈ ឬឯកជន ឈ្មោះម្ចាស់កម្មសិទ្ធិ) ។
    - ឈ្មោះ ឬលេខ ផ្លូវលំ និងផ្លូវតូច
    - ផ្ទៃក្រឡាដីឡូត៍
    - បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូត៍ (ទីតាំង និង កំពស់ )
    - បណ្តាសំង់ដែលមានស្រាប់នៅលើដីឡូត៍ជាប់គ្នា ផ្ទៃបាត និងកំពស់របស់វា
    - មាត្រដ្ឋានប្លង់រង្វាស់ជ្រុង និងមុំនីមួយៗ ការកំណត់ទិស
    - ចំណុចនឹងថ្កល់សម្រាប់ជាគោលសម្គាល់កម្ពស់ ដែលបោះនៅលើដីឡូត៍
    - បន្ទាត់ជួរតម្រង់ផ្លូវសធារណៈ។
- ប្លង់ទីតាំងអគារក្នុងដីឡូត៍: មាត្រដ្ឋាន ១:២០០ (១:៥០០ ក្រោយទទួលការយល់ព្រមពីបណ្តាមន្ទីរទទួលបន្ទុកដីឡូត៍ធំៗ)។ នៅលើប្លង់នេះមានបញ្ជាក់អំពី៖
    - ការបោះទីតាំងនៃសំណង់ក្នុងដីឡូត៍ដែលជាកម្មវត្ថុនៃពាក្យសុំ ដោយមានបញ្ជាក់អំពីចម្ងាយរវាងអគារមួយឬច្រើននិងព្រំប្រទល់ដីឡូត៍ និងចម្ងាយទៅបណ្តាអគារនៅជិតខាងដែលមាន ស្រាប់។
    - រាល់ការរៀបចំផ្នែកផ្សេងៗ នៃដីទំនេរ ដយបញ្ជាក់ប្រភេទដីនិងដំណាំមានស្រាប់ និងទៅអនាគត បណ្តាកន្លែងចតរថយន្ត និងរបង (កំពស់ និងទីតាំង)។
    - ចំណុចនឹងថ្កល់នៃកម្ពស់ដីឡូត៍ ក្រោយការងាររៀបចំហើយ។
    - បំពង់លូក្រៅអគារ (រូបធាតុ វិជ្ឈមាត្រ ចំណោទ រណ្តៅពិនិត្យ) រហូតដល់កន្លែងតភ្ជាប់ទៅបណ្តាញ

សាធារណៈ សម្រាប់បញ្ចេញទឹកស្អុយ និងសំរាប់ទឹកស្អាត អាងបង្គន់អនាម័យ អណ្តូង។

- ប្លង់អគារគ្រប់ជាន់: មាត្រដ្ឋាន ១: ១០០

  នៅលើប្លង់នេះមានបញ្ជាក់ពី៖

  - គោលដៅប្រើប្រាស់រាល់បន្ទប់ និងផ្ទៃក្រឡារបស់វា
  - បណ្តាបបនភណ្ឌអនាម័យ និងកន្លែងដាក់បំពង់លូ
  - ចំពោះការរៀបចំទីទាំងឧស្សាហកម្ម ៖ របៀបរៀបចំទីតាំងគ្រឿងយន្ត។

- ប្លង់ផ្នែកបណ្តាញក្រោមដីនានា និងអាងបង្គន់អនាម័យ (មាត្រដ្ឋាន ១:១០០)
- ប្លង់មុខភាពនៃអគារ (មាត្រដ្ឋាន ១:១០០)។នៅលើបណ្តាប្លង់មុខភាពមានបង្ហាញអំពី៖
  - កំរិតកម្ពស់កំរាលនីមួយៗ កំរិតកម្ពស់ដីនៅជើងអគារ ដោយបញ្ជាក់កំរិតកម្ពស់ដីធម្មជាតិ ដីចាក់បំពេញ ឬដីចូកចេញ
  - កំរិតកម្ពស់ដំបូល និងព្រំដំបូល ឬកំរិតកម្ពស់នៅពេលសង់ហើយនៃដំបូលតែរាស់ និងក្បាំងក្បាលជញ្ជាំង
  - កំរិតកម្ពស់សង់នៃទ្រើងផ្កា
  - រូបធាតុសំរាប់មុខភាព
- ប្លង់ពុះពីរយ៉ាងតិចដែលមានមាត្រដ្ឋាន ១:១០០
- តារាងផ្ទៃក្រឡាមួយស្រាប់ជាន់នីមួយៗ
- សាលាកប័ត្រគណនាផ្ទៃបាតផ្ទាល់ដីនិងសន្ទស្សន៍នៃការប្រើប្រាស់។
- ចំពោះបណ្តាការផ្លាស់ប្តូរទ្រង់ទ្រាយ ពង្រីកទំហំ ពង្រីកឡើងលើ ប្លង់ត្រូវបង្ហាញរៀបខុសពីគ្នាចំពោះផ្នែកដែលមានពីមុន ការរុះរើ និងសភាពគ្រោងធ្វើ។ សាលាក្រុង និងសាលាខេត្តនីមួយៗ ត្រូវចេញសារាចរបញ្ជាក់អំពីខ្លឹមសារចាំបាច់ និងឯកសារបន្ថែមពាក់ព័ន្ធនឹងសំណុំលិខិតអនុញ្ញាតសាងសង់។
- ក្រោយពីទទួលលិខិតអនុញ្ញាតសាងសង់ហើយ ត្រូវមានប្លង់លំអិតគ្រឿងផ្គុំសំណង់ ដែលត្រូវពិនិត្យដោយក្រសួងសាធារណៈការនិងដឹកជញ្ជូនមុនបើកការដ្ឋានសាងសង់។[7]

**១.៣.១.២. គោលការណ៍ពីរដ្ឋានិបាល**

សំណុំលិខិតអនុញ្ញាតសាងសង់ទាំងអស់ ត្រូវជាភាសាខ្មែរ។ អត្ថបទជាភាសាអង់គ្លេស ឬភាសាបារាំង ឬភាសាផ្សេងទៀតអាចផ្តល់ភ្ជាប់ជាមួយលិខិតនេះ។[8] ពាក្យសុំលិខិតអនុញ្ញាតសាងសង់ និងបណ្តាប្លង់ ត្រូវមាន

[7] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា៩

[8] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា១០

ចុះហត្ថលេខាដោយម្ចាស់ដី និងអ្នកធ្វើគម្រោង។ កាលណាអ្នកសុំពុំមែនជាម្ចាស់កម្មសិទ្ធិ អ្នកសុំដែលបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ក៏ត្រូវចុះហត្ថលេខាលើសំណុំលិខិតពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ដែរ[9]។

អ្នកធ្វើគម្រោងត្រូវតែជាស្ថាបត្យករខ្មែរ ឬបុគ្គលមានការរួមចំណែកជាមួយស្ថាបត្យករខ្មែរ ហើយដែលត្រូវបានទទួលស្គាល់ពីរាជរដ្ឋាភិបាល ស្នើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច ឬដោយគណៈសាបត្យករ បន្ទាប់ពីគណៈស្ថាបត្យករខ្មែរនេះបានបង្កើតឡើង។ ក្នុងករណីដែលសំនង់មានទំហំលើសពី៥០០ម៉ែត្រទ្វេរគុណ គម្រោងអាចធ្វើបានដោយស្ថាបត្យករតែប៉ុណ្ណោះ។[10]

### ១.៣.២. ការពិនិត្យលក្ខខណ្ឌចាំបាច់

ក្រោយពេលដាក់ពាក្យរួច អាជ្ញាធរដែនដីត្រូវត្រួតពិនិត្យ និងវាយតម្លៃលើសំណង់ដែលតាំងនៅ ថាស្ថិតក្នុងដីសាធារណៈរដ្ឋ ឬតំបន់ហាមឃាត់រឺទេ ដោយមើលក្នុងប្លង់ប្រើប្រាស់ដីធ្លី និងប្លង់គោល ឬក្នុងអនុក្រឹត្យលេខ ៨៦ស្តីពីលិខិតអនុញ្ញាតសាងសង់(ករណីដែលគ្មានប្លង់ប្រើប្រាស់ដីធ្លី និងប្លង់គោល) ថាតើបំពេញនូវលក្ខខណ្ឌដើម្បីឱ្យលិខិតអនុញ្ញាតសាងសង់មានសុពលភាពអនុវត្តហើយឬនៅ? ដែលលក្ខណ្ឌទាំងនោះរួមមានដូចជា ប្លង់ជួរតម្រង់ និងប្លង់កម្ពស់។

#### ១.៣.២.១. ប្លង់ជួរតម្រង់

ប្លង់ជួរតម្រង់ គឺជាប្លង់ដែលគោរពតាមជួរតំរង់នៃអគារជិតខាង ហើយមានទំហំពីអ័ក្សផ្លូវប្រវែងស្មើគ្នាស្ថិតនៅតាមបណ្តោយផ្លូវតែមួយ។

**ក.ការកំណត់ប្លង់ជួរតម្រង់**

ការកំណត់ប្លង់ជួរតម្រង់ត្រូវបានចែកចែញជាពីរគឺ ការកំណត់ក្នុងលក្ខខណ្ឌទូទៅ និងការកំណត់ក្នុងលក្ខខណ្ឌពិសេស។

**ក.១.ការកំណត់ក្នុងលក្ខណៈទូទៅ**

សំណង់ទាំងឡាយត្រូវបោះទីតាំងលើជួរតម្រង់ផ្លូវសាធារណៈឬឃ្លាតថយពីជួរតម្រង់យ៉ាងតិច ៤ម៉ែត្រ។ ការកំណត់ដូចនេះ ត្រូវយកមកអនុវត្តក្នុងករណីមិនទាន់មានប្លង់ប្រើប្រាស់ដីធ្លី និងប្លង់គោល។ ម៉្យាងវិញទៀតក្នុងការប្រតិបត្តិខាងលើ យើងបានធ្វើការកំណត់នូវប្រភេទដីជាពីរករណីសម្រាប់ការសាងសង់ តាមមុខងាររបស់អគារ និងការកំណត់គម្លាតសម្រាប់ការសាងសង់ផងដែរ ដើម្បីរក្សាឱ្យបាននីរសោភ័ណភាពរបស់សំណង់។

ចំពោះការកំណត់ក្នុងលក្ខខណ្ឌទូទៅគឺ សំណង់ទាំងឡាយត្រូវបោះទីតាំងលើជួរតម្រង់សាធារណៈ ឬឃ្លាតថយពីជួរតម្រង់យ៉ាងតិច ៤ម៉ែត្រ។ ការកំណត់ដូចនេះត្រូវយកមកក្នុងករណីមិនទាន់មានប្លង់ប្រើប្រាស់ដីធ្លី

[9] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា១១

[10] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា១១

និងប្លង់គោល។ ម្យ៉ាងវិញទៀត ក្នុងការប្រតិបត្តិខាងលើ យើងបានធ្វើការកំណត់នូវប្រភេទដីជាពីរករណី សម្រាប់ការសាងសង់តាមមុខងាររបស់អគារ និងការកំណត់នូវគម្លាតសម្រាប់ការសាងសង់ផងដែរ ដើម្បីរក្សាឱ្យបានសោភណ្ឌភាពរបស់សំណង់។

• **ករណីដីឡូតិ៍សម្រាប់ភូមិគ្រឹះ** ៖ យើងបានធ្វើការកំណត់គម្លាត ៤ម៉ែត្រយ៉ាងតិចពីព្រំដីឡូតិ៍ និងទុកចិញ្ចើមយ៉ាងតិច ៥ម៉ែត្រ ពោលគឺគិតពីថ្នល់មកទល់នឹងរបងនៃដីឡូតិ៍ភូមិគ្រឹះយ៉ាងតិច ៩ម៉ែត្រ។ ចំពោះការកសាងភូមិគ្រឹះវិញ គេគិតនូវគម្លាតដែលអនុញ្ញាតឱ្យមានការសាងសង់ចម្ងាយ ៤ម៉ែត្រយ៉ាងតិចគិតពីរបងទៅដល់ភូមិគ្រឹះ ឬអាចសាងសង់បាន ៥០ភាគរយនៃផ្ទៃដី ហើយផ្ទៃដែលនៅសល់ត្រូវចាត់ចែងរៀបចំជាសួនផ្សេងៗ[11]។ ប៉ុន្តែបច្ចុប្បន្ន យើងសង្កេតឃើញថា ការប្រតិបត្តិតាមការកំណត់ក្នុងអនុក្រឹត្យពុំទាន់មានការអនុវត្តទាំងស្រុងពីសំណាកប្រជាពលរដ្ឋនៅឡើយទេ ពោលគឺសំណង់ខ្លះសាងសង់ខុសពីការកំណត់ និងសំណង់មួយចំនួនសង់គោរពតាមការកំណត់។

• **ករណីដីឡូតិ៍សម្រាប់ផ្ទះល្វែង**៖ ការកំណត់គម្លាតចំពោះផ្ទះល្វែងវិញ គឺយើងកំណត់ដោយគិតពីថ្នល់មកទល់មុខផ្ទះត្រូវរក្សាគម្លាត៤ម៉ែត្រយ៉ាងតិច ពីជួរតម្រង់អគារឬព្រំដីឡូតិ៍ ពោលគឺគម្លាតមុខចោល ៤ម៉ែត្រយ៉ាងតិច ក្រោយ២ម៉ែត្រ ចំហៀង២ម៉ែត្រ តែអាចអនុគ្រោះគម្លាតចំហៀងតូចជាង២ម៉ែត្រ តែត្រូវគោរពទៅតាមផលធៀបផ្ទៃបាតនៃសំណង់គឺ ៧៥ភាគរយ ហើយចំពោះផ្ទះល្វែងដែលស្ថិតនៅប្លុកតភ្ជាប់ គឺអាចសង់ជាប់ព្រំសាធារណៈដូចជា ផ្ទះល្វែងនៅក្នុងបុរីនីមួយៗជាដើម។ ដោយឡែកចំពោះគម្លាតដែលបានលយទៅលើចិញ្ចើមថ្នល់ និងព្រំដីឡូតិ៍នោះ គឺមិនអនុញ្ញាតឱ្យប្រក់ដំបូលអាលុយមីញ៉ូមទេ ដោយសារធ្វើឱ្យបាត់បង់សោភណ្ឌភាពទីក្រុង។

ប៉ុន្តែការកំណត់ដូចបានបរិយាយខាងលើ មិនអាចអនុវត្តបានទាំងស្រុងនោះទេនៅក្នុងទីក្រុងភ្នំពេញ និងទីរួមខេត្តមួយចំនួនដែលកំពុងអភិវឌ្ឍ ព្រោះស្ថានភាពនៃតំបន់មិនទុកលទ្ធភាពឱ្យរក្សាគម្លាតបានពីថ្នល់យ៉ាងតិច ៤ម៉ែត្រនោះទេ។ ហេតុនេះ ការរៀបប្លង់ជួរតម្រង់ត្រូវអនុវត្តតាមស្ថានភាពទីតាំងភូមិសាស្រ្តនៃតំបន់នីមួយៗ ទើបធ្វើឱ្យការកំណត់គម្លាតជាមធ្យមពីថ្នល់ត្រូវតែចន្លោះពី ២ម៉ែត្រទៅ ៧ម៉ែត្រ ហើយចំពោះគម្លាត២ម៉ែត្រដែលយើងឃើញនោះជាក់ស្តែងអាចបានព្រោះស្ថិតនៅក្នុងប្លុកតភ្ជាប់ តែខុសពីប្លុកនេះ មិនដែលមានការអនុញ្ញាតឱ្យរក្សាគម្លាត២ម៉ែត្រទេ បើមាន គឺការសាងសង់នោះខុសពីច្បាប់អនុញ្ញាត ហើយក៏មានតំបន់សំខាន់មួយចំនួនអាចមានការកំណត់គម្លាតលើសពីនេះ ឬអាចតម្រូវបន្ថែមឱ្យមានគម្លាតពីថ្នល់ផងដែរ។ ដូច្នេះហើយចំពោះការកំណត់គម្លាតឱ្យច្បាស់លាស់ និងត្រឹមត្រូវដូចគ្នាមួយ គឺមិនអាចធ្វើទៅបានទេ។

[11] សៀវភៅមេរៀន នគរូបនីយវិទ្យា ឆ្នាំ២០១៩ របស់បណ្ឌិត អ៊ុន សកក្កដា

### ក.២.សមត្ថកិច្ចក្នុងការកំណត់ប្លង់ជួរតម្រង់

សមត្ថកិច្ចក្នុងការរៀបចំប្លង់ជួរតម្រង់ គឺទទួលបន្ទុកដោយអភិបាលខេត្តក្រុង ឬប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងនានា និងក្រសួងជំនាញពាក់ព័ន្ធ ជាអ្នកកំណត់ប្លង់ជួរតម្រង់ផ្លូវសាធារណៈ និងទីធ្លាសាធារណៈ។ ការកំណត់នេះ ត្រូវឃ្លាតថយហួសពីថ្នល់ទៅតាមបណ្តាខេត្តក្រុងនានាក្នុងតំបន់គ្រប់គ្រងរបស់ខ្លួន។ ចំពោះខេត្តក្រុង ឬទីប្រជុំជនណាដែលមានប្រជាជនលើសពី ២០០០០នាក់( ពីរម៉ឺននាក់) ត្រូវមានការយល់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាមុនសិន រួមទាំងដីចំណីសាធារណៈ និងធ្លាគំលាតនៃផ្លូវជាតិ ផ្លូវសំខាន់ៗដែលពាក់ព័ន្ធនឹងការរៀបចំទីក្រុង និងនគរូបនីយកម្ម ជាអាទិ៍ផ្លូវទំនប់[12]។

### ១.៣.២.២. ប្លង់កម្ពស់

ប្លង់កម្ពស់ គឺជាប្លង់ដែលគេបានធ្វើកំណត់នូវកម្ពស់របស់អគារនៃតំបន់ណាមួយ តាមរយៈប្លង់ប្រើប្រាស់ដីធ្លី និងប្លង់គោលនាតំបន់នីមួយៗនៅក្នុងប្រទេស។

### ក.ការកំណត់ប្លង់កម្ពស់

ការកំណត់ប្លង់កម្ពស់នៅកម្ពុជាចែកចេញជាពីរគឺ៖ ការកំណត់ក្នុងលក្ខណៈទូទៅ និងការកំណត់ក្នុងលក្ខខណ្ឌពិសេស។

•**ការកំណត់ក្នុងលក្ខខណ្ឌទូទៅ៖** ការកំណត់ប្លង់កម្ពស់ ក្នុងការសាងសង់សំណង់អ្វីមួយចាំបាច់ត្រូវគិតទៅដល់ចំណុចសំខាន់ៗក្នុងតំបន់ដែលធ្វើការសាងសង់ពោលគឺយើងត្រូវធ្វើការពិនិត្យឱ្យបានច្បាស់នូវកម្ពស់មធ្យមនៃសង្កាត់ ខណ្ឌឬទីប្រជុំជននីមួយៗ និងលក្ខណៈសំខាន់ៗនៃតំបន់ ហើយត្រូវធ្វើការវិនិច្ឆ័យឱ្យបានត្រឹមត្រូវនូវប្រភេទនៃសំណង់ សម្រាប់សាងសង់ដើម្បីឱ្យការរៀបចំទីក្រុង និងទីប្រជុំជនកាន់តែមានសោភ័ណ្ឌភាពថែមទៀត។

• **ការកំណត់ក្នុងលក្ខខណ្ឌពិសេស៖** តាមគោលការណ៍ការអនុញ្ញាតឱ្យសាងសង់សំណង់ មានការកំណត់កម្ពស់បែបនេះគឺវាមាន លក្ខណៈដូចគ្នាទៅនឹងការរៀបចំប្លង់ជួរតម្រង់ដែរ មានន័យថាវាអាស្រ័យទៅលើទីតាំងនៃតំបន់នីមួយៗនៅក្នុងទីក្រុងនានាក៏ដូចជាទីក្រុងនិងទីប្រជុំជនដែរ។ ប៉ុន្តែចំពោះការកំណត់កម្ពស់នៃអគារដែលអាចធ្វើការសាងសង់បាននាពេលបច្ចុប្បន្ននេះពុំទាន់មានការកំណត់ច្បាស់លាស់នៅឡើយទេ ដោយហេតុថាការរៀបចំប្លង់កម្ពស់សព្វថ្ងៃ គឺការកំណត់កម្ពស់សំណង់យកតាមកម្ពស់សំណង់ចាស់ៗ ដែលមានបន្សល់ទុកពីមុនមកធ្វើជាគោលការណ៍។

[12] សៀវភៅមេរៀន នគរូបនីយវិទ្យា ឆ្នាំ២០១៧ របស់បណ្ឌិត អ៊ុន សកក្កដា

#### ១.៣.២.៣. ប្រភេទ ការកំណត់ទីតាំង និងបណ្តាញផ្លូវពាក់ព័ន្ធ

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះសំណង់ទាំងឡាយណាដែលទីតាំង ប្រភេទ ទំហំ មានលក្ខណៈនាំឱ្យប៉ះពាល់ដល់សុខមាលភាព ឬដល់សុវត្ថិភាពសាធារណៈ នាំឱ្យរំខាន ឬបណ្តាលឱ្យមានមហន្តរាយ។[13]

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះ៖

- ទីដីដែលអាចមានមហន្តរាយ តំបន់បាក់ស្រុតរលំ តំពន់ដីសើមដែលត្រូវការពារ តាមមាត់ច្រាំង ទន្លេ ព្រែក ស្ទឹង បឹងបួ ដែលពុំមានភាពរឹងមាំគ្រប់គ្រាន់ ហើយអាចបណ្តាលឱ្យមានគ្រោះថ្នាក់ចំពោះសុវត្ថិភាពរបស់មនុស្ស និងសម្បត្តិទ្រព្យ លើកលែងតែភូមិដ្ឋានទាំងនោះបានអនុម័តតាមប្លង់គោល។[14]
- សំណង់អាចត្រូវទទួលរងធាតុរំខានខ្លាំងៗ ឬបើសំណង់នោះអាចបង្កធាតុរំខានដោយសំលេងខ្លាំងៗ[15]
- សំណង់ដែលមានប្រភេទ ទំហំ ឬទីតាំងអាចបណ្តាលឱ្យអន្តរាយដល់ការអភិរក្ស ឬអន្តរាយដល់ការលើកកម្ពស់តម្លៃនៃរមណីយដ្ឋាន ឬកេរ្តិ៍ដំណែលប្រវត្តិសាស្ត្រជាដើម[16]។
- សំណង់ដែលធ្វើសាងសង់នៅលើដីដែលពុំមានផ្លូវចេញចូលដូចជា ផ្លូវសាធារណៈ ផ្លូវឯកជន ច្រកផ្លូវ ឬ ផ្លូវឆ្លងកាត់ដែលទទឹងត្រូវសមាមាត្រស្របទៅនឹងទំហំ និងការប្រើប្រាស់នៃអគារ ហើយពុំអាចមានទទឹងតិចជាង ៣.៥ម៉ែត្រដែលជាទំហំចាំបាច់សម្រាប់ឱ្យរថយន្តពន្លត់អគ្គិភ័យចូលបាន[17]។
- សំណង់ដែលបោះទីតាំងតាមផ្លូវដងផ្លូវសាធារណៈដូចជា នៅលើដីចំណីផ្លូវ ឬធ្លាគម្លាតនៃផ្លូវជាតិ។

លើសពីនេះទៅទៀត សំណង់អគារត្រូវតែធានាឱ្យមានបណ្តាញផ្គត់ផ្គង់ទឹកស្អាតដោយអ្នកស្នើសុំត្រូវតែបញ្ជាក់អំពីលក្ខណៈបច្ចេកទេសរបស់អណ្តូង និងគុណភាពទឹក ហើយគ្រប់បណ្តាលំនៅដ្ឋាន ត្រូវតែមានការផ្គត់ផ្គង់ដោយបណ្តាញទឹកស្អាត និងមាននូវប្រព័ន្ធលូដើម្បីបញ្ចេញចោលនូវទឹកកខ្វក់ផ្សេងៗ។[18]

## ១.៤. សមត្ថកិច្ចក្នុងការផ្តល់លិខិតអនុញ្ញាសាងសង់

ស្ថាប័នដែលមានសមត្ថកិច្ចក្នុងការផ្តល់លិខិតអនុញ្ញាតសាងសង់នៅកម្ពុជាមានពីរថ្នាក់ គឺថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបែងចែកជា២គឺ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម

[13] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា២៧

[14] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា២៧.១

[15] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា២៧.២

[16] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា២៧.៣

[17] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា២៧.៤

[18] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា៣១

និងសំណង់ និងរាជរដ្ឋាភិបាល។ ខណៈដែលរដ្ឋបាលថ្នាក់ក្រោមជាតិមាន សាលាក្រុង ស្រុក ខណ្ឌ និងសាលារាជធានី-ខេត្ត។

### ១.៤.១. អាជ្ញាធរថ្នាក់ជាតិ

លិខិតអនុញ្ញាតសាងសង់មួយចំនួន ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល។ រាជរដ្ឋាភិបាលមានសមត្ថកិច្ចសម្រេចផ្តល់លិខិតអនុញ្ញាតសាងសង់ ចំពោះប្រភេទសំណង់ដូចជា៖

- បណ្តាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម និងឧស្សាហកម្មដែលមានផ្ទៃក្រឡាកម្រាលលើសពី ៣.០០០ ម៉ែត្រទ្វេគុណ
- រាល់សណ្ឋាគារ ត្រូវចាត់ទុកជាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម
- បណ្តាអគារសម្រាប់ការបង្កបង្កើនផលកសិកម្ម សម្រាប់ធ្វើអាជីវកម្មពី ៥០០ហិចតាឡើងទៅ
- បណ្តាអាកាសយានដ្ឋាន កំពង់ផែ ស្ថានីយអយស្ម័យយាន និង ស្ថានីយរថយន្ត
- បណ្តាសំណង់សាធារណៈ និងឯកជនដែលមានផ្ទៃក្រឡាកម្រាលលើសពី ៣.០០០ម៉ែត្រទ្វេគុណ និងផ្ទៃកពង្រីកបន្ថែមដោយគិតទាំងអគារមានស្រាប់ ដែលលើសពី ៣.០០០ ម៉ែត្រទ្វេគុណ ( វប្បធម៌ អប់រំ កីឡា រដ្ឋបាល ទេសចរណ៍ សុខាភិបាល ថាមពល...)
- បណ្តាសំណង់សំខាន់ៗ ក្នុងទីដ្ឋានការពារ ក្នុងក្របខ័ណ្ឌបរិស្ថាន ទេសភាព បេតិកភណ្ឌ ប្រវត្តិសាស្ត្របុរាណវត្ថុ និងវប្បធម៌
- ការកែប្របណ្តាអគារ ជាផលប្រយោជន៍បេតិកភណ្ឌដែលបានកំណត់ទុក
- បណ្តាសំណង់លើទឹកដីក្នុងភាពមើលឃើញទៅវិញទៅមក ជាមួយប្រាង្គប្រាសាទប្រវត្តិសាស្ត្រ
- បណ្តាសំណង់ និងការ្យ សំរាប់ការពារ និងអគារយោធា។

ក្នុងករណីនេះ លិខិតអនុញ្ញាតសាងសង់ត្រូវចុះហត្ថលេខាដោយប្រធានគណៈកម្មធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ បន្ទាប់ពីទទួលបានយោបល់ឯកភាពពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ។[19]

### ១.៤.២. អាជ្ញាធរថ្នាក់ក្រោមជាតិ

សាលាខេត្ត ក្រុង ជាអាជ្ញាធរដែលមានសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតសាងសង់រាល់សំណង់ដែលមានទំហំតូចជាង ៣០០០ម៉ែត្រទ្វេរគុណ និងមានសិទ្ធិបដិសេដគ្រប់ពេល វេលារាស់សំណង់ដែលស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ខ្លួន។ រាល់ពេលដែលធ្វើការបដិសេធការកែតំរូវគំពាងប្លង់ ឬមិនផ្តល់លិខិតអនុញ្ញាតសាងសង់ឱ្យម្ចាស់សំណើក្នុងករណីណាក៏ដោយ ត្រូវធ្វើលិខិតជាលាយលក្ខណ៍អក្សរថែមទាំង បង្ហាញ

[19] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា៥

មូលហេតុឱ្យបានច្បាស់លាស់ទៅឱ្យម្ចាស់សំណើឱ្យបានដឹងប្រសិនបើសាលាខេត្ត-ក្រុងយល់ឃើញថា ការសាងសង់នោះមានការប៉ះពាល់ឬខុសឆ្គងដល់តំបន់ដែលច្បាប់ធ្វើការហាមឃាត់។[20] ឧទហរណ៍៖ ម្ចាស់សំណង់បានធ្វើការសាងសង់នៅលើតំបន់បេតិកភណ្ឌវប្បធម៌ ឬទីតាំងដែលងាយរងគ្រោះថ្នាក់ ឬនៅលើទីដ្ឋានសួនច្បារ/ដីចំណែកផ្លូវសាធារណៈ សាលាខេត្តក្រុងអាចធ្វើការបដិសេធបាន។ ចំពោះសំណង់ដែលមានលក្ខណៈសមស្របនឹងត្រឹមត្រូវគឺ ត្រូវចុះហត្ថលេខាដោយអភិបាលខេត្ត-ក្រុង។

ដោយឡែកសម្រាប់សមត្ថកិច្ចរបស់ក្រុង ស្រុក ខណ្ឌ ដែលទទួលប្រតិភូកម្មអំណាចក្នុងការចេញលិខិតអនុញ្ញាតសាងសង់វិញ គឺចំពោះសំណង់លំនៅឋានមានផ្ទៃក្រឡាសាងសង់ស្មើ ឬតូចជាង ៥០០ម៉ែត្រក្រឡា។

## ១.៥. ការផ្សព្វផ្សាយលិខិតអនុញ្ញាតសាងសង់ និងអង្កេតសាធារណៈ

អាជ្ញាធរមានសមត្ថកិច្ចផ្សព្វផ្សាយដំណឹងដល់សាធារណៈជន អំពីការដាក់ពាក្យសុំដោយបិទប្រកាសផ្សាយនៅសាលាខ័ណ្ឌ ស្រុក ខេត្ត និងនៅកន្លែងសាងសង់គម្រោង។ កាលបរិច្ឆេទជាផ្លូវការនៃការដាក់ពាក្យសុំត្រូវចារក្នុងសំណុំលិខិតហើយជូនដំណឹងដល់អ្នកស្នើសុំ។ ម្យ៉ាងទៀតចំពោះអគារ និងបណ្ដាការ្យធំៗ ឬដែលដែលមានប្រភេទអាចធ្វើឱ្យរំខានដល់សុវត្ថិភាព សុខមាលភាពសាធារណៈនោះ ត្រូវផ្សព្វផ្សាយដល់សាធារណៈជន ពីការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ដោយវិធីណាមួយផ្សេងទៀត ដែលគេយល់ឃើញថាមានប្រសិទ្ធភាពជាង ដោយផ្អែកលើមធ្យោបាយផ្សាយព័ត៌មាននៅតាមមូលដ្ឋាន។

រាល់បុគ្គលពាក់ព័ន្ធអាចសាកសួរសុំមើលសំណុំលិខិត នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ចំពោះរាជធានីភ្នំពេញ និងនៅសាលាស្រុក ឬសាលាខេត្តចំពោះខេត្ត ក្នុងរយៈពេល ២៥ថ្ងៃ និងអាចធ្វើការតវ៉ាបាន ឬទាមទារទៅអាជ្ញាធរមានសមត្ថកិច្ច។ បណ្ដឹងតវ៉ាទាំងនោះត្រូវដាក់បញ្ចូលទៅក្នុងសំណុំលិខិតពាក្យសុំ។

អាជ្ញាធរមូលដ្ឋានពិនិត្យមើលការជំទាស់ ដែលទទួលបានក្នុងពេលអង្កេត និងធ្វើរបាយការណ៍មួយជូនទៅសាលាខេត្ត សាលាក្រុងក្នុងរយៈពេល ៥ថ្ងៃ។ សាលាខេត្ត សាលាក្រុង ឬគណៈកម្មការ ចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) គណៈកម្មការនេះត្រូវសម្រេចអំពីសុពលភាពនៃបណ្ដឹងតវ៉ា។[21]

## ១.៦. រយៈពេលនៃការពិនិត្យសម្រេចលើពាក្យសុំលិខិតអនុញ្ញាសាងសង់

តាមគោលការណ៍ រយៈពេលត្រួតពិនិត្យសំណុំឯកសារនៃពាក្យសុំ គឺមានរយៈពេល ៤៥ថ្ងៃនៃថ្ងៃធ្វើការ។ រយៈពេលនេះគិតចាប់ពីថ្ងៃដែលរាល់លិខិតស្នាមភ្ជាប់ជាមួយ និងពាក្យសុំលិខិតអនុញ្ញាតសាងសង់បានបំពេញសព្វគ្រប់។[22]

[20] សៀវភៅមេរៀន នគរូបនីយវិទ្យា របស់បណ្ឌិត អ៊ុន សកក្កដា

[21] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា១២

[22] អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់,លេខ៨៦អនក្រ/បក, ១៩ ធ្នូ ១៩៩៧, មាត្រា១៤

### ១.៦.១. សមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត

ចំពោះការដាក់ពាក្យសុំផ្តល់លិខិតអនុញ្ញាតសាងសង់ ម្ចាស់សំណើត្រូវដាក់ពាក្យនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ និងចំពោះទីក្រុងភ្នំពេញត្រូវដាក់នៅការិយាល័យរដ្ឋបាលនៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីក្រុង តាមរយៈអាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ ស្រុក ខណ្ឌ ឬអង្គភាពពាក់ព័ន្ធក្នុងករណីចាំបាច់។

បន្ទាប់មកអាជ្ញាធរមូលដ្ឋានឃុំ សង្កាត់ ស្រុក ខណ្ឌ ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ឬអង្គភាពពាក់ព័ន្ធក្នុងករណីចាំបាច់ ត្រូវបញ្ជូនសំណុំឯកសារទៅសាលាខេត្តក្រុងដើម្បីពិនិត្យសម្រេច រួចហើយសាលាខេត្ត ក្រុង មានសមត្ថកិច្ចត្រួតពិនិត្យ និងសម្រេចលើសំណុំឯកសារនៃពាក្យសុំផ្តល់លិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ៣០ថ្ងៃនៃថ្ងៃធ្វើការ។ស្ថិតក្នុងរយៈពេលនេះ មន្ទីររៀបចំដែនដី នគរូបណីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុងធ្វើការត្រួតពិនិត្យ សម្រេចលើសំណុំឯកសារនេះក្នុងរយៈពេលយ៉ាងយូរ ២៥ថ្ងៃនៃថ្ងៃធ្វើការ និងសាលាខេត្ត ក្រុង ត្រួតពិនិត្យយ៉ាងយូរ៥ថ្ងៃនៃថ្ងៃធ្វើការ និងមានការបែងចែកនូវបរិបទនៃការត្រួតពិនិត្យរួមទាំងរយៈពេលកំណត់នៅតាមមន្ទីរជំនាញក្រោមឱវាទបន្តទៀត។

### ១.៦.២.សមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ចំពោះរយៈពេលនៃការពិនិត្យលើសំណង់ដែលជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គឺមានរយៈពេល ៤៥ថ្ងៃ នៃថ្ងៃធ្វើការដោយគិតចាប់ពីពេលដែលទទួលបានសំណុំឯកសារពាក្យសុំគ្រប់គ្រាន់នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មានសិទ្ធិធ្វើការត្រួតពិនិត្យ និងសម្រេចលើសំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់ ក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃ នៃថ្ងៃធ្វើការ ដោយមិនគិតពីរយៈពេល៣០ថ្ងៃនៃថ្ងៃធ្វើការរបស់សាលាខេត្តក្រុង។ ស្ថិតនៅក្នុងពេលនោះ អគ្គនាយកដ្ឋានរដ្ឋបាល មានរយៈពេលយ៉ាងយូរ ១ថ្ងៃនៃថ្ងៃធ្វើការ និងអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម មានរយៈពេលត្រួតពិនិត្យយ៉ាងយូរ ១២ថ្ងៃនៃថ្ងៃធ្វើការ ហើយនៅអគ្គនាយកដ្ឋានសំណង់មានរយៈពេលយ៉ាងយូរ ១០ថ្ងៃនៃថ្ងៃធ្វើការ ស្របពេលដែលអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្មធ្វើការត្រួតពិនិត្យផងដែរ។ ចំណែកនៅខុទ្ទការល័យវិញមានរយៈពេលយ៉ាងយូរ ២ថ្ងៃនៃថ្ងៃធ្វើការ និងមានការបែងចែកនូវបរិបទនៃការត្រួតពិនិត្យ រួមទាំងរយៈពេលកំណត់ទៅតាមមន្ទីរជំនាញក្រោមឱវាទបន្តទៀត។

### ១.៦.៣. នីតិវិធីត្រួតពិនិត្យ និងសម្រេចលើសំណុំឯកសារផ្តល់លិខិតអនុញ្ញាតសាងសង់

រាល់ការត្រួតពិនិត្យ និងសម្រេចលើពាក្យសុំលិខិតអនុញ្ញាតសាងសង់ អាជ្ញាធរមានសមត្ថកិច្ចត្រូវសម្រេចក្នុងរយៈពេល ៤៥ថ្ងៃ គិតចាប់ពីថ្ងៃដែលរាល់លិខិតស្នាម ឬសំណុំឯកសារពាក់ព័ន្ធ ដែលភ្ជាប់មកជាមួយ

លិខិតអនុញ្ញាតសាងសង់ត្រូវបានបំពេញចប់សព្វគ្រប់ និងត្រឹមត្រូវហើយចាប់ពីពេលនោះម្ចាស់សំណើមានសិទ្ធិទទួលបាននូវបង្កាន់ដៃទទួលពាក្យសុំ ដែលក្នុងរយៈពេលកំណត់នេះម្ចាស់សំណើរត្រូវទទួលដំណឹងអំពីសេចក្តីសម្រេចនេះជាលាយលក្ខអក្សរស្តីពីការអនុញ្ញាត ឬមិនអនុញ្ញាត ឬអនុញ្ញាតតែស្នើសុំឱ្យធ្វើការកែសម្រួលបន្ថែម ហើយប្រសិនជាមានការបដិសេធ អាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើជាលាយលក្ខអក្សរជូនទៅម្ចាស់សំណើវិញ។

ក្នុងករណីដែលពិនិត្យទៅឃើញថា សំណុំឯកសារនៃពាក្យសុំផ្តល់លិខិតអនុញ្ញាតសាងសង់នោះនៅមានការខ្វះខាត ឬខុសឆ្គង មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ឬអគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម រួមទាំងអគ្គនាយកដ្ឋានសំណង់ត្រូវធ្វើសេចក្តីជូនដំណឹងជាលាយលក្ខអក្សរដល់ម្ចាស់សំណើរឱ្យបំពេញបន្ថែម ឬកែសម្រួលដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលាខេត្តក្រុងជាអ្នកសម្រេច។ ចំណែកឯរយៈពេលគិតសារជាថ្មីនៃការបំពេញបន្ថែម ឬការកែតម្រូវនេះត្រូវគិតចាប់ពីថ្ងៃដែលម្ចាស់សំណង់បានដាក់ពាក្យសុំផ្តល់លិខិតអនុញ្ញាតសាងសង់ឡើងវិញ។ ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចណាមួយ ធ្វើឱ្យការដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់មានការអូសបន្លាយពេលវេលាលើសពីការកំណត់ ហើយមិនបានបង្ហាញនូវមូលហេតុណាមួយច្បាស់លាស់ និងមិនសមស្របទេ មន្ត្រីពាក់ព័ន្ធត្រូវតែទទួលខុសត្រូវចំពោះម្ចាស់សំណើ និងចំពោះមុខច្បាប់ជាធរមាន។

### ១.៦.៤.ការផ្តល់លិខិតអនុញ្ញាតសាងសង់

ក្រោយពេលត្រួតពិនិត្យសំណុំឯកសារឃើញថា ត្រឹមត្រូវមន្ត្រីទទួលពាក្យត្រូវចេញបង្កាន់ដៃ ទទួលពាក្យសុំផ្តល់លិខិតអនុញ្ញាតសាងសង់ទៅម្ចាស់សំណើរ ហើយពេលវេលាទទួលបានលិខិតអនុញ្ញាតសាងសង់ ក៏បានចាប់ផ្តើមពីពេលនោះដែរ។ បន្ទាប់មកម្ចាស់សំណើរត្រូវប្រគល់លិខិតអនុញ្ញាតសាងសង់ គំរោងប្លង់ចំនួន ០១ច្បាប់ និងសំណុំឯកសារដទៃទៀតត្រូវតម្កល់ទុកនៅសាលាខេត្តក្រុង និងនៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តក្រុង។ ក្នុងករណីជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំនង់ក៏ត្រូវយកឯកសារចម្លងមួយច្បាប់មករក្សាទុកដែរ។ ម្ចាស់សំណើរក្រៅពីមានលិខិតអនុញ្ញាតសាងសង់ គឺត្រូវតែមានប្លង់លម្អិតគ្រឿងបង្កុំសំណង់ដើម្បីចាប់ផ្តើមដំណើរការការដ្ឋាន។

## ១.៧. សោហ៊ុយលើសេវា និងសុពលភាពនៃលិខិតអនុញ្ញាតសាងសង់

### ១.៧.១.សោហ៊ុយលើសេវា

សោហ៊ុយត្រូវបង្កើតឡើងចំពោះសេវាសំណង់ក្នុងការពិនិត្យ និងសម្រេចលើការសុំលិខិតអនុញ្ញាតសាងសង់។ ទាក់ទងនឹងតម្លៃលើសេវាមានពីរប្រភេទ គឺសំណង់លំនៅឋាន និងសំណង់អគារផ្សេងៗក្រៅពីលំនៅឋាន។ ចំណែកសោហ៊ុយលើសេវាត្រូវបានកំណត់ចែងក្នុងប្រកាសអន្តរក្រសួងលេខ ៣៦៥ សហវ.ប្រក ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០១៩ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

### ១.៧.២. សុពលភាពនៃលិខិតអនុញ្ញាតសាងសង់

លិខិតអនុញ្ញាតសាងសង់នឹងត្រូវអស់សុពលភាព ប្រសិនបើការសាងសង់មិនទាន់ដំណើរការក្នុងរយៈពេលមួយឆ្នាំដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាចេញលិខិតអនុញ្ញាតសាងសង់។ ប៉ុន្តែទោះជាយ៉ាងណាលិខិតនេះអាចពន្យារពេលបានមួយដង បើសិនមានករណីចាំបាច់ណាមួយដោយម្ចាស់សំណង់អាចដាក់ពាក្យស្នើសុំពន្យារពេលដល់អាជ្ញាធរមានសមត្ថកិច្ច។ កាលណាការងារសាងសង់ត្រូវបានផ្អាកលើសពីមួយឆ្នាំ អាជ្ញាធរមានសមត្ថកិច្ចអាចបង្ខំឱ្យបញ្ចប់ការសាងសង់ឬបង្ខំឱ្យរុះរើសំណង់ដែលបានចាប់ផ្តើម ហើយរៀបចំទីកន្លែងឱ្យបានត្រឹមត្រូវដូចដើមវិញក្នុងរយៈពេលមួយដែលបានកំណត់ ដោយសោហ៊ុយចាការចំណាយរបស់ម្ចាស់លិខិតអនុញ្ញាតសាងសង់។

# ជំពូកទី២
# ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាព
# សំណាច់

# ជំពូកទី២៖ ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់

ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ គឺសំដៅដល់ការត្រួតពិនិត្យសំណង់ឱ្យបានត្រឹមត្រូវ តាមបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសសំណង់ ដូចជាការវិភាគ ការបញ្ជាក់លើគម្រោងប្លង់ ការគណនា សេចក្តីណែនាំបច្ចេកទេសសម្រាប់ការងារសាងសង់ ឬរុះរើ និងប្រតិបត្តិការងារសាងសង់ឬរុះរើ និងបទប្បញ្ញត្តិ ជាធរមានដទៃទៀត ដើម្បីធានាសុវត្ថិភាព សុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់និង សាធារណជន និងធានាគណនេយ្យភាព និងប្រសិទ្ធភាពក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យសាងសង់។ ក្រៅពីនេះ ការត្រួតពិនិត្យសំណង់ ក៏បានរួមចំណែកនៅក្នុងការគ្រប់គ្រងសំណង់ ដើម្បីរក្សាសណ្តាប់ធ្នាប់ និងសោភ័ណ្ឌភាព ទីក្រុងផងដែរ។

ទន្ទឹមនឹងនេះ ដើម្បីជំរុញឲ្យការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់កាន់តែមានប្រសិទ្ធភាព ជាការពិតណាស់គឺត្រូវមានការចូលរួមជាចាំបាច់ពីអាជ្ញាធរដែលមានសមត្ថកិច្ច ដោយពួកគាត់ជាអ្នកដែលមាន សិទ្ធិអំណាចក្នុងការបញ្ជាក់ និងវាយតម្លៃនូវរាល់សំណង់ទាំងអស់ពីភាពត្រឹមត្រូវទៅតាមបទដ្ឋានគតិយុត្ត និង បទដ្ឋានបច្ចេកទេសសំណង់។ ដូចនេះ នៅក្នុងជំពូកទី២នេះ យើងនឹងធ្វើការសិក្សាទៅលើបញ្ហាមួយចំនួនដូចជា តើអាជ្ញាធរដែលពាក់ព័ន្ធណាខ្លះដែលមានសមត្ថកិច្ចនៅក្នុងការត្រួតពិនិត្យសំណង់? និងដំណើរការនៃការត្រួត ពិនិត្យសំណង់ គេត្រូវត្រួតពិនិត្យទៅលើផ្នែកណាខ្លះ?

## ២.១ អាជ្ញាធរមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់

អាជ្ញាធរមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ ជាមន្ត្រីត្រួតពិនិត្យសំណង់ ដែលសំដៅដល់មន្ត្រីជំនាញដែលត្រូវបានចាត់តាំងដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចុះត្រួតពិនិត្យការងារ សាងសង់ឬរុះរើ និងត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់។ មន្ត្រីត្រួតពិនិត្យសំណង់មាន មន្ត្រីជំនាញនៃអគ្គ នាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ។[23]

នៅក្នុងនោះដើម្បីធានាឲ្យបាននូវការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ឲ្យបាននៅក្នុងប្រទេស និងដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ បានចេញសេចក្តីសម្រេច ស្តីពីការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ជា០២អង្គភាព ពោលរួមមាន៖

- អង្គភាពថ្នាក់ជាតិ សំដៅដល់មន្ត្រីត្រួតពិនិត្យសំណង់ទទួលបន្ទុករួម
- និងអង្គភាពថ្នាក់ក្រោមជាតិ សំដៅដល់មន្ត្រីត្រួតពិនិត្យសំណង់រាជធានី ខេត្ត។[24]

[23] សេចក្តីណែនាំស្តីពីការពង្រឹងគុណភាពសុវត្ថិភាពសំណង់ លេខ០០២ ដនស/សណន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

[24] សេចក្តីសម្រេចស្តីពីការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់លេខ ០០៥ សសរ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០

## ២.១.១ អាជ្ញាធរថ្នាក់ជាតិ

### ២.១.១.១ សមាសភាព

សមាសភាពរបស់មន្ត្រីត្រួតពិនិត្យសំណង់ទទួលបន្ទុករួម ដែលត្រូវបានចាត់តាំងតាមសេចក្តីសម្រេចស្តីពីការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ មានសមាជិកចំនួន១៧រូប រួមមានៈ

- ប្រធាន ០១រូប
- អនុប្រធាន ០២រូប
- អគ្គនាយកសំណង់ ០១រូបជាសមាជិកអចិន្ត្រៃយ៍
- អគ្គនាយករដ្ឋបាល ០១រូបជាសមាជិក
- អគ្គនាយករៀបចំដែនដី និងនគរូបនីយកម្ម ០១រូបជាសមាជិក
- អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ ០១រូបជាសមាជិក
- អគ្គនាយកលំនៅឋាន ០១រូបជាសមាជិក
- អគ្គាធិការរង នៃអគ្គាធិការដ្ឋាន ០១រូបជាសមាជិក
- ប្រធាននាយកដ្ឋាននីតិកម្ម ០១រូបជាសមាជិក
- និងសមាជិក ០៧រូបផ្សេងទៀត។[25]

### ២.១.១.២ តួនាទីនិងភារកិច្ច

មន្ត្រីត្រួតពិនិត្យសំណង់ទទួលបន្ទុករួមៈ

- ដឹកនាំកំណត់ទិសដៅអនុវត្តដល់មន្ត្រីសំណង់រាជធានី ខេត្ត បន្ទាប់ពីទទួលបានគោលការណ៍ពីថ្នាក់ដឹកនាំក្រសួង
- តាមដាន និងត្រួតពិនិត្យការអនុវត្តការងាររបស់មន្ត្រីត្រួតពិនិត្យសំណង់រាជធានី ខេត្ត
- ធ្វើរបាយការណ៍គោរពស្នើសុំការត្រួតពិនិត្យ និងសម្រេចពីថ្នាក់ដឹកនាំក្រសួងលើការផ្អាក ការកែតម្រូវ ការបញ្ឈប់ ការតម្រូវឲ្យរុះរើ និងចាត់វិធានការចាំបាច់ផ្សេងទៀត ក្នុងករណីការងារសាងសង់ ឬរុះរើ មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំក្រសួង
- បំពេញការងារផ្សេងទៀតដែលក្រសួងប្រគល់ជូន។[26]

[25] ប្រការ១ នៃសេចក្តីសម្រេចស្តីពីការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ លេខ០០៥ សសរ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០

[26] ប្រការ២ នៃសេចក្តីសម្រេចស្តីពីការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ លេខ០០៥ សសរ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០

### ២.១.២ អាជ្ញាធរថ្នាក់ក្រោមជាតិ

មន្ត្រីត្រួតពិនិត្យសំណង់រាជធានី-ខេត្ត ដែលជាអាជ្ញាធរថ្នាក់ក្រោមជាតិត្រូវបានបែងចែកជា ០៩តំបន់ ដែលក្នុងតំបន់នីមួយៗអាចមានមួ០១ខេត្ត ០៣ខេត្ត ឬ០៤ខេត្តទៅតាមតំបន់ដែលមានដូចជា៖

- ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ
- ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង
- រាជធានីភ្នំពេញ
- ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ
- ខេត្តព្រះសីហនុ
- ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តប៉ៃលិន
- ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី
- ខេត្តតាកែវ ខេត្តកែប ខេត្តកំពត និងខេត្តកោះកុង
- ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តកំពង់ស្ពឺ។[27]

#### ២.១.២.១ សមាសភាព

**ក. ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ**

មន្ត្រីត្រួតពិនិត្យសំណង់នៅក្នុងតំបន់នេះមានសមាជិកសរុបចំនួន ១៧សមាជិករួមមាន៖

- ប្រធាន ០១រូប
- អនុប្រធាន ០២រូប
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ ជាសមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកគោលដៅ ជាលេខាធិការ
- និងសមាជិក ១២រូបផ្សេងទៀត។

**ខ. ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង**

- ប្រធាន ០១រូប
- អនុប្រធាន ០២រូប
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ ជាសមាជិកអចិន្ត្រៃយ៍

[27] ប្រការ១ នៃសេចក្តីសម្រេចស្តីពីការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ លេខ០០៥ សសរ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០

- ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកគោលដៅ ជាលេខាធិការ
- និងសមាជិក ១២រូបផ្សេងទៀត។

**គ. រាជធានីភ្នំពេញ**

- ប្រធាន ០១រូប
- អនុប្រធាន ០២រូប
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ ជាសមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលខណ្ឌគោលដៅ ជាលេខាធិការ
- និងសមាជិក ១៨រូបផ្សេងទៀត។

**ឃ. ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ**

- ប្រធាន ០១រូប
- អនុប្រធាន ០២រូប
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ ជាសមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកគោលដៅ ជាលេខាធិការ
- និងសមាជិក ១០រូបផ្សេងទៀត។

**ង. ខេត្តព្រះសីហនុ**

- ប្រធាន ០១រូប
- អនុប្រធាន ០២រូប
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ ជាសមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកគោលដៅ ជាលេខាធិការ

និងសមាជិក ១៤រូបផ្សេងទៀត។

**ច. ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តប៉ៃលិន**

- ប្រធាន ០១រូប
- អនុប្រធាន ០២រូប

- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ ជាសមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកគោលដៅ ជាលេខាធិការ
- និងសមាជិក ១១រូបផ្សេងទៀត។

**ឆ. ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី**

- ប្រធាន ០១រូប
- អនុប្រធាន ០២រូប
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ ជាសមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកគោលដៅ ជាលេខាធិការ
- និងសមាជិក ១១រូបផ្សេងទៀត។

**ជ. ខេត្តតាកែវ ខេត្តកែប ខេត្តកំពត និងខេត្តកោះកុង**

- ប្រធាន ០១រូប
- អនុប្រធាន ០២រូប
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ ជាសមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកគោលដៅ ជាលេខាធិការ
- និងសមាជិក ១២រូបផ្សេងទៀត។

**ឈ. ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តកំពង់ស្ពឺ**

- ប្រធាន ០១រូប
- អនុប្រធាន ០២រូប
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ ជាសមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកគោលដៅ ជាលេខាធិការ

និងសមាជិក ១០រូបផ្សេងទៀត។

### ២.១.២.២ តួនាទី និងភារកិច្ច

- ពិនិត្យ និងផ្តល់យោបល់ទាំងលើទិដ្ឋភាពច្បាប់និងបច្ចេកទេសលើគម្រោងសាងសង់ និងតាមដានត្រួតពិនិត្យការសាងសង់
- ចុះត្រួតពិនិត្យ និងបោះបង្គោលព្រំកំណត់ទីតាំងស្នើសុំសាងសង់ ឬរុះរើ
- ចុះត្រួតពិនិត្យការងារសាងសង់ ឬរុះរើ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការចុះត្រួតពិនិត្យជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេចលើការផ្អាក ការកែតម្រូវ ការបញ្ឈប់ ការតម្រូវឲ្យរុះរើ ចាត់វិធានការចាំបាច់ផ្សេងទៀត ឬលើកសំណើសុំធ្វើអធិការកិច្ចសំណង់ ក្នុងករណីរកឃើញថាការងារសាងសង់ ពង្រីក ឬរុះរើ មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញតិជាធរមានដទៃទៀត
- សហការជាមួយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គោលដៅ ដើម្បីចុះតាមដាន និងត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិនីគរូបនីយកម្មចំពោះគម្រោងសាងសង់រហូតដល់បញ្ចប់ការដ្ឋាន
- ប្រមូលនិងចងក្រងទិន្នន័យ និងធ្វើរបាយការណ៍តាមការដ្ឋាននីមួយៗ ដែលបានចុះត្រួតពិនិត្យបោះបង្គោលព្រំកំណត់ទីតាំងស្នើសុំសាងសង់ ឬរុះរើ។
- បំពេញការងារផ្សេងទៀតដែលក្រសួងប្រគល់ជូន។
- មន្ត្រីត្រួតពិនិត្យសំណង់នេះអាចប្រើប្រាស់មន្ត្រីក្រោមឱវាទ ឲ្យជួយបំពេញភារកិច្ចតាមការចាំបាច់។[28]

## ២.២ ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់

ដើម្បីធានាសន្តិសុខ សុវត្ថិភាពក្នុងការដ្ឋានសំណង់ សុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន តាមបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសសំណង់ អាជ្ញាធរមានសមត្ថកិច្ចត្រូវយកចិត្តទុកដាក់ អនុវត្តគោលការណ៍ និងវិធានការទៅលើ លិខិតអនុញ្ញាតសាងសង់ ឬជួសជុល ឬរុះរើ លិខិតអនុញ្ញាតបើកការដ្ឋាន ការរៀបចំការដ្ឋាន ដំណើរការការដ្ឋានសំណង់ និងការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់។

### ២.២.១. ការចុះត្រួតពិនិត្យទីតាំងស្នើសុំលិខិតអនុញ្ញាតសាងសង់

បន្ទាប់ពីទទួលបានលិខិតរបស់ប្រធានមន្ត្រីត្រួតពិនិត្យសំណង់ទទួលបន្ទុករួម ជូនទៅប្រធានក្រុមមន្ត្រីត្រួតពិនិត្យសំណង់រាជធានី ខេត្តគោលដៅ ប្រធានក្រុមមន្ត្រីត្រួតពិនិត្យពិនិត្យតាមគោលដៅនោះ ត្រូវចាត់មន្ត្រីនៅក្នុងក្រុមរបស់ខ្លួនចុះទៅពិនិត្យទីតាំងស្នើសុំសាងសង់ ឱ្យបានទាន់ពេលវេលាដោយមិនលើសពីរយៈពេល ១៥ថ្ងៃ។ ចំពោះមន្ត្រីត្រួតពិនិត្យសំណង់ ដែលត្រូវចុះពិនិត្យទីតាំងស្នើសុំសាងសង់ ត្រូវផ្តល់ព័ត៌មានជាមុនទៅ

[28] ប្រការ៣ នៃសេចក្តីសម្រេចស្តីពីការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់លេខ០០៥ សសរ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល គោលដៅ ម្ចាស់សំណង់ ឬអ្នកតំណាង អំពីកាលបរិច្ឆេទចុះត្រួតពិនិត្យ។

នៅក្នុងការចុះត្រួតពិនិត្យទីតាំងស្នើសុំសាងសង់ មន្ត្រីត្រួតពិនិត្យសំណង់ត្រូវធ្វើកំណត់ហេតុស្តីពីការចុះត្រួតពិនិត្យ ដែលបង្ហាញអំពីព័តមានពាក់ព័ន្ធអំពីទីតាំងស្នើសុំ ជាទីតាំងមានគម្រោងសាងសង់ ឬជាទីតាំងដែលមានសំណង់កំពុងដំណើរការសាងសង់។

**២.២.១.១ ទីតាំងដែលមានគម្រោងសាងសង់**

ក្រោយពេលដែលម្ចាស់សំណង់ធ្វើការដាក់សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់រួចនោះ មន្ត្រីត្រួតពិនិត្យសំណង់នឹងធ្វើការពិនិត្យទៅលើ៖ ព័ត៌មានគម្រោងសាងសង់ និងកិច្ចសន្យាហ៊ុំព័ទ្ធ។

**ក. ព័ត៌មានគម្រោងប្លង់**

នៅក្នុងព័ត៌មានគម្រោងប្លង់ត្រូវមានបញ្ជាក់អំពី៖

- អំពីគម្រោង៖ មានឈ្មោះគម្រោង មុខងារប្រើប្រាស់នៃសំណង់ ប្រភេទនៃអគារ និងទីតាំង។
- អំពីម្ចាស់គម្រោង៖ ឈ្មោះម្ចាស់កម្មសិទ្ធិអចលនវត្ថុ អ្នកជួលដី(ប្រសិនបើមាន) ឈ្មោះម្ចាស់សំណង់ កាលបរិច្ឆេទនៃការចាប់ផ្តើមសាងសង់និងបញ្ចប់គម្រោងសសាងសង់។
- អំពីការសិក្សាគម្រោងប្លង់៖ ប្លង់ស្ថាបត្យកម្ម ឈ្មោះក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាប័ណ្ណ ឈ្មោះរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ដែលបានចុះបញ្ជី។

**ខ. កិច្ចសន្យាហ៊ុំព័ទ្ធ**

កិច្ចសន្យាហ៊ុំព័ទ្ធជាកិច្ចសន្យា ដែលម្ចាស់សំណង់ធ្វើជូនអាជ្ញាធរ អំពីការដាក់សម្ភារៈសាងសង់នៅលើទីតាំងនៃអចលនវត្ថុណាមួយដូចខាងក្រោម៖

- ធ្វើរបងហ៊ុំព័ទ្ធការដ្ឋានសំណង់ ដាក់សម្ភារៈ និងធ្វើរបាំងឲ្យបានម៉ត់ចត់ពីក្រោមដល់លើដើម្បីរក្សាការពារគ្រោះថ្នាក់ផ្សេងៗ។
- រក្សាទុកចិញ្ចើមថ្នល់ឱ្យបានទូលាយ ស្មើនឹងពីរភាគបី សំរាប់ឱ្យថ្មើរជើងធ្វើដំណើរទៅមកដោយសេរី។
- មិនយកទ្រូងថ្នល់ធ្វើជាកន្លែងលាយស៊ីម៉ង់ត៍ ចាក់សំរាម កំទេចកំទីសម្ភារៈសំណង់ និងចាក់ថ្មគ្រួស ខ្សាច់ ធ្វើឱ្យប៉ះពាល់ដល់អនាម័យសណ្តាប់ធ្នាប់ដាច់ខាត។
- មិនបង្កទំនាស់ មិនរំខានអ្នកជិតខាងជាប់ដីឡូត៍គ្នា។

**២.២.១.២ សំណង់ដែលកំពុងដំណើរការសាងសង់**

នៅក្នុងករណីនេះ មន្ត្រីត្រួតពិនិត្យសំណង់នឹងធ្វើការពិនិត្យបន្ថែមអំពីលក្ខខណ្ឌបច្ចេកទេសចាំបាច់មួយចំនួនដូចជា ក្រៅពីការពិនិត្យទៅលើសំណុំឯកសារខាងលើ មានដូចជា៖

➢ លក្ខណៈបច្ចេកទេសនៃសំណង់
➢ លក្ខណៈនគរូបនីយប្បញ្ញត្តិ
➢ ការរៀបចំសុវត្ថិភាព និងសណ្តាប់ធ្នាប់ការដ្ឋាន

**ក. លក្ខណៈបច្ចេកទេសសំណង់**

នៅក្នុងលក្ខណៈនៃបច្ចេកទេសសំណង់ សំដៅដល់សំណង់ទាំងអស់ត្រូវតែមាននូវៈ

➢ គ្រឿងផ្គុំដែលអាចទ្រាល់បន្ទុកបានប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់របស់សំណង់។[29]
➢ រាល់សំណង់ត្រូវអនុលោមទៅតាមបទប្បញ្ញត្តិសុវត្ថិភាពអគ្គីភ័យ។[30]

ការត្រួតពិនិត្យអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ត្រូវអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាប័ណ្ណ ឬការអនុញ្ញាតផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[31]

**ខ. លក្ខណៈនគរូបនីយប្បញ្ញត្តិ**

ការត្រួតពិនិត្យសំណង់ទៅលើលក្ខណៈនគរូបនីយប្បញ្ញត្តិ មន្ត្រីត្រួតពិនិត្យសំណង់នឹងធ្វើការត្រួតពិនិត្យទៅលើប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ការសាងសង់ដែលប៉ះពាល់ដល់ខាងផ្នែកបុរាណវិទ្យា និងទីធ្លាដែលហាមឃាត់មិនឱ្យសាងសង់។

❖ ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវតែបញ្ជាក់ឱ្យច្បាស់អំពីតំបន់ដែលត្រូវប្រើប្រាស់ សំរាប់ការពារជាតិ សំរាប់កសិកម្ម សំរាប់ពាណិជ្ជកម្ម សំរាប់ឧស្សាហកម្ម សំរាប់សិប្បកម្ម សំរាប់វប្បធម៌ សំរាប់ទេសចរណ៍ សំរាប់សាសនា ព្រមទាំងសំរាប់សំណង់នៃរដ្ឋបាលនិងបរិក្ខាសាធារណៈ។ ប្លង់នេះត្រូវតែគោរពទៅតាមប្លង់គោល និងកំណត់ផងដែរនូវលទ្ធភាពសំរាប់សាងសង់។[32]
❖ រាល់ការសាងសង់ទាំងឡាយដែលមានការកកាយរុករក ឬការស្ទង់ដែលមានការប៉ះពាល់ដល់ខាងផ្នែកបុរាណវិទ្យា ចាំបាច់ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល។ រាល់ការសាងសង់ ក្នុងករណីជួបប្រទះនូវវត្ថុអ្វីមួយដែលមានអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ឬប្រវត្តិសាស្ត្រ អ្នកទទួលខុសត្រូវការដ្ឋានត្រូវមានកាតព្វកិច្ចរាយការណ៍មកអាជ្ញាធរមានសមត្ថកិច្ចឱ្យបានជ្រាបភ្លាមៗ។ អាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្អាកសំណង់ជាបន្ទាន់។[33]

---

[29] មាត្រា៨ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩
[30] មាត្រា៩ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩
[31] មាត្រា៧ នៃច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩
[32] មាត្រា៦ នៃច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤
[33] មាត្រា១១ នៃច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤

❖ រាល់បុគ្គល ឬស្ថាប័នឯកជនក៏ដូចជាអាជ្ញាធរសាធារណៈ ត្រូវហាមឃាត់មិនឱ្យសាងសង់លើទីធ្លាដែលមានលក្ខណៈជាសាធារណៈដូចតទៅ៖

- ទីបំរុងទុកទឹក និងទំនប់ទឹក
- ទំបំរុងជីកដី និងតំបន់ព្រៃឈើ
- រមណីយដ្ឋានបុរាណវិទ្យា និងប្រវត្តិសាស្ត្រ
- សួនច្បារ ឧទ្យានសាធារណៈនិងតំបន់អភិរឌ្ឍន៍
- ដីបំរុងទុកសំរាប់ផ្លូវ បំរុងសំរាប់ចំណីផ្លូវ និងដីបំរុងទុកសំរាប់ផ្លូវរថភ្លើង និងអាកាសយានដ្ឋាន
- ទន្លេ សមុទ្រ ព្រែក ស្ទឹងព្រមទាំងឆ្នេរច្រាំង
- ជាទុទៅនៅលើដីទាំងឡាយណាដែលបញ្ញត្តិច្បាប់កំណត់មិនឱ្យសង់។

លក្ខខណ្ឌនៃការគ្រប់គ្រងតំបន់ទាំងនោះ លក្ខខណ្ឌសំណង់ ឬតាំងទីលំនៅធុនស្រាល បណ្ដោះអាសន្នអនុញ្ញាតបានដោយអនុក្រឹត្យ។[34]

**គ. ការរៀបចំសុវត្ថិភាព និងសណ្ដាប់ធ្នាប់ការដ្ឋាន**

ការរៀបចំសុវត្ថិភាព និងសណ្ដាប់ធ្នាប់ការដ្ឋាន មន្ត្រីត្រួតពិនិត្យសំណង់នឹងធ្វើការពិនិត្យទៅលើ៖

- វិស្វករប្រចាំការដ្ឋាន (បានចុះកិច្ចសន្យាជាមួយម្ចាស់សំណើ ឬត្រូវចាត់តាំងដោយក្រុមហ៊ុនសាងសង់)
- អាងប្រព្រឹត្តកម្មទឹកកខ្វក់
- ម៉ាស៊ីនចម្រោះទឹកកខ្វក់
- សំណាញ់ការពារសុវត្ថិភាព
- ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ
- ប្រព័ន្ធលូទឹកកខ្វក់
- ប៉ាណូការដ្ឋានសំណង់
- សញ្ញា និងភ្លើងបំភ្លឺការដ្ឋាន។

បន្ទាប់ពីបានចុះត្រួតពិនិត្យទីតាំងរួច មន្ត្រីត្រួតពិនិត្យសំណង់ត្រូវធ្វើរបាយការណ៍អំពីលទ្ធផល នៃការចុះត្រួតពិនិត្យ ដោយភ្ជាប់មកជាមួយនូវកំណត់ហេតុចុះត្រួតពិនិត្យនិងរូបភាពទីតាំងជាក់ស្ដែង។ ចំពោះយោបល់នៅក្នុងរបាយការណ៍នេះក្រុមមន្ត្រីត្រួតពិនិត្យសំណង់អាចជូនយោបល់ ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេចលើការអនុញ្ញាតចេញលិខិតអនុញ្ញាតសាងសង់ ឬផ្អាក ការកែតម្រូវ ការបញ្ឈប់ ការតម្រូវឱ្យរុះរើ ចាត់វិធានការ

[34] មាត្រា១២ នៃច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤

ផ្សេងទៀត ឬលើកសំណើសុំធ្វើអធិការកិច្ចសំណង់ក្នុងករណីពិនិត្យឃើញថា ការងារសាងសង់មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត។

### ២.២.២ ការត្រួតពិនិត្យក្នុងពេលសាងសង់

នៅក្នុងពេលដំណើរការនៃការចាប់ផ្ដើមសាងសង់ ឬក្នុងអំឡុងពេលសាងសង់នៃការសាងសង់ មន្ត្រីត្រួតពិនិត្យធ្វើការពិនិត្យទៅលើលិខិតអនុញ្ញាត ការរៀបចំការដ្ឋាន និងដំណើរការនៃការដ្ឋាន។

#### ២.២.២.១ លិខិតអនុញ្ញាត

រាល់សំណង់ដែលសាងសង់ទាំងអស់ត្រូវតែមាននូវលិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតបើកការដ្ឋានជាមុន ទើបអាចដំណើរការបើកការដ្ឋានបាន។

**ក. លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ**

មន្ត្រីត្រួតពិនិត្យសំណង់នឹងធ្វើការសួររក និងពិនិត្យលើលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើពីម្ចាស់សំណង់ដើម្បីបញ្ជាក់ពីភាពស្របច្បាប់នៃសំណង់ និងដើម្បីពង្រឹងគុណភាព និងសុវត្ថិភាពសំណង់ដោយពិនិត្យទៅលើគម្រោងប្លង់ដែលមាននៅក្នុងលិខិតអនុញ្ញាតទាំងនោះ។

- គម្រោងប្លង់ស្ថាបត្យកម្មត្រូវសិក្សា និងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកប្រកបវិជ្ជាជីវៈជាស្ថាបត្យកម្ម និងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រផ្ដល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- នៅក្នុងករណីគម្រោងប្លង់រុះរើ ត្រូវសិក្សានិងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬត្រូវមានហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាវិស្វករ និងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រផ្ដល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[35]

**ខ. លិខិតអនុញ្ញាតបើកការដ្ឋាន**

លិខិតអនុញ្ញាតបើកដ្ឋាន គឺជាលិខិតដែលចេញដោយក្រសួងនគរូបនីយកម្ម និងសំណង់ ឬសាលារាជធានី-ខេត្ត តាមការស្នើសុំបន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ ទៅអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត។[36] ក្នុងការស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាន ត្រូវមានភ្ជាប់សំណុំឯកសារមួយចំនួនដូចជា៖

[35] ចំណុចទី១ នៃសេចក្ដីណែនាំលេខ០០២ ដនស/សណន ស្ដីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់

[36] ប្រការ៣(ថ្មី) នៃប្រកាសស្ដីពីការកែសំរួលប្រការ២ និងប្រការ៣ នៃប្រកាសលេខ៣២ប្រក/សណស្ដីពីការគ្រប់គ្រងការដ្ឋានសំណង់

- សំណុំឯកសារពាក្យសុំរបស់ម្ចាស់សំណង់។
- លិខិតអនុញ្ញាតសាងសង់។
- ប្លង់ស្ថាបត្យកម្មដែលបានអនុញ្ញាត។
- ប្លង់គ្រឿងផ្គុំសំណង់។[37]

ក្រោយពេលមន្ត្រីត្រួតពិនិត្យសំណង់ត្រួតពីនិត្យលើលិខិតអនុញ្ញាតសាងសង់រួចហើយ មន្ត្រីត្រួតពិនិត្យសំណង់ត្រូវត្រួតពិនិត្យទៅលើលិខិតអនុញ្ញាតបើកការដ្ឋាន ពីព្រោះការដ្ឋាននីមួយ អាចដំណើរការបានលុះត្រាតែមានលិខិតអនុញ្ញាតបើកការដ្ឋាន។ ពាក់ព័ន្ធជាមួយនឹងការត្រួតពិនិត្យទៅលើលិខិតអនុញ្ញាតបើកការដ្ឋាន មន្ត្រីត្រួតពិនិត្យសំណង់នឹងធ្វើការស្នើសុំឲ្យម្ចាស់សំណង់ផ្តល់នូវលិខិតអនុញ្ញាតបើកការដ្ឋាន ដើម្បីបញ្ជាក់ថាម្ចាស់សំណង់បានគោរពទៅតាមបទដ្ឋានគតិយុត្តក្នុងការសាងសង់ ដោយពិតជាបានទទួលនូវលិខិតអនុញ្ញាតដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលាខេត្ត-ក្រុង ពិតប្រាកដមែនដែរឬទេ។

បន្ទាប់ពីមន្ត្រីត្រួតពិនិត្យសំណង់ពិនិត្យឃើញថា ម្ចាស់សំណង់ពិតជាទទួលបាននូវលិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតបើកការដ្ឋានមុននឹងធ្វើការសាងសង់ពិតប្រាកដហើយនោះ មន្ត្រីត្រួតពិនិត្យសំណង់នឹងធ្វើការត្រួតពិនិត្យបន្ថែមទៀតទៅលើលិខិតអនុញ្ញាតបើកការដ្ឋាន គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងគម្រោងប្លង់បច្ចេកទេស។

នៅក្នុងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ត្រូវមានការបញ្ជាក់អំពីអត្តសញ្ញាណរបស់អ្នកសាងសង់ វិស្វករប្រចាំការដ្ឋាន វិញ្ញាបនបត្រធានារ៉ាប់រងការទទួលខុសត្រូវការដ្ឋាន និងគម្រោងប្លង់រៀបចំការដ្ឋានសំណង់ដែលមានហត្ថលេខារបស់នាយកបច្ចេកទេស។[38]

គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀតត្រូវសិក្សា និងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាវិស្វករនិងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ ដែលមានអាជ្ញាប័ណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[39] គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀត ត្រូវមានការបញ្ជាក់អនុលោមភាពតាមបទដ្ឋានបច្ចេកទេសសំណង់ ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលទទួលស្គាល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[40]

---

[37] ប្រការ៣(ថ្មី) នៃប្រកាសស្តីពីការកែសំរួលប្រការ២ និងប្រការ៣ នៃប្រកាសលេខ៣២ប្រក/សណស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

[38] ចំណុចទី២ នៃសេចក្តីណែនាំលេខ០០២ ដនស/សណន ស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់

[39] ចំណុចទី២ នៃសេចក្តីណែនាំលេខ០០២ ដនស/សណន ស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់

[40] ចំណុចទី២ នៃសេចក្តីណែនាំលេខ០០២ ដនស/សណន ស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់

➢ ជាក់ស្តែង កាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បាន ចេញលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់លេខ០២៦ អសណ/នសណ អនុញ្ញាតជូនក្រុមហ៊ុន ម.ហ តំណាង ដោយលោក គ.ស.ហ ជាម្ចាស់សំណើស្នើសុំសងសង់ផ្ទះល្វែង ចំនួន៦៦៥ល្វែង ស្មើនឹង០៣ជាន់ ភូមិគ្រឹះ ចំនួន ១៨ខ្នង ស្មើនឹង០៤ជាន់ ដែលមានផ្ទៃសំណង់សរុប ១៧៧.៣៦៥,៨៦ម² នូវលិខិតអនុញ្ញាតបើកការដ្ឋានសាង សង់នៅលើដីឡូត៍មានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៩០៧០៨-០៨៩២ ផ្លូវលំ ភូមិវិមានទ្រង់ សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។[41]

ក្រោយការត្រួតពិនិត្យរបស់មន្ត្រីត្រួតពិនិត្យសំណង់ទៅលើលិខិតអនុញ្ញាតបើកការដ្ឋានរួចហើយ ពិនិត្យ ឃើញថាត្រឹមត្រូវទៅតាមលិខិតអនុញ្ញាតហើយនោះ មន្ត្រីត្រួតពិនិត្យសំណង់នឹងធ្វើការត្រួតពិនិត្យជាបន្ទាប់ទៅ ទៀតលើការរៀបចំការដ្ឋាន។

**២.២.២.២ ការរៀបចំការដ្ឋាន**

មន្ត្រីត្រួតពិនិត្យសំណង់ត្រូវចុះវាស់វែង និងបោះបង្គោលព្រំកំណត់ទីតាំងដែលត្រូវសាងសង់ស្របតាម គម្រោងប្លង់ស្ថាបត្យកម្មដែលទទួលបានការយល់ព្រមតាមរយៈលិខិតអនុញ្ញាតសាងសង់។[42]

ក្រៅពីការចុះវាស់វែង និងបោះបង្គោលព្រំកំណត់ទីតាំង មន្ត្រីត្រួតពិនិត្យសំណង់នឹងធ្វើការពិនិត្យទៅលើ ការរៀបចំការដ្ឋានសំណង់នីមួយៗ ដើម្បីបញ្ជាក់ថាការដ្ឋានសំណង់ដែលនឹងធ្វើការសាងសង់មានអនុលោមទៅ តាមបញ្ញត្តិដែលមានចែងក្នុងប្រកាសស្តីពីការគ្រប់គ្រងការដ្ឋាន និងសុវត្ថិភាពក្នុងការដ្ឋានសំណង់ដែរឬទេ។

នៅក្នុងការរៀបចំការដ្ឋានសំណង់នីមួយត្រូវៈ

- តម្កល់ជាប្រចាំ លិខិតបើកការដ្ឋាន គំនូរប្លង់តាមមុខជំនាញការងារសំណង់ ផែនការអនុវត្តការងារក្នុង ដំណាក់កាលនីមួយៗនៃការសាងសង់ និងឯកសារពាក់ព័ន្ធទុកសម្រាប់ភ្នាក់ងារសំណង់តាមដានត្រួត ពិនិត្យ។
- ដាក់ផ្ទាំងគំនូរសំណង់ ដែលមានឈ្មោះសំណង់ នៃអគារត្រូវសាងសង់ ក្រុមហ៊ុនសំណង់ ម្ចាស់សំណង់ ស្ថាបត្យករ វិស្វករ ផ្ទៃក្រឡាសំណង់ លេខទូរស័ព្ទទាក់ទង និងកន្លែងការដ្ឋានតាំងនៅ។
- មានភ្លើងដើម្បីបំភ្លឺ និងត្រូវមានប្រដាប់សម្រាប់ពន្លត់អគ្គីភ័យជាប្រចាំ។
- បន្ថយការរំខានដោយសូរសំលេង ផ្សែង ធូលី និងផលប៉ះពាល់ដទៃទៀត ឲ្យស្ថិតនៅក្នុងកំរិត និងពេល វេលាមួយដែលអ្នករស់នៅជុំវិញការដ្ឋានអាចទទួលបាន។[43]

[41] លិខិតអនុញ្ញាតបើកការដ្ឋានសាងសង់លេខ០២៦ អសណ/នសណ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦

[42] ចំណុចទី៣ នៃសេចក្តីណែនាំលេខ០០២ ដនស/សណន ស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់

[43] ប្រការ៤ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់លេខ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១

ដើម្បីធានានូវសុវត្ថិភាពក្នុងការសាងសង់ ការដ្ឋាននីមួយៗត្រូវហ៊ុមព័ទ្ធដោយរបងមានកម្ពស់ ២ម៉ែត្រយ៉ាងទាបបំផុត ហើយមិនអនុញ្ញាតឲ្យធ្វើលើចិញ្ចើមថ្នល់។ ក្នុងករណីទីតាំងការដ្ឋានចង្អៀត ការធ្វើរបងបិទបាំងបណ្តោះអាសន្នលើចិញ្ចើមថ្នល់សារធារណៈ ត្រូវរក្សាឲ្យមានចន្លោះផ្លូវដើរលើចិញ្ចើមថ្នល់ និងធ្វើរបាំងការពារតាមទំហំដែលអនុញ្ញាត ឬ កំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។ ចំពោះសំណង់ដែលមានកម្ពស់ចាប់ពី៥ម៉ែត្រឡើងទៅ ត្រូវហ៊ុមព័ទ្ធដោយក្រណាត់កៅស៊ូ ឬសំណាញ់សុវត្ថិភាព។[44]

- ជាក់ស្តែង យោងតាមសេចក្តីណែនាំបន្ថែមស្តីពីការរៀបចំការដ្ឋានសាងសង់សំណង់អគារគ្រប់ប្រភេទនៅខេត្តព្រះសីហនុ លេខ២២៥៥ ដនស/គដនជ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨ ដែលចេញដោយគណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្មថ្នាក់ជាតិ បានកំណត់រាល់ការដ្ឋានសាងសង់សំណង់អគារគ្រប់ប្រភេទនៅខេត្តព្រះសីហនុ ត្រូវៈធ្វើរបងហ៊ុំព័ទ្ធការដ្ឋានសំណង់កម្ពស់យ៉ាងតិច ២ (ពីរ) ម៉ែត្រ ពីនីវ៉ូ 0 (សូន្យ) នៃគម្រោងដែលក្នុងនេះត្រូវរៀបជើងរបងអំពីថ្មកម្ពស់យ៉ាងតិច ៨០ (ប៉ែតសិប) សង់ទីម៉ែត្រដើម្បីកុំឱ្យដី សំណល់រឹង និងរាវ ហៀរចេញពីការដ្ឋានទៅលើផ្លូវ ចិញ្ចើមផ្លូវ ដីចំណីឆ្នេរ ឆ្នេរសមុទ្រ សមុទ្រ ព្រែក អូរ បឹង និងទីតាំងសាធារណៈ ក្នុងគោលដៅធានាសុវត្ថិភាព សណ្តាប់ធ្នាប់ អនាម័យ និងបរិស្ថានសាធារណៈ។[45]

ការដ្ឋានត្រូវមានសណ្តាប់ធ្នាប់ និងអនាម័យ ជាប្រចាំង តាំងពីពេលចាប់ផ្តើមដំណើរការរហូតដល់ពេលបញ្ចប់ការដ្ឋាន។ ម្ចាស់សំណង់ជាអ្នកទទួលខុសត្រូវចំពោះការរៀបចំសណ្តាប់ធ្នាប់ និងអនាម័យដែលបណ្តាលមកពីការទុកដាក់សម្ភារៈ ឬកាកសំណល់ឲ្យប៉ះពាល់ផ្លូវសាធារណៈ ឬហូរធ្លាក់ចូលក្នុងអាងត្រួតពិនិត្យ នៃបណ្តាលូ និងប្រឡាយទឹក។[46]

ចំពោះសំណង់ដែលត្រូវប្រើគ្រឿងចក្របរិក្ខារលើកស្ទូច ហើយអាចធ្វើឲ្យប៉ះពាល់ដល់ការធ្វើដំណើរលើផ្លូវសាធារណៈ ម្ចាស់សំណង់ត្រូវៈ

- សុំការអនុញ្ញាតពីអាជ្ញាធរដែនដី ដើម្បីបិទផ្លូវសម្រាប់ការដំឡើងគ្រឿងផ្គុំសំណង់ ហើយធ្វើផ្លូវវាងជាបណ្តោះអាសន្ន
- បំពាក់ភ្លើងសញ្ញាសម្គាល់លើផ្លូវដែលបិទ ដើម្បីសុវត្ថិភាពនិងសណ្តាប់ធ្នាប់សាធារណៈនៅពេលយប់។[47]

[44] ប្រការ៥ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់លេខ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១

[45] សេចក្តីណែនាំបន្ថែមស្តីពីការរៀបចំការដ្ឋានសាងសង់សំណង់អគារគ្រប់ប្រភេទ នៅខេត្តព្រះសីហនុ លេខ២២៥៥ ដនស/គដនជ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨

[46] ប្រការ៦ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់លេខ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១

[47] ប្រការ៨ នៃប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់លេខ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១

ម្ចាស់សំណង់ និងអ្នកម៉ៅការសាងសង់ត្រូវបំពាក់ប្រដាប់ការពារសុវត្ថិភាព មានមួកសុវត្ថិភាព ស្រោមដៃ ស្បែកជើង ខ្សែក្រវ៉ាត់សុវត្ថិភាពសម្រាប់ឈរនៅទីខ្ពស់ និងឧបករណ៍ការពារដទៃទៀតដល់បុគ្គលិកកម្មករជាប្រចាំក្នុងការដ្ឋាន។

**២.២.២.៣ ដំណើរការដ្ឋានសំណង់**

ជាក់ស្តែងមានតែក្រុមហ៊ុនសាងសង់តែប៉ុណ្ណោះដែលមានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រដែលផ្តល់ឱ្យដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទើបអាចទទួលបានម៉ៅការសាងសង់បាន។ ក្រុមហ៊ុនសាងសង់អាចចុះកិច្ចសន្យាបន្តដើម្បីប្រគល់ការងារមួយផ្នែកឬច្រើនទៅឱ្យក្រុមជាងសំណង់។ ក្នុងករណីនេះ ក្រុមជាងសំណង់ត្រូវអនុវត្តការងារក្រោមការទទួលខុសត្រូវរបស់ក្រុមហ៊ុននោះ។ វិស្វករប្រចាំការដ្ឋានត្រូវចាត់តាំងដោយក្រុមហ៊ុនសាងសង់។

ក្រុមជាងដែលមានវិញ្ញាបនបត្រក្រុមជាងសំណង់ ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានីខេត្ត អាចទទួលម៉ៅការសាងសង់ស្ថិតក្រោមសមត្ថកិច្ចអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។ ការងាររបស់ក្រុមជាងសំណង់ត្រូវស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់វិស្វករប្រចាំការដ្ឋានយ៉ាងតិច០១ (មួយ) រូប ដែលមានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងដែលបានចុះកិច្ចសន្យាជាមួយម្ចាស់សំណង់។

គ្រប់ការដ្ឋានសំណង់ទាំងអស់ ត្រូវមានសៀវភៅតាមដានការងារសាងសង់ដើម្បីកត់ត្រាអំពីការងារសាងសង់ ឬរះរើជាប្រចាំ និងត្រូវដាក់ជូនមន្ត្រីត្រួតពិនិត្យសំណង់រាល់ពេលចុះត្រួតពិនិត្យ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់មន្ត្រីត្រួតពិនិត្យសំណង់ឲ្យចុះបំពេញការងារត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ជាប្រចាំ។ មន្ត្រីត្រួតពិនិត្យសំណង់មាន មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ។

ក្រុមហ៊ុនសាងសង់ ឬវិស្វករប្រចាំការដ្ឋាន ត្រូវជូនដំណឹងមកមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះពិនិត្យលើការងារសាងសង់តាមដំណាក់កាលដូចខាងក្រោម៖

- ក្នុងពេលកំណត់ទីតាំងសាងសង់
- ក្នុងពេលអនុវត្តការងារគ្រឹះ
- ក្នុងពេលអនុវត្តការងារសសរជាន់ផ្ទាល់ដី
- ក្នុងពេលអនុវត្តការងារគ្រឿងផ្គុំបន្តបន្ទាប់ទៀត។

នៅរាល់ពេលចុះត្រួតពិនិត្យការដ្ឋាន មន្ត្រីត្រួតពិនិត្យសំណង់ត្រូវចុះហត្ថលេខាលើសៀវភៅតាមដានការងារសាងសង់ និងធ្វើកំណត់ហេតុត្រួតពិនិត្យសំណង់ដោយមានហត្ថលេខារបស់មន្ត្រីត្រួតពិនិត្យសំណង់ និង

វិស្វករប្រចាំការដ្ឋាន និងស្នាមមេដៃរបស់ម្ចាស់សំណង់ និងអ្នកពាក់ព័ន្ធ។

ក្នុងករណីពិនិត្យឃើញថាការងារសាងសង់ឬវិធីមិនអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់គម្រោងប្លង់ស្ថាបត្យកម្មដែលបានអនុញ្ញាតហើយ និងបទប្បញ្ញត្តិជាធរមានដទៃទៀត អាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឱ្យវិធីឬវិធានការចាំបាច់ផ្សេងទៀត។

អគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវចងក្រងនិងរក្សារាល់កំណត់ហេតុ របាយការណ៍ត្រួតពិនិត្យសំណង់ រូបថត និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការដ្ឋានសំណង់នីមួយៗ ទាំងជាឯកសាររឹងនិងទាំងជាឯកសារអេឡិចត្រូនិក សម្រាប់ប្រើប្រាស់ក្នុងករណីចាំបាច់។ [48]

### ២.២.៣ ការត្រួតពិនិត្យពេលបញ្ចប់ការសាងសង់

ក្រោយបញ្ចប់ការដ្ឋានសាងសង់ ម្ចាស់សំណង់ត្រូវស្នើសុំលិខិតបិទការដ្ឋាន បន្ទាប់ពីបិទការដ្ឋានហើយ ម្ចាស់សំណង់ត្រូវស្នើបញ្ជាក់អំពីភាពត្រឹមត្រូវ។ នៅក្នុងការត្រួតពិនិត្យ និងបញ្ជាក់សំណង់ មន្ត្រីត្រួតពិនិត្យនឹងធ្វើការត្រួតពិនិត្យទៅលើ៖

- គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងការងារសាងសង់ ត្រូវមានការត្រួតពិនិត្យ និងបញ្ជាក់អនុលោមភាពតាមបទដ្ឋានបច្ចេកទេសសំណង់ ដែលអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ ដែលជាក្រុមហ៊ុនសិក្សាគម្រោង ប្លង់ ឬក្រុមហ៊ុនសាងសង់ដែលកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួង។
- ការត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់គ្រឿងផ្គុំសំណង់ ត្រូវអនុវត្តដាច់ខាតលើគម្រោងប្លង់ផ្នែកគ្រឹះ ជើងតាង សសរ ធ្នឹម កម្រាលខណ្ឌ និងជញ្ជាំងទ្រទម្ងន់។ ការត្រួតពិនិត្យនិងបញ្ជាក់លើការងារសាងសង់ ត្រូវអនុវត្តដាច់ខាតនៅតាមដំណាក់កាលសំខាន់ៗនៃការងារគ្រឿងផ្គុំជាអាទិ៍ ផ្នែកគ្រឹះ សសរ ធ្នឹម កម្រាលខណ្ឌ និងជញ្ជាំងទ្រទម្ងន់។ ការត្រួតពិនិត្យនិងបញ្ជាក់លើការងារសាងសង់ ត្រូវអនុវត្តដាច់ខាតនៅតាមដំណាក់កាល សំខាន់ៗនៃការងារគ្រឿងផ្គុំ ជាអាទិ៍ ផ្នែកគ្រឹះ សសរ ធ្នឹម កម្រាលខណ្ឌ និងជញ្ជាំងទ្រទម្ងន់។

វិញ្ញាបនបត្រត្រួតពិនិត្យនិងបញ្ជាក់សំណង់ចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ គឺជាឯកសារដែលអាជ្ញាធរមានសមត្ថកិច្ចសប្រើប្រាស់ក្នុងការសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលមានតម្លៃសម្រាប់ចូលប្រើប្រាស់ ការដាក់ជួល ការលក់ ឬការប្រតិបត្តិការពាណិជ្ជកម្មផ្សេងទៀតពាក់ព័ន្ធនឹងសំណង់៕

[48] ចំណុចទី៤ សេចក្តីណែនាំស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់លេខ០០២ ដនស/សណន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ការសិក្សាស្រាវជ្រាវ ស្វែងយល់ពីប្រធានបទស្តីពី ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ ខាងលើរួចមក ក្រុមយើងខ្ញុំសង្កេតឃើញថា ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ គឺជារឿងមួយដ៏ចាំបាច់បំផុតដែលអាជ្ញាធរត្រូវតែបំពេញឲ្យបានខ្ជាប់ខ្ជួន ជាពិសេសមន្ត្រីត្រួតពិនិត្យសំណង់ដែលទទួលបន្ទុក ដើម្បីធានាសុវត្ថិភាព សុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់និងសាធារណជន និងធានាគណនេយ្យភាព និងប្រសិទ្ធភាពក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យសាងសង់។

សរុបសេចក្តីមក រាល់ការសាងសង់ក្នុងទីក្រុង និងទីប្រជុំជន រាល់សំណង់ថ្មី ការសាងសង់ឡើងវិញជាថ្មី ការពង្រីក និងការសាងសង់បន្ថែមពីលើអគារដែលមានស្រាប់ ការប្តូរទ្រង់ទ្រាយអគារដែលមានស្រាប់ សុទ្ធតែតម្រូវឲ្យមានលិខិតអនុញ្ញាតសាងសង់ និងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យគុណភាពសំណង់ និងសុវត្ថិភាពសំណង់។នៅក្នុងដំណើរការនៃការត្រួតពិនិត្យ ដើម្បីជំរុញឲ្យការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់កាន់តែមានប្រសិទ្ធភាព គឺត្រូវមានការចូលរួមជាចាំបាច់ពីអាជ្ញាធរដែលមានសមត្ថកិច្ច ដោយពួកគាត់ជាអ្នកដែលមានសិទ្ធិអំណាចក្នុងការបញ្ជាក់ និងវាយតម្លៃនូវរាល់សំណង់ទាំងអស់ពីភាពត្រឹមត្រូវទៅតាមបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសសំណង់។ អាជ្ញាធរដែលមានសមត្ថកិច្ចនៅក្នុងការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់មានដូចជា មន្ត្រីទទួលបន្ទុករួម និងមន្ត្រីត្រួតពិនិត្យសំណង់រាជធានី ខេត្ត ត្រូវបានបែងចែកជា០៩តំបន់ ដែលក្នុងតំបន់នីមួយៗអាចមានមួ០១ខេត្ត ០៣ខេត្ត ឬ០៤ខេត្ត។ នៅក្នុងដំណើរការនៃការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ មន្ត្រីត្រួតពិនិត្យសំណង់នឹងធ្វើការត្រួតពិនិត្យទៅលើលិខិតអនុញ្ញាតសាងសង់ ជួសជុលឬរុះរើ លិខិតអនុញ្ញាតបើកការដ្ឋាន ការរៀបចំការដ្ឋាន ដំណើរការដ្ឋានសំណង់ ការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់។

ទន្ទឹមនឹងនេះដែរ ក៏មាននូវសំណង់មួយចំនួនដែលពុំចំណុំក្រោមលិខិតអនុញ្ញាតសាងសង់មានដូចជាសំណង់ជាលំនៅដ្ឋានប្រជាពលរដ្ឋដែលស្ថិតនៅទីជនបទ ឬតំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និងឆ្ងាយពីតំបន់រមណីដ្ឋានទេសចរណ៍ តំបន់បេតិកភ័ណ្ឌជាតិ តំបន់រក្សាទុកការអារដោយពុំគិតពីទំហំ ឬសម្ភារៈសំណង់ ការជួសជុល និងថែរក្សាទាំងឡាយដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ឬទិដ្ឋភាពសំណង់ លើកលែងតែការជួសជុលនោះអាចបណ្តាលឲ្យប៉ះពាល់ដល់អ្នកជិតខាង ទីសក្ការៈបូជា សាលាសំណាក់សាធារណៈ និងបណ្តាការរូសិល្បៈរបស់រដ្ឋសម្រាប់សេវាសាធារណៈ ដែលរដ្ឋជាម្ចាស់កិច្ចការ ដោយគ្រាន់តែជូនដំណឹងអំពីគំរោងសាងសង់ទៅអាជ្ញាធរមូលដ្ឋាន។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការបកស្រាយ និងសិក្សាយ៉ាងលម្អិតអំពី ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់រួចមក ក្រុមយើងខ្ញុំយល់ឃើញថា មន្ត្រីត្រួតពិនិត្យសំណង់បានធ្វើការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់បានយ៉ាងប្រសិទ្ធិភាព តួយ៉ាង ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់ បានចេញលិខិតផ្អាកការដ្ឋាន និងផ្អាកការសាងសង់សំណង់មួយចំនួន ដែលមិនបានគោរពទៅតាមបទប្បញ្ញត្តិសំណង់ និងការសាងសង់ដោយគ្មានលិខិតអនុញ្ញាតសាងសង់។ ក៏ប៉ុន្តែម្ចាស់សំណង់មួយចំនួន នៅតែមិនគោរពច្បាប់នៅឡើយដោយគិតតែពីផលប្រយោជន៍ផ្ទាល់ខ្លួនជាធំ ដោយធ្វើការសាងសង់មុនរួចទើបសុំលិខិតអនុញ្ញាតសាងសង់ជាក្រោយ និងមានម្ចាស់សំណង់មួយចំនួនទៀតដែលទទួលបានលិខិតផ្អាកការសាងសង់ពីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ដោយពិនិត្យឃើញថាជាសំណង់មិនស្របច្បាប់ដោយមិនគោរពទៅនឹងបទប្បញ្ញត្តិសំណង់ និងបច្ចេសទេសសំណង់យ៉ាងណាក៏ដោយក៏នៅតែបន្តការសាងសង់ដដែល។ ហេតុដូចនេះហើយទើបក្រុមយើងខ្ញុំមានជាសំណូមពរ ក៏ដូចជាអនុសាសន៍មួយចំនួនទៅកាន់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជូនចំពោះអ្នកអានះ

១. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតែតាមដាន និងយកចិត្តទុកដាក់បន្ថែមទៀតចំពោះ អាជ្ញាធរថ្នាក់ជាតិ និងជាពិសេសអាជ្ញាធរថ្នាក់ក្រោម ដោយសារអាជ្ញាធរថ្នាក់ក្រោមជាតិមានមូលដ្ឋានស្ថិតនៅជិតជាមួយម្ចាស់សំណង់ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចផ្ទាល់របស់ខ្លួន។

២. មន្ត្រីត្រួតពិនិត្យសំណង់ត្រូវតែធ្វើរបាយការណ៍ នៅរាល់ភាពល្មើសច្បាប់របស់ម្ចាស់សំណង់ មិនត្រូវធ្វើការបិទបាំង និងឃុបឃិតជាមួយនឹងម្ចាស់សំណង់ឡើយ។

៣. ផ្អាកការដ្ឋានទាំងឡាយណាដែលបានសាងសង់មុនលិខិតអនុញ្ញាតសាងសង់ឱ្យផ្អាកនៅសកម្មភាពជាបន្ទន់ ក្នុងករណីមិនទាន់ស្នើសុំលិខិតអនុញ្ញាត ត្រូវទៅស្នើសុំលិខិតអនុញ្ញាតសិនទើបសាងសង់បន្តបាន។

៤. បន្តផ្សព្វផ្សាយខ្លឹមសារអំពីច្បាប់សំណង់ ទៅដល់ម្ចាស់សំណង់ ក្រុមហ៊ុន សាងសង់ ក្រុមហ៊ុនសិក្សាគម្រោងប្លង់ វិស្វករ ស្ថាបត្យករឱ្យបានទូលំទូលាយ ដើម្បីកំណត់ថារាល់សំណង់បានសាងសង់រួច និងសាងសង់បន្ទាប់ត្រូវគោរពតាមបទប្បញ្ញត្តិបច្ចេកទេស និងប្រកបដោយគុណភាព។

៥. អាជ្ញាធរត្រូវតែធ្វើការផ្សព្វផ្សាយណែនាំដោយម្ចាស់សំណង់ វិស្វករ អ្នកប្រកបវិជ្ជាជីវៈសំណង់ និងប្រជាពលរដ្ឋ អំពីសុវត្ថិភាព និងគុណភាពសំណង់ ក៏ដូចជាអំពីហានិភ័យដែលបង្កឡើងពីការសាងសង់សំណង់ដែលខុសទៅនឹងបទប្បញ្ញត្តិបច្ចេកទេសសំណង់ផងដែលដើម្បីឲ្យពួកគេយល់ដឹងកាន់តែច្បាស់៕

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិ

- ច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៩៩៤
- ច្បាប់ស្តីពីសំណង់ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩
- អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ លេខ៨៦អនក្រ/បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧
- ប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់លេខ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១
- ប្រកាសស្តីពីការកែសំរួលប្រការ២ និងប្រការ៣ នៃប្រកាសលេខ៣២ ប្រក/សណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- សេចក្តីណែនាំបន្ថែមស្តីពីការរៀបចំការដ្ឋានសាងសង់សំណង់អគារគ្រប់ប្រភេទ នៅខេត្តព្រះសីហនុ លេខ២២៥៥ ដនស/គដនជ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៨
- សេចក្តីសម្រេចស្តីពីការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ លេខ០០៥ សសរ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០
- សេចក្តីណែនាំស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់ លេខ០០២ ដនស/សណន ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០
- លិខិតអនុញ្ញាតបើកការដ្ឋានសាងសង់លេខ០២៦ អសណ/នសណ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៦

## ខ.សៀវភៅ

- សៀវភៅ នីតិនគរូបនីយកម្មវិទ្យា, បណ្ឌិត អ៊ុន សកក្កដា ឆ្នាំសិក្សា២០១៩-២០២០។

# ឧបសម្ព័ន្ធ

# មាតិកាឧបសម្ព័ន្ធ


**១. ឧបសម្ព័ន្ធទម្រង់លិខិត**

ឧបសម្ព័ន្ធទី១៖ សំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់

ឧបសម្ព័ន្ធទី២៖ សំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន

ឧបសម្ព័ន្ធទី៣៖ សំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតបិទការដ្ឋាន ឬវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ

**២. ឧបសម្ព័ន្ធគតិយុត្តិ**

ឧបសម្ព័ន្ធទី១៖ ច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពីសំណង់

ឧបសម្ព័ន្ធទី៣៖ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់

ឧបសម្ព័ន្ធទី៤៖ ប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

ឧបសម្ព័ន្ធទី៥៖ ប្រកាសស្តីពីការកែសំរួលប្រការ២ និងប្រការ៣ នៃប្រកាសលេខ៣២ប្រក/សណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

ឧបសម្ព័ន្ធទី៦៖ ប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ឧបសម្ព័ន្ធទី៧៖សេចក្តីណែនាំបន្ថែមស្តីពីការរៀបចំការដ្ឋានសាងសង់សំណង់អគារគ្រប់ប្រភេទ នៅខេត្តព្រះសីហនុ

ឧបសម្ព័ន្ធទី៨៖ សេចក្តីសម្រេចស្តីពីការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់

ឧបសម្ព័ន្ធទី៩៖ សេចក្តីណែនាំស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់

# ឧបសម្ព័ន្ធទម្រង់លិខិត

# ឧបសម្ព័ន្ធទី១៖ សំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យសុំលិខិតអនុញ្ញាតសាងសង់**

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.......................................ភេទ...........អាយុ...........ឆ្នាំសញ្ជាតិ........................
មុខរបរ.......................................... អាស័យដ្ឋានស្នាក់នៅផ្ទះលេខ............ក្រុមទី................ភូមិ..........................
ឃុំ/សង្កាត់.........................................ក្រុង ស្រុក ខណ្ឌ............................ រាជធានី ខេត្ត.............................។

**គោរពជូន**

**លោក/លោកស្រីអភិបាលក្រុង ស្រុក ខណ្ឌ..............................**

**តាមរយៈ** : មេឃុំ/ចៅសង្កាត់.......................................................................................................

**កម្មវត្ថុ** : សំណើសុំ...............................................លើដីឡូត៍........................ផ្លូវលេខ........................
ឃុំ/សង្កាត់.......................ក្រុង ស្រុក ខណ្ឌ........................ រាជធានី ខេត្ត.................................។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំ សូមជម្រាបជូនលោក/លោកស្រីអភិបាលក្រុង ស្រុក ខណ្ឌ មេត្តាជ្រាបថា ខ្ញុំបាទ-នាងខ្ញុំ មានបំណង............................................លើដីឡូត៍...........................ផ្លូវលេខ.........
ឃុំ/សង្កាត់.........................ក្រុង ស្រុក ខណ្ឌ.................................. រាជធានី ខេត្ត.................................។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ សូមលោក/លោកស្រីអភិបាលក្រុង ស្រុក ខណ្ឌ មេត្តាពិនិត្យ និងអនុញ្ញាត ..................................................................................................................ដោយអនុគ្រោះ។

សូម លោក/លោកស្រី អភិបាល មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ ។

**សូមជូនភ្ជាប់មកជាមួយនូវ:**

- ច្បាប់ថតចំលងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចំនួន.................ច្បាប់
- ប្លង់ស្ថាបត្យកម្ម ចំនួន.................ច្បាប់
- សលាកប័ត្រដីឡូត៍ ចំនួន.................ច្បាប់
- កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន ចំនួន.................ច្បាប់
- កិច្ចសន្យាសាងសង់ជាប់ជញ្ជាំងអឡ្យសិទ្ធិ (ករណីការសាងសង់ជាប់ជញ្ជាំងអឡ្យសិទ្ធិជាមួយអ្នកជិតខាង) ចំនួន.................ច្បាប់
- រូបថតបង្ហាញទីតាំង ចំនួន.................សន្លឹក
- ច្បាប់ថតចំលងលិខិតបញ្ជាក់អត្តសញ្ញាណសាមីសំណើ ចំនួន.................ច្បាប់

ថ្ងៃ.... ខែ...... ឆ្នាំ....នព្វស័ក ព.ស.២៥៦...
.............ថ្ងៃទី.........ខែ.............ឆ្នាំ២០.......
**ស្នាមមេដៃស្តាំអ្នកស្នើសុំ**

លេខ:....................
បានឃើញ និង បញ្ជូនមក
លោក/លោកស្រី អភិបាលក្រុង ស្រុក ខណ្ឌ....................
"ដើម្បីពិនិត្យ និងសម្រេច ដោយក្តីអនុគ្រោះ"
ថ្ងៃ......... ខែ .... ឆ្នាំ ....នព្វស័ក ព.ស. ២០៥៦.....
............ថ្ងៃទី..........ខែ..........ឆ្នាំ២០.......
**មេឃុំ/ចៅសង្កាត់**.......................

# កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន

ខ្ញុំបាទ នាងខ្ញុំឈ្មោះ........................................ភេទ..............អាយុ..........ឆ្នាំ សញ្ជាតិ
........................ អាស័យដ្ឋានស្នាក់នៅផ្ទះលេខ..............ក្រុមទី................ភូមិ..............................ឃុំ/ សង្កាត់
..................................ក្រុង ស្រុក ខណ្ឌ...........................រាជធានី ខេត្ត...............................កាន់អត្ត
សញ្ញាណប័ណ្ណលេខ...................... ។

ខ្ញុំបាទ នាងខ្ញុំឈ្មោះ........................................ភេទ..............អាយុ..........ឆ្នាំ សញ្ជាតិ
........................ អាស័យដ្ឋានស្នាក់នៅផ្ទះលេខ..............ក្រុមទី................ភូមិ..............................ឃុំ/ សង្កាត់
..................................ក្រុង ស្រុក ខណ្ឌ..............................រាជធានី ខេត្ត...............................កាន់អត្ត
សញ្ញាណប័ណ្ណលេខ...................... ។

សូមធ្វើកិច្ចសន្យាជូនរដ្ឋអំណាចអំពីការដាក់សំភារៈសាងសង់ដែលមានទីតាំងលើដីឡូត៍លេខ..............................ផ្លូវ
លេខ......................នៅភូមិ.......................ឃុំ/ សង្កាត់......................................ក្រុង ស្រុក ខណ្ឌ
.................................. រាជធានី ខេត្ត...................................................ដូចខាងក្រោម ÷

១- ធ្វើរបងហ៊ុំព័ទ្ធការដ្ឋានសំណង់ ដាក់សំភារៈ និងធ្វើរបាំងឲ្យបានម៉ត់ចត់ពីក្រោមដល់លើ ដើម្បីការពារគ្រោះថ្នាក់ផ្សេងៗ។

២- រក្សាទុកចិញ្ចើមថ្នល់ឲ្យបានទូលាយ ស្មើនឹងពីរភាគបី សំរាប់ឲ្យថ្មើរជើងធ្វើដំណើរទៅមកដោយសេរី។

៣- មិនយកទ្រូងថ្នល់ធ្វើជាកន្លែងលាយស៊ីម៉ងត៍ ចាក់សំរាម កំទេចកំទីសំភារៈសំណង់ និងចាក់ថ្ម គ្រួស ខ្សាច់ ធ្វើឲ្យប៉ះពាល់ដល់អនាម័យសណ្តាប់ធ្នាប់ដាច់ខាត។

៤- មិនបង្កទំនាស់ មិនរំខានអ្នកជិតខាងជាប់ដីឡូត៍គ្នា។

ក្រែងពុំប្រាកដ យើងខ្ញុំ សូមផ្តិតមេដៃស្តាំទុកជាភស្តុតាងស្រាប់។

ថ្ងៃ......... ខែ .... ឆ្នាំ ....នព្វស័ក ព.ស. ២០៥៦...
..............ថ្ងៃទី..........ខែ............ឆ្នាំ២០.......

**ស្នាមមេដៃស្តាំ**

លេខ:...........................

បានឃើញ និង បញ្ជាក់ថា

ស្នាមមេដៃខាងលើនេះ ពិតជាស្នាមមេដៃស្តាំរបស់

ឈ្មោះ....................................................ប្រាកដមែន។
ថ្ងៃ......... ខែ .... ឆ្នាំ ....នព្វស័ក ព.ស. ២០៥៦...
..................ថ្ងៃទី..........ខែ..............ឆ្នាំ២០......

**មេឃុំ/ចៅសង្កាត់**.......................

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យាសាងសង់ជាប់ជញ្ជាំងម្ចាស់សិទ្ធិ

ខ្ញុំបាទ នាងខ្ញុំឈ្មោះ.................................... ភេទ............. អាយុ............ ឆ្នាំ សញ្ជាតិ............................. អាស័យដ្ឋានស្នាក់នៅផ្ទះលេខ............... ក្រុមទី............ ភូមិ..................... ផ្លូវ.................... ឃុំ/ សង្កាត់........ ............. ក្រុង ស្រុក ខណ្ឌ........................ រាជធានី ខេត្ត................................ មានព្រំ.............................. ជាប់ជាមួយ................................................... ដែលត្រូវសាងសង់លេខ .............................. ផ្លូវ.......................... ឃុំ/ សង្កាត់................................ ក្រុង ស្រុក ខណ្ឌ............ រាជធានី ខេត្ត............ របស់លោក លោកស្រី.................. ..................................................។

អនុញ្ញាតឱ្យលោក/ លោកស្រី........................................................... សាងសង់ជាប់ជញ្ជាំងរបស់ខ្ញុំបាទ-នាងខ្ញុំ ដោយសន្យាថានៅពេលដែលឈ្មោះ............................................... ធ្វើការសាងសង់បើសិនជាមានការប៉ះពាល់ដោយប្រការណាមួយមកលើខាងខ្ញុំ.................................... គឺឈ្មោះ............................................... ត្រូវទទួលខុសត្រូវទាំងស្រុងនូវរាល់ការខូចខាតនេះ។

ក្រែងពុំប្រាកដ យើងខ្ញុំសូមផ្តិតមេដៃស្តាំទុកជាភស្តុតាងស្រាប់។

ថ្ងៃ......... ខែ .... ឆ្នាំ .... នព្វស័ក ព.ស. ២០៥៦...

.............. ថ្ងៃទី......... ខែ............ ឆ្នាំ២០.......

**ស្នាមមេដៃស្តាំអ្នកសុំសាងសង់** **សាក្សី** **ស្នាមមេដៃស្តាំអ្នកអនុញ្ញាតឱ្យ**

លេខ:...........................

បានឃើញ និង បញ្ជាក់ថា

ស្នាមមេដៃខាងលើនេះ ពិតជាស្នាមមេដៃស្តាំរបស់ឈ្មោះ

...........................................................................................

............................................................................ ប្រាកដមែន។

ថ្ងៃ......... ខែ .... ឆ្នាំ .... នព្វស័ក ព.ស. ២០៥៦...

.................. ថ្ងៃទី......... ខែ.............. ឆ្នាំ២០......

**មេឃុំ/ចៅសង្កាត់**........................

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## បទបញ្ជា

ដើម្បីរក្សានូវ សណ្ដាប់ធ្នាប់សាធារណៈ សោភ័ណភាពរបស់ក្រុង-ស្រុក-ខណ្ឌ និងធានានូវគុណភាព និងសុវត្ថិភាពរបស់សំណង់ យោងតាមអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន និងអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសេចក្ដីសម្រេច លេខ ១២សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ ស្ដីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ស្រុក ខណ្ឌរបស់រាជរដ្ឋាភិបាល

ម្ចាស់សំណង់ត្រូវ:

១-មានលិខិតអនុញ្ញាតបើកការដ្ឋាន មុនពេលសាងសង់ពីសាលាក្រុង-ស្រុក-ខណ្ឌ ..........................................។

២-អនុវត្តតាមប្លង់លម្អិតគ្រឿងផ្គុំសំណង់ និងគោរពតាមប្លង់ស្ថាបត្យកម្ម ដែលបានយល់ព្រមដោយសាលាក្រុង-ស្រុក-ខណ្ឌ ..........................................។

៣-ការពារសុវត្ថិភាពនៅពេលសាងសង់ដល់អគារជិតខាង និងធានានូវសណ្ដាប់ធ្នាប់សាធារណៈ ដូចជា ការធ្វើរបងព័ទ្ធជុំវិញការដ្ឋាន ការទុកដាក់គ្រឿងចក្រ ឬសម្ភារៈសំណង់ និងការងារអនាម័យជាដើម

៤-មានលិខិតបិទការដ្ឋាន ឬវិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវតាមប្លង់នៃសំណង់ពីសាលាក្រុង-ស្រុក-ខណ្ឌ .............. ក្រោយពេលសាងសង់រួចជាស្ថាពរ មុនដំណើរការប្រើប្រាស់សំណង់។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ ..........................................សូមគោរពតាមបទបញ្ជា ដូចមានចែងខាងលើ ដោយឥតល័ក្ខខ័ណ្ឌ។ ក្នុងករណីដែលខ្ញុំបាទ-នាងខ្ញុំ មិនគោរពតាមបទបញ្ជាខាងលើនេះ ខ្ញុំបាទ-នាងខ្ញុំ សុខចិត្តឱ្យអាជ្ញាធរមានសមត្ថកិច្ចចាត់វិធានការផ្អាកការដ្ឋាន មិនឱ្យចូលស្នាក់នៅ មិនផ្ដល់កម្មសិទ្ធ មិនឱ្យបើកអាជីវកម្ម ឬ កសាងសំណុំរឿងឯកសារបញ្ជូនទៅតុលាការ ដើម្បីពិនិត្យវិនិច្ឆ័យករណីខុសច្បាប់ជាធរមាន។

ថ្ងៃ.................ខែ............ឆ្នាំ..............ព.ស.២៥៦...

ធ្វើនៅ............ ថ្ងៃទី........ខែ........ឆ្នាំ ២០......

**ស្នាមមេដៃស្ដាំ**

លេខ:.................................................. ជនសភ..........

**បានឃើញ និង ពិនិត្យសម្រេច**

**បញ្ជូនមកលោកអភិបាល ក្រុង-ស្រុក-ខណ្ឌ មេត្តាពិនិត្យ និង សម្រេច**

ថ្ងៃ.................................. ខែ.................. ឆ្នាំ............ ព.ស. ២៥៦...

.................., ថ្ងៃទី.................ខែ......................ឆ្នាំ ២០.........

**ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ក្រុង-ស្រុក-ខណ្ឌ..............**

លេខ:..................................................

**បានឃើញ និង យល់ព្រម**

ថ្ងៃ.................................. ខែ.......................... ឆ្នាំ............ ព.ស. ២៥៦...

.................., ថ្ងៃទី.......................ខែ........................ ឆ្នាំ ២០.......

**អភិបាល ក្រុង-ស្រុក-ខណ្ឌ..............**

ទ្រង់ទ្រាយ A3

| លេខ | ថ្ងៃ ខែ ឆ្នាំ | កំណែ | ក្រុមហ៊ុនសិក្សាគម្រោងប្លង់ | ឈ្មោះ-មុខងារ | | ហត្ថលេខា | ថ្ងៃ ខែ ឆ្នាំ | ទីតាំងសាងសង់ : | ម្ចាស់សំណង់ : | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | គូរដោយ | | | | | | | |
| | | | | គណនាដោយ | | | | ឈ្មោះគម្រោង : | | | |
| | | | | សិក្សាដោយ | | | | | | | |
| | | | | ពិនិត្យដោយ | | | | ឈ្មោះប្លង់ : | មាត្រដ្ឋាន | ចំនួនសន្លឹក | លេខសន្លឹក |
| | | | | យល់ព្រមដោយ | | | | | | | |

# ឧបសម្ព័ន្ធទី២៖ សំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋាន

ខ្ញុំបាទនាងខ្ញុំឈ្មោះ.......................................... ភេទ.............. អាយុ.......... ឆ្នាំ សញ្ជាតិ........................ ថ្ងៃ ខែ ឆ្នាំកំណើត................................ កាន់អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនលេខ........................................ ចុះថ្ងៃទី........... ខែ............. ឆ្នាំ.............. មុខរបរ........................................................................................ អាស័យដ្ឋានទំនាក់ទំនងផ្ទះលេខ............ ផ្លូវ.............. ឃុំ/ សង្កាត់..................... ក្រុង ស្រុក ខណ្ឌ..................... រាជធានី ខេត្ត............................ ទូរស័ព្ទលេខ................................ ទូរសារលេខ............................ ។

**គោរពជូន**

**លោក/លោកស្រី អភិបាលក្រុង ស្រុក ខណ្ឌ**............................

**កម្មវត្ថុ** : សំណើសុំលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់.......................................................................
ដែលមានទីតាំងស្ថិតនៅដីឡូត៍លេខ.............. ផ្លូវ................................ ភូមិ.....................................
ឃុំ/ សង្កាត់.......................... ក្រុង ស្រុក ខណ្ឌ..................... រាជធានី ខេត្ត................................ ។

**យោង** : លិខិតអនុញ្ញាតសាងសង់លេខ.......... ចុះថ្ងៃទី......... ខែ.......... ឆ្នាំ......... របស់សាលាក្រុង ស្រុក ខណ្ឌ........ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោក/លោកស្រីអភិបាលខណ្ឌ មេត្តាអនុញ្ញាតផ្តល់ឱ្យ ខ្ញុំបាទ/នាងខ្ញុំ នូវលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់.................................................................................. ដែលមានទីតាំងដូចខាងលើដោយអនុគ្រោះ ។

ខ្ញុំបាទ-នាងខ្ញុំ សូមសន្យាថាអនុវត្តទៅតាមបទបញ្ញាដូចបានចែងក្នុងគម្រោងប្លង់ដែលបានអនុញ្ញាត ប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ បទដ្ឋានបច្ចេកទេសសំណង់ ច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

សូមលោក/លោកស្រីអភិបាល ទទួលនូវការគោរពពីខ្ញុំបាទ/ នាងខ្ញុំ ។

ថ្ងៃ ខែ ឆ្នាំ... នព្វស័ក ព.ស.២៥៦...

.................. ថ្ងៃទី............ ខែ.............ឆ្នាំ២០......

**ហត្ថលេខា ឬស្នាមមេដៃស្តាំម្ចាស់សំណង់**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យារបស់ម្ចាស់សំណង់

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ........................................................ភេទ...........អាយុ.............ឆ្នាំសញ្ជាតិ................ មុខរបរសព្វថ្ងៃ........................................................................................ទីលំនៅបច្ចុប្បន្នផ្ទះលេខ................ ផ្លូវ................ភូមិក្រុម...............................ឃុំ/ សង្កាត់.........................ក្រុង ស្រុក ខណ្ឌ................................ រាជធានី ខេត្ត.......................... ជាម្ចាស់សំណង់........................................................................................... ដែលមានទីតាំងនៅដីឡូតិ៍លេខ..............ផ្លូវ.............. ឃុំ/ សង្កាត់..........................ក្រុង ស្រុក ខណ្ឌ..................... រាជធានី ខេត្ត......................................... សូមសន្យាដូចតទៅ ÷

១- គោរពនិងអនុវត្តតាមការណែនាំរបស់សាលាខណ្ឌ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់និង ភូមិបាល ក្រុង ស្រុក ខណ្ឌ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតាមច្បាប់ បទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

២- គោរពតាមលិខិតអនុញ្ញាតសាងសង់និងគម្រោងប្លង់ស្ថាបត្យកម្ម ដែលទទួលបាននូវការអនុញ្ញាតពីសាលាក្រុង ស្រុក ខណ្ឌ។

៣- គោរព និងអនុវត្តតាមគម្រោងប្លង់គ្រឿងផ្គុំសំណង់ ដែលគណនាទទួលខុសត្រូវដោយវិស្វករសំណង់ ។

៤- ធានា និងទទួលខុសត្រូវលើគុណភាពសំណង់ និងសុវត្ថិភាពសំណង់ ។

៥- ធានាខុសត្រូវចំពោះការបាក់ស្រុតពេលកំពុងសាងសង់ និងក្រោយពេលសាងសង់រួច ។

ក្នុងករណីដែលខ្ញុំបាទ/ នាងខ្ញុំ មិនគោរពតាមកិច្ចសន្យាខាងលើ ឬអនុវត្តខុសឆ្គងលើលក្ខណៈបច្ចេកទេសក្នុងការ សាងសង់ខ្ញុំបាទ/នាងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុងលើគុណភាព និងសុវត្ថិភាពសំណង់ និងយល់ព្រមឱ្យសាលាក្រុង ស្រុក ខណ្ឌ ធ្វើការផ្អាកការដ្ឋានរបស់ខ្ញុំបាទ/ នាងខ្ញុំ ព្រមទាំងចាត់វិធានការទៅតាមផ្លូវច្បាប់ជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា ។

ក្រែងពុំពិតប្រាកដខ្ញុំបាទ/ នាងខ្ញុំ សូមផ្តិតមេដៃស្តាំទុកជាភស្តុតាង ។

ថ្ងៃ ខែ ឆ្នាំ... នព្វស័ក ព.ស.២៥៦...

........................ ថ្ងៃទី............ខែ..............ឆ្នាំ២០.....

**ស្នាមមេដៃស្តាំម្ចាស់សំណង់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ការត្រួតពិនិត្យសំណុំឯកសារសម្រាប់សុំលិខិតអនុញ្ញាតបើកការដ្ឋាន

១. ម្ចាស់សំណង់ឈ្មោះ.......................................... ភេទ................ អាយុ............. ឆ្នាំសញ្ជាតិ.......................

២. ប្រភេទសំណង់..........................................................................................................................

៣. ទីតាំងស្នើសុំសាងសង់÷ ដីឡូត៍លេខ.................... ផ្លូវ...................... ភូមិ...................... ឃុំ/ សង្កាត់.............

ក្រុង ស្រុក ខណ្ឌ.............................. រាជធានី ខេត្ត.............................. ផ្ទៃក្រឡាដី.......................... ម² ។

៤. លិខិតអនុញ្ញាតសាងសង់របស់សាលាក្រុង ស្រុក ខណ្ឌ មាន☐ គ្មាន☐

៤.១. សុពលភាពលិខិតអនុញ្ញាតសាងសង់ មានសុពលភាព☐ ផុតសុពលភាព☐

៥. កិច្ចសន្យារវាងម្ចាស់សំណង់និងអ្នកម៉ៅការសាងសង់ មាន☐ គ្មាន☐

៦. វិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់របស់ក្រុមហ៊ុនសាងសង់ ឬក្រុមជាងសំណង់ មាន☐ គ្មាន☐

៧. ឯកសារពាក់ព័ន្ធរួមមាន ÷

- ប្លង់ស្ថាបត្យកម្មដែលបានអនុម័ត មាន☐ គ្មាន☐
- ប្លង់គ្រឿងផ្គុំសំណង់ មាន☐ គ្មាន☐
- សញ្ញាបត្រវិស្វករគណនាគ្រឿងផ្គុំសំណង់ មាន☐ គ្មាន☐
- របាយការណ៍សិក្សាពិសោធន៍ដី មាន☐ គ្មាន☐
-

..........................................................................................................

-

..........................................................................................................

-

៨. យោបល់មន្ត្រីជំនាញក្នុងការបើកការដ្ឋាន÷ គួរអនុញ្ញាត☐ មិនគួរអនុញ្ញាត☐

មូលហេតុ÷

..........................................................................................................................................

..........................................................................................................................................

ថ្ងៃ ខែ ឆ្នាំ... នព្វស័ក ព.ស.២៥៦...

.................. ថ្ងៃទី............ ខែ..............ឆ្នាំ២០......

**មន្ត្រីត្រួតពិនិត្យ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កំណត់បង្ហាញ

## ស្តីពី

## ការចុះត្រួតពិនិត្យការដ្ឋាន.............................................

១. ឆ្នាំ..................... ខែ........................ ថ្ងៃទី........................ វេលាម៉ោង....................................................

២. នៅ ..........................................................................................................................................

៣. មានការត្រួតពិនិត្យការដ្ឋានសំណង់ទីតាំងដីឡូត៍លេខ...........................................................................

...................................................................................................................................................

...................................................................................................................................................

៤. ក្រោមការដឹកនាំរបស់..........................................................................................................

៥. សមាសភាពចូលរួម ÷

...................................................................................................................................................

...................................................................................................................................................

៦. លទ្ធផលនៃការត្រួតពិនិត្យ ÷...............................................................................................

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

...................................................................................................................................................

៧. ការងារត្រួតពិនិត្យការដ្ឋានសាងសង់ខាងលើបានបញ្ចប់សព្វគ្រប់នៅម៉ោង............................នៃថ្ងៃខែឆ្នាំ ដដែល។

**អ្នកធ្វើកំណត់ហេតុ**

បានឃើញ និងឯកភាព

ថ្ងៃ ខែ ឆ្នាំ... នព្វស័ក ព.ស.២៥៦...

....................ថ្ងៃទី...........ខែ...........ឆ្នាំ២០........

**ប្រធានក្រុមការងារ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាក្រុង ស្រុក ខណ្ឌ.................**
លេខ..............................

ថ្ងៃ ខែ ឆ្នាំ... នព្វស័ក ព.ស.២៥៦...
...............ថ្ងៃទី.........ខែ...........ឆ្នាំ២០......

# លិខិតអនុញ្ញាតបើកការដ្ឋាន

**យោង ÷**

- **លិខិតអនុញ្ញាតសាងសង់លេខ.........ចុះថ្ងៃទី........ខែ.........ឆ្នាំ........របស់សាលាក្រុង ស្រុក ខណ្ឌ...............**
- **ប្លង់គ្រឿងផ្គុំសំណង់**
- **កំណត់ហេតុពិនិត្យការដ្ឋានសាងសង់ចុះថ្ងៃទី.........ខែ...........ឆ្នាំ............**
- **ពាក្យសុំលិខិតអនុញ្ញាតបើកការដ្ឋានចុះថ្ងៃទី.........ខែ...........ឆ្នាំ............**

**សាលាក្រុង ស្រុក ខណ្ឌ................................**

**អនុញ្ញាតជូន**

លោក/ លោកស្រី......................................................ភេទ.............អាយុ...........ឆ្នាំ សញ្ជាតិ
......................... មុខរបរ.........................................................ជាម្ចាស់សំណង់
........................................................................... ដែលមានទីតាំងស្ថិតដីឡូត៍លេខ.................... ផ្លូវ
.........................ភូមិ.........................ឃុំ/ សង្កាត់.......................... ក្រុង ស្រុក ខណ្ឌ...................................
រាជធានី ខេត្ត....................................នូវលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ខាងលើចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ម្ចាស់សំណង់ និងក្រុមហ៊ុនសាងសង់ ឬក្រុមជាងសំណង់ ត្រូវគោរពតាមបទបញ្ជាដូចមានចែងក្នុងគម្រោងប្លង់ ដែល បាន អនុញ្ញាត បទបញ្ជា ប្រកាសស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ បទប្បញ្ញត្តិបច្ចេកទេសសំណង់ និងច្បាប់ជាធរមាននៃព្រះរាជណាចក្រកម្ពុជា។

**អភិបាលក្រុង ស្រុក ខណ្ឌ**

ចម្លងជូន÷

- សាលារាជធានី ខេត្ត
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត...................
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ.............
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣៖ សំណុំឯកសារនៃពាក្យសុំលិខិតអនុញ្ញាតបិទការដ្ឋាន ឬ វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ



## ពាក្យសុំលិខិតអនុញ្ញាតបិទការដ្ឋាន

ខ្ញុំបាទនាងខ្ញុំឈ្មោះ.......................................ភេទ...............អាយុ..........ឆ្នាំ សញ្ជាតិ.........................
ថ្ងៃ ខែ ឆ្នាំកំណើត.....................................កាន់អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនលេខ.................................
ចុះថ្ងៃទី...........ខែ...............ឆ្នាំ..............មុខរបរ......................................................................................
អាសយដ្ឋានទំនាក់ទំនងផ្ទះលេខ............ផ្លូវ......................ឃុំ/ សង្កាត់.....................ក្រុង ស្រុក ខណ្ឌ....................
រាជធានី ខេត្ត..........................ទូរស័ព្ទលេខ...............................ទូរសារលេខ.........................................។

**គោរពជូន**

**លោក/លោកស្រី អភិបាលក្រុង ស្រុក ខណ្ឌ............................**

**កម្មវត្ថុ** : សំណើសុំលិខិតអនុញ្ញាតបិទការដ្ឋានសាងសង់.......................................................................
ដែលមានទីតាំងស្ថិតនៅដីឡូតិ៍លេខ.................ផ្លូវ..........................ភូមិ.......................................
ឃុំ/ សង្កាត់............................ក្រុង ស្រុក ខណ្ឌ......................រាជធានី ខេត្ត............................។

**យោង** : - លិខិតអនុញ្ញាតសាងសង់លេខ..........ចុះថ្ងៃទី.......ខែ........ឆ្នាំ.........របស់សាលាក្រុង ស្រុកខណ្ឌ.........។
- លិខិតអនុញ្ញាតបើកការដ្ឋានលេខ.......ចុះថ្ងៃទី......ខែ........ឆ្នាំ........របស់សាលាក្រុង ស្រុក ខណ្ឌ........។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោក/ លោកស្រីអភិបាល មេត្តាអនុញ្ញាតផ្ដល់ឱ្យខ្ញុំបាទ/ នាងខ្ញុំ នូវលិខិតអនុញ្ញាតបិទការដ្ឋានសាងសង់.......................................................................................... ដែលមានទីតាំងដូចខាងលើដោយអនុគ្រោះ ។

សូមលោក/ លោកស្រីអភិបាល ទទួលនូវការគោរពពីខ្ញុំបាទ/ នាងខ្ញុំ ។

ថ្ងៃ ខែ ឆ្នាំ... នព្វស័ក ព.ស.២៥៦...

.................. ថ្ងៃទី............ ខែ..............ឆ្នាំ២០.......

**ហត្ថលេខា ឬស្នាមមេដៃស្ដាំម្ចាស់សំណង់**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ការត្រួតពិនិត្យសំណុំឯកសារសម្រាប់សុំលិខិតអនុញ្ញាតបិទការដ្ឋាន

១. ម្ចាស់សំណង់ឈ្មោះ........................................ភេទ.................អាយុ.............ឆ្នាំសញ្ជាតិ........................

២. ប្រភេទសំណង់..........................................................................................................................

៣. ទីតាំងស្នើសុំសាងសង់÷ ដីឡូត៍លេខ.......................ផ្លូវ..........................ភូមិ...................ឃុំ/ សង្កាត់..............

ក្រុង ស្រុក ខណ្ឌ..............................រាជធានី ខេត្ត..................................ផ្ទៃក្រឡាដី............................ម$^2$ ។

៤. លិខិតអនុញ្ញាតសាងសង់របស់សាលាក្រុង ស្រុក ខណ្ឌ មាន☐ គ្មាន☐

៤.១. សុពលភាពលិខិតអនុញ្ញាតសាងសង់ មានសុពលភាព☐ ផុតសុពលភាព☐

៥. លិខិតអនុញ្ញាតបើកការដ្ឋានរបស់សាលាក្រុង ស្រុក ខណ្ឌ មាន☐ គ្មាន☐

៦. ឯកសារពាក់ព័ន្ធរួមមាន ÷

- ប្លង់ស្ថាបត្យកម្មដែលបានអនុម័ត មាន☐ គ្មាន☐
- ប្លង់គ្រឿងផ្គុំសំណង់ មាន☐ គ្មាន☐
- ក្រុមហ៊ុនម៉ៅការសាងសង់ ឬក្រុមជាងសំណង់ មាន☐ គ្មាន☐
- បញ្ហាទំនាស់ មាន☐ គ្មាន☐
- បញ្ហាផ្សេងៗ ..........................................................................................

..........................................................................................

..........................................................................................

..........................................................................................

៧. យោបល់មន្ត្រីជំនាញក្នុងការបិទការដ្ឋាន÷ គួរអនុញ្ញាត☐ មិនគួរអនុញ្ញាត☐

មូលហេតុ÷

..........................................................................................................................

..........................................................................................................................

..........................................................................................................................

ថ្ងៃ ខែ ឆ្នាំ... នព្វស័ក ព.ស.២៥៦...

.................. ថ្ងៃទី............ ខែ..............ឆ្នាំ២០......

**មន្ត្រីត្រួតពិនិត្យ**

# ឧបសម្ព័ន្ធគតិយុត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

........

# ច្បាប់

ស្តីពី

# ការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

ព.ស ២៥៣៨ គ.ស ១៩៩៤

# ច្បាប់

## ស្តីពី

## ការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់

## ជំពូកទី ១

## កម្មវត្ថុ

មាត្រា ១.-

ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ មានកម្មវត្ថុជំរុញអោយមានការរៀបចំកែលំអទីក្រុងនិងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងធានាកិច្ចអភិវឌ្ឍន៍សុខដុមនៃប្រទេស ក្នុងស្មារតី :

- គោរពប្រយោជន៍រួមនិងប្រយោជន៍បុគ្គលផង គោរពសិទ្ធិឯកជនផង គោរពបទបញ្ញាច្បាប់ផងនិងត្រួតពិនិត្យការសាងសង់ផង ។
- ធានាការអភិវឌ្ឍន៍សំដៅរកលំនឹងរវាងទីក្រុងនិងតំបន់ជនបទ ផ្អែកទៅលើភូមិសាស្ត្រនិងលក្ខណៈពិសេសនៃជនបទនីមួយៗ ។
- ធានាលើកលែសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌និងធានាការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច វិស័យទេសចរណ៍និងរក្សាបាននូវគុណភាពបរិដ្ឋាន ។

មាត្រា ២.-

ច្បាប់រៀបចំទឹកដី នគរូបនីយកម្មនិងសំណង់នេះ ត្រូវសំអាងទៅលើកម្មសិទ្ធិដែលអនុលោមទៅតាមច្បាប់ភូមិបាលបច្ចុប្បន្ន, ។ ក្នុងករណីដែលច្បាប់ភូមិបាលត្រូវកែប្រែឬផ្លាស់ប្តូរ ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់នឹងត្រូវកែច្នៃអោយស្របទៅតាមច្បាប់ភូមិបាលនេះដែរ ។

មាត្រា ៣.-

ដើម្បីសំរេចនូវបំណងដែលបានចែងខាងលើនេះ ត្រូវបង្កើតអោយមានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ ដែលមានសមាជិកនិងសំណើការតែងតាំងនឹងរៀបចំដោយអនុក្រឹត្យ ។

# ជំពូកទី ៣
## ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់

មាត្រា ៦.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវរៀបចំឡើងសំរាប់រាជធានី ខេត្ត ក្រុង ។ ប្លង់នេះត្រូវមានការគោរពពីសំណាក់ឯកជនក៏ដូចជាអាជ្ញាធរសាធារណៈក្នុងកិច្ចការសាងសង់របស់ខ្លួន ។

មាត្រា ៧.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ត្រូវតែបញ្ជាក់អោយច្បាស់លាស់អំពីតំបន់ដែលត្រូវប្រើប្រាស់សំរាប់ការពារជាតិ សំរាប់កសិកម្ម សំរាប់ពាណិជ្ជកម្ម សំរាប់ឧស្សាហកម្ម សំរាប់ សិប្បកម្ម សំរាប់វប្បធម៌ សំរាប់ទេសចរណ៍ សំរាប់សាសនា ព្រមទាំងសំរាប់សំណង់នៃរដ្ឋបាលនិងបរិក្ខាសាធារណៈ ។ ប្លង់នេះកំណត់ផងដែរនូវលទ្ធភាពសំរាប់សាងសង់ ។

មាត្រា ៨.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ត្រូវគោរពតាមប្លង់គោល ដូចមានចែងក្នុងមាត្រា ៥ នៃច្បាប់នេះ ។

មាត្រា ៩.-

ប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់សំរាប់រាជធានីនិងខេត្ត ក្រុងនីមួយៗត្រូវមានការទទួលយល់ព្រមពីគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់រាជធានី ឬ អនុគណៈកម្មាធិការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ខេត្ត ក្រុង រួចត្រូវមានការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ទៀត ។ ប្លង់ទាំងអស់ត្រូវមានការទទួលគោរពពីឯកជន ក៏ដូចជាអាជ្ញាធរសាធារណៈទាំងពួងដែរ ។

មាត្រា ១០.-

រាជរដ្ឋាភិបាលរៀបចំបទបញ្ញត្តិពិសេសនិងសេវាភាពនគរូបនីយកម្មដើម្បីការពារនិងលើកតម្លៃរមណីយដ្ឋានឬអចលនវត្ថុណាដែលនឹងផ្តល់នូវអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពឬបច្ចេកទេស ។ បញ្ជីអចលនវត្ថុឬ

## ជំពូកទី ៤
## ការងារនិងសំណង់

មាត្រា ១១.-

រាល់ការកកាយរុករកឬការស្ទង់ដែលមានការប៉ះពាល់ដល់ខាងផ្នែកបុរាណវិទ្យា ចាំបាច់ត្រូវមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

រាល់ការសាងសង់ ក្នុងករណីជួបប្រទះនូវវត្ថុអ្វីមួយដែលមានអត្ថប្រយោជន៍ខាងផ្នែកបុរាណវិទ្យាឬប្រវត្តិសាស្ត្រ អ្នកទទួលខុសត្រូវការដ្ឋានត្រូវមានកាតព្វកិច្ចរាយការណ៍មកអាជ្ញាធរមានសមត្ថកិច្ចអោយបានជ្រាបភ្លាមៗ ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវបញ្ឈប់ផ្អាកសំណង់ជាបន្ទាន់ ។

មាត្រា ១២.-

រាល់បុគ្គលឬស្ថាប័នឯកជនក៏ដូចជាអាជ្ញាធរសាធារណៈ ត្រូវហាមឃាត់មិនអោយសាងសង់លើទីធ្លាដែលមានលក្ខណៈជាសាធារណៈដូចតទៅ ៖

- ទីបំរុងទុកទឹកនិងទំនប់ទឹក
- ទីបំរុងជីករ៉ែនិងតំបន់ព្រៃឈើ
- រមណីយដ្ឋានបុរាណវិទ្យានិងប្រវត្តិសាស្ត្រ
- សួនច្បារ ឧទ្យានសាធារណៈនិងតំបន់អភិវឌ្ឍន៍
- ដីបំរុងទុកសំរាប់ផ្លូវ បំរុងសំរាប់ចំណីផ្លូវនិងដីបំរុងទុកសំរាប់ផ្លូវរថភ្លើង និងអាកាសយានដ្ឋាន
- ទន្លេ សមុទ្រ ព្រែក ស្ទឹងព្រមទាំងឆ្នេរច្រាំង
- ជាទូទៅនៅលើដីទាំងឡាយណាដែលបញ្ញត្តិច្បាប់កំណត់មិនឲ្យសង់ ។

លក្ខខ័ណ្ឌនៃការគ្រប់គ្រងតំបន់ទាំងនោះ លក្ខខ័ណ្ឌសំណង់ឬតាំងទីលំនៅធុនស្រាល បណ្តោះអាសន្ន អនុញ្ញាតបានដោយអនុក្រឹត្យ

មាត្រា ១៣.-

ការងារសាងសង់និងការតាំងទីត្រូវធ្វើឡើងដោយគោរពតាមឯកសារដែលទាក់ទងនឹងការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ គោរពតាមប្លង់គោលដែលមានចែងក្នុងមាត្រា ៤ និង ៥ នៃច្បាប់នេះ ។

មាត្រា ១៤.-

រាល់ការសាងសង់ រាល់ការកែប្រែទិដ្ឋភាពឬការកែប្រែការប្រើប្រាស់សំណង់ណាមួយ ត្រូវមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ។

ពាក្យស្នើសុំអនុញ្ញាតសាងសង់ត្រូវមានឯកសារនិងប្លង់ចាំបាច់ ។ និតិវិធីក្នុងការអនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៥.-

ឯកសារនិងប្លង់ចាំបាច់សំរាប់ភ្ជាប់ពាក្យសុំអនុញ្ញាតសាងសង់សំណង់ធំៗ ត្រូវរៀបចំឡើងដោយស្ថាបត្យករខ្មែរមានសញ្ញាប័ត្រឬជនណាដែលមានការទទួលស្គាល់ពីស្ថាប័នមានសមត្ថកិច្ច ។

លក្ខខ័ណ្ឌដែលទាមទារអំពីសញ្ញាបត្រនិងទាមទារការទទួលស្គាល់ខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៦.-

ពាក្យសុំអនុញ្ញាតសាងសង់ត្រូវយកមកដាក់សុំដោយម្ចាស់កម្មសិទ្ធិដីឬអ្នកបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ។ ពាក្យសុំអនុញ្ញាតនេះត្រូវមានភ្ជាប់មកជាមួយផងនូវឯកសារបញ្ជាក់អំពីកម្មសិទ្ធិរបស់ម្ចាស់ដី ។

មាត្រា ១៧.-

មិនអនុញ្ញាតអោយសាងសង់នូវសំណង់ណាក្នុងលក្ខណៈដែលមិនសមស្របនឹងប្លង់គោលឬប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ ។

មិនអនុញ្ញាតអោយសាងសង់ បើគម្រោងសាងសង់នោះមានការប៉ះពាល់ដល់សន្តិសុខសាធារណៈ ប៉ះពាល់ដល់បរិដ្ឋាន ប៉ះពាល់ដល់អនាម័យសាធារណៈ សំណង់ឬអចលនវត្ថុដែលមានសារប្រយោជន៍ដល់ផ្នែកបុរាណវិទ្យា ប្រវត្តិសាស្ត្រ វប្បធម៌ សោភ័ណភាពបច្ចេកទេសឬប៉ះពាល់ដល់តំបន់ដែលមានធនធានធម្មជាតិ ។

មិនអនុញ្ញាតអោយសាងសង់ បើសិនជាពុំមានការរៀបចំអោយមានហេដ្ឋារចនាសម្ព័ន្ធឬបរិក្ខាសាធារណៈអោយបានគ្រប់គ្រាន់និងតំរែងសំណង់ដែលសុំ ។

មាត្រា ១៨.-

ក្នុងករណីពុំទាន់មានប្លង់ប្រើប្រាស់ដីធ្លីនិងសំណង់ អាជ្ញាធរខេត្ត ក្រុង ត្រូវបង្កើតគណៈកម្មការដើម្បីពិនិត្យពាក្យសុំនិងចេញលិខិតអនុញ្ញាតសាងសង់ ។

មាត្រា ១៩.-

ចំពោះគំរោងសំណង់រដ្ឋបាល អង្គភាពដែលស្នើសុំសាងសង់ត្រូវមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ច ។

ការអនុញ្ញាតនោះអាចផ្តល់បានតែចំពោះសំណង់ណាដែលមានលក្ខណៈចាំបាច់សំរាប់ដំណើរការផ្នែករដ្ឋបាល ។

ការអនុញ្ញាតនេះមិនអាចនាំអោយមានការផ្លាស់ប្តូរនូវការប្រើប្រាស់ដីធ្លីដែលបានកំណត់មកហើយ ហើយក៏មិនអាចកែប្រែនូវលក្ខណៈសាធារណៈនិងអត្ថប្រយោជន៍ទូទៅនៃតំបន់នេះឡើយ ។

មាត្រា ២០.-

សំណង់ទាំងឡាយណាដែលអ្នកវិនិយោគទុនឯកជនបានសាងសង់នៅលើដីរបស់រដ្ឋស្របតាមកិច្ចសន្យាណាមួយ ត្រូវប្រគល់មកអោយរដ្ឋវិញពេលផុតកំណត់ចែងក្នុងកិច្ចសន្យានោះ ។

មាត្រា ២១.-

បើគ្មានមូលហេតុត្រឹមត្រូវដែលបានបញ្ជាក់ក្នុងច្បាប់នេះ មន្ត្រីរាជការណាដែលប្រកែកមិនព្រមទទួលពិនិត្យពាក្យសុំសាងសង់ឬចេញលិខិតអនុញ្ញាតសាងសង់ឬប្រឆាំងនឹងការចេញលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលមួយយ៉ាងយូរ ៤៥ ថ្ងៃទេនោះ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

ក៏ត្រូវផ្តន្ទាទោសផងដែរ ចំពោះភ្នាក់ងារណាដែលបានពិនិត្យគំរោងសាងសង់និងចេញលិខិតអនុញ្ញាតសាងសង់ដែលមិនស្របនឹងបទបញ្ញត្តិ ។

ភ្នាក់ងារត្រួតពិនិត្យលើសំណង់ដែលពុំបានជំទាស់ ពេលដែលខ្លួនឃើញសំណង់លើការដ្ឋានណាមួយមិនគោរពតាមគំរោងដែលបានអនុញ្ញាត ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ ។

ទណ្ឌកម្មផ្នែករដ្ឋបាលដែលត្រូវយកមកអនុវត្តចំពោះភ្នាក់ងារដែលមានកំហុសដូចបានរៀបរាប់ខាងលើនេះ ត្រូវកំណត់ដោយច្បាប់រដ្ឋបាល ។

ចំណែកឯអ្នកសាងសង់ដែលមិនគោរពលិខិតអនុញ្ញាតសាងសង់ទេនោះ នឹងត្រូវទទួលបង្គាប់អោយរុះរើកែសំណង់អោយស្របតាមលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេល ៣០ ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលលិខិតបញ្ជាផ្លូវការ ។

មន្ត្រីរាជការណាដែលរួមគំនិត នឹងត្រូវដាក់បទចោទប្រកាន់ចំពោះមុខតុលាការ ។

នៅពេលពិនិត្យឃើញមានសំណង់ខុសឆ្គង ការដ្ឋានត្រូវបញ្ឈប់ ហើយជាយថាហេតុ សម្ភារៈនិងឧបករណ៍សំណង់នៅទីនោះ ត្រូវទទួលរឹបអូសតាមបង្គាប់តុលាការ ។ ក្នុងករណីដែលអ្នកសាងសង់ទទួលរងគ្រោះដោយមិនមែនជាកំហុសរបស់ខ្លួន អ្នករងគ្រោះអាចប្រើសិទ្ធិរបស់ខ្លួនដើម្បីប្តឹងទៅតុលាការទារជម្ងឺចិត្ត ។

មាត្រា ២២.-

ម្ចាស់សំណង់ មុនពេលវាយកំទេចសំណង់របស់ខ្លួនដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតរុះរើពីអាជ្ញាធរមានសមត្ថកិច្ចជាមុនសិន ។

បែបបទនៃការរុះរើវាយកំទេចសំណង់នឹងត្រូវកំណត់ដោយអនុក្រឹត្យ ។

ការអនុញ្ញាតអោយរុះរើវាយកំទេចសំណង់អាចត្រូវបដិសេធបាន ក្នុងលក្ខណៈ
ដែលការរុះរើវាយកំទេចសំណង់នោះមានទាក់ទិននឹងបញ្ហាសង្គមកិច្ច បច្ចេកទេសនិងបេតិកភណ្ឌ ដែលរដ្ឋបានកត់ត្រា។

មាត្រា ២៣.-

បទបញ្ញត្តិទាំងឡាយណាដែលមាននៅក្នុងច្បាប់ពីមុន ស្តីពីការរៀបចំទឹកដី នគរូបនីយកម្មនិងសំណង់ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃ ច័ន្ទ ទី ២៣ ខែឧសភា ឆ្នាំ១៩៩៤ នាសម័យប្រជុំ
រដ្ឋសភាលើកទី ២ នីតិកាលទី ១ ។

ភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ ១៩៩៤

ប្រធានរដ្ឋសភាស្តីទី

# ព្រះរាជក្រម

នស/រកម/១១១៩/០១៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសំណង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ច្បាប់
# ស្តីពី
# សំណង់

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ច្បាប់នេះមានគោលបំណងធានា៖

- គុណភាព សន្តិសុខ សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិនិងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- សោភណភាពនិងបរិស្ថានល្អសម្រាប់ការរស់នៅប្រកបដោយចីរភាព សំដៅលើកកម្ពស់សុខុមាលភាពសាធារណៈ
- គណនេយ្យភាពនិងប្រសិទ្ធភាពក្នុងការប្រកបការងារនិងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់
- ការបង្កើនការជឿទុកចិត្តរបស់វិនិយោគិននៅក្នុងវិស័យសំណង់ និងជំរុញទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនិងសង្គម។

**មាត្រា២.-**

ច្បាប់នេះមានគោលដៅកំណត់គោលការណ៍ បទប្បញ្ញត្តិបច្ចេកទេសសំណង់ វិធាន និងនីតិវិធីក្នុងការគ្រប់គ្រងវិស័យសំណង់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះវិស័យសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែប្រភេទសំណង់ដែលកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥.-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់ដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៣
## គោលការណ៍

**មាត្រា៦.-**

រាល់ការសាងសង់សំណង់ត្រូវគោរពគោលការណ៍៖

- ការពារផលប្រយោជន៍សាធារណៈនិងសិទ្ធិបុគ្គល
- ប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន
- រៀបចំដែនដីនិងនគរូបនីយកម្ម
- អភិវឌ្ឍបៃតង ការពារធនធានធម្មជាតិ និងបរិស្ថាន
- រក្សានិងលើកកម្ពស់អត្តសញ្ញាណជាតិ។

## ជំពូកទី៤
## បទប្បញ្ញត្តិបច្ចេកទេសសំណង់

**មាត្រា៧ ..**

រាល់ការងារសំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ការត្រួតពិនិត្យអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨ ..**

រាល់សំណង់ត្រូវមានគ្រឿងផ្គុំដែលអាចទ្ររាល់បន្ទុកបានប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់របស់សំណង់ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពគ្រឿងផ្គុំត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៩ ..**

រាល់សំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិសុវត្ថិភាពអគ្គិភ័យ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពអគ្គិភ័យលើសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១០ ..**

បទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ត្រូវដាក់ឱ្យប្រើប្រាស់ដោយអនុក្រឹត្យតាមសំណើរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់។

បទប្បញ្ញត្តិបច្ចេកទេសសំណង់ដទៃទៀតក្រៅពីបទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលតម្រូវឱ្យអនុវត្តតាមស្តង់ដារណាមួយជាកំណត់ ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យ

ជំពូកទី២២

អវសានប្បញ្ញត្តិ

**មាត្រា១១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា១១១.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃសៅរ៍ ៦កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ២០១៩

ចារស. ១៩១១. ១៦៥៦

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៩៦ អនក្រ.បក

2 5 DEC 1997

# អនុក្រឹត្យ
# ស្តីពី
# លិខិតអនុញ្ញាតសាងសង់

* * * *

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញ ព្រះរាជក្រឹត្យចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ស្តីពីការតែងតាំង នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២
- បានឃើញ ព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត ១០៩៤/ ៨៣ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត ១០៩៤/ ៩០ ចុះថ្ងៃទី ៣១ ខែតុលា ឆ្នាំ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/ រកត/ ០៨៩៧/ ១៨៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០៤ នស ៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ។
- តាមសំណើរបស់ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌និងវិចិត្រសិល្បៈ រៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧

## សំរេច

<u>មាត្រា ១</u> : រាល់រូបវន្តបុគ្គល ឬនីតិបុគ្គល សាធារណៈ ឬឯកជន មានសិទ្ធិសាងសង់អគារលើដីដែលជាកម្មសិទ្ធិរបស់ខ្លួន ហើយសិទ្ធិសាងសង់នេះត្រូវបានទទួលការការពារដោយអនុក្រឹត្យនេះ ។ លិខិតអនុញ្ញាតសាងសង់ដែលត្រូវបានចេញអោយមុនការសាងសង់ ជាគ្រឹះនៃភាពស្របច្បាប់របស់សំណង់ ។ ឯរបៀបសុំលិខិតអនុញ្ញាតសាងសង់មានអធិប្បាយនៅក្នុងវគ្គទី ១ នៃអនុក្រឹត្យនេះ ។

ដើម្បីឱ្យប្រជាពលរដ្ឋ ជាពិសេសប្រជាជនក្រីក្រមានលំនៅដ្ឋានសម្រាប់រស់នៅ រាល់<u>សំណង់តូចតាចធ្វើអំពីឈើ</u> ឬស្លឹក ឬរូបជាតិនានា ពុំទាមទារអោយសុំលិខិតអនុញ្ញាតសាងសង់ឡើយ ស្របតាមបទបញ្ញត្តិដែលមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ។

ដើម្បីធានាសុខមាលភាពនៃសំណង់ និង សុវត្ថិភាពសាធារណៈ ព្រមទាំងដើម្បីការពារបរិស្ថានសាធារណៈ ចាំបាច់ សំរាប់ធានាដល់ដំណើរការរៀបចំទីក្រុង និងតំបន់កសិកម្មបានល្អប្រសើរ បទបញ្ញត្តិទូទៅនៃសំណង់មានកំណត់អំពីសិទ្ធិ និងអំពីករណីយកិច្ចនៃប្រជាពលរដ្ឋ និងស្ថាប័នសាធារណៈ ក្នុងការសាងសង់សំណង់សាធារណៈ និង សំណង់ឯកជន ។

រាល់ការគោរពនូវបទបញ្ញត្តិដែលមានចែងក្នុងវគ្គទី ២នៃអនុក្រឹត្យនេះ នឹងត្រូវបានទទួលលិខិតអនុញ្ញាតសាងសង់ ។

បទបញ្ញត្តិទាំងនេះ ត្រូវយកមកអនុវត្តក្នុងពេលពុំទាន់មានប្លង់ប្រើប្រាស់ដីថ្មី និង ប្លង់គោល អនុម័តដោយរាជរដ្ឋាភិបាល ។

បទបញ្ញត្តិនេះអាចនឹងបំពេញបន្ថែម ដើម្បីឱ្យស្របទៅស្ថានភាពមូលដ្ឋាន ដោយស្ថិតក្នុងបទបញ្ញត្តិសំណង់ជាក់ស្តែងក្នុងប្លង់ប្រើប្រាស់ដីថ្មីរបស់ខេត្ត-ក្រុង ។

អនុក្រឹត្យនេះមិនយកទៅអនុវត្ត លើសំណង់មានស្រាប់ដែលមានការអនុញ្ញាត ។
ចំពោះសំណង់មានស្រាប់ដែលគ្មានការអនុញ្ញាត ហើយដែលប៉ះពាល់យ៉ាងខ្លាំងធ្ងន់ដល់ប្រយោជន៍ ឬសោភ័ណភាពសាធារណៈ ការរុះរើត្រូវសំរេចដោយរាជរដ្ឋាភិបាល ឬតំណាងដែលបានទទួលសិទ្ធិប្រទាន តាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ច ។

# ចំណងជើងទី ១
# លិខិតអនុញ្ញាតសាងសង់ និង លិខិតអនុញ្ញាតរុះរើ
## ជំពូក ១
## ការតម្រូវតិច្ចនៃលិខិតអនុញ្ញាតសាងសង់

មាត្រា ២: **សំណង់ដែលតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ជាមុន**

រាល់ការសាងសង់ក្នុងទីក្រុង និង ទីប្រជុំជន ត្រូវមានលិខិតអនុញ្ញាតសាងសង់

រាល់សំណង់ថ្មី សុទ្ធតែត្រូវមានលិខិតអនុញ្ញាតសាងសង់ ។

ការសាងសង់ឡើងវិញជាថ្មី ការពង្រីក និង ការសង់បន្ថែមពីលើអគារដែលមានស្រាប់ ក៏សុទ្ធតែតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ដែរ ។

ការប្តូរទ្រង់ទ្រាយអគារដែលមានស្រាប់ ត្រូវមានលិខិតអនុញ្ញាតសាងសង់ បើការងារនេះកែប្រែ :

- ការប្រើប្រាស់របស់ផ្នែកអគារ
- ទិដ្ឋភាពនៃអគារ ( Aspect des Bâtiments )
- ការធ្វើបង្គន់អនាម័យ និង ការបន្តភ្ជាប់ទៅបំពង់លូ
- ការធ្វើអាងប្រព្រឹត្តកម្មទឹកកខ្វក់ តភ្ជាប់ទៅបំពង់លូ
- បង្កើនផ្ទៃក្រឡាកម្រាលសំណង់
- កន្លែងទទួលសាធារណៈជន ( Locaux ouverts au public )
- ទំរង់ដី (ចាក់ដីបំពេញ ជីកយកដីចេញ ប្តូរប្រភេទដីស្រែចំការជាដីសាងសង់) ឬ ប៉ះពាល់ខ្លាំងដល់ទិដ្ឋភាពទីឡានណាមួយ ដូចជាលប់បំបាត់បឹង ឬប្រឡាយបង្ហូរទឹក ឬផ្នែកណាមួយនៃប្រព័ន្ធបង្ហូរទឹកចេញ ការកាប់ដើមឈើដែលមានស្រាប់ ។ ល ។

ការសាងសង់ ឬ ការកែទ្រង់ទ្រាយបរិភណ្ឌផ្សេងៗ ដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គីភ័យ (ការដាក់ស៊ីទែនកន្លែងស្តុកប្រេងឥន្ធនៈ រោងជាងដែលមានផលិតផលគ្រឿងផ្ទុះ កន្លែងទទួលសាធារណៈជន) ។ ល ។ ការប្តូរទ្រង់ទ្រាយអគារឧស្សាហកម្ម ការដាក់ផ្លាក ផ្សាយពាណិជ្ជកម្ម ការដាក់អង់តែនទូរទស្សន៍ និងទូរគមនាគមន៍ ផ្ទាំងស្រូបពន្លឺព្រះអាទិត្យ ក៏ដូចជារាល់គ្រឿងដទៃទៀតដែលបំពាក់ទៅនឹងអគារ ហើយស្ថិតនៅជិតមាត់ផ្លូវ ឬ តាំងចំទិសដែលគេអាចមើលឃើញ សាលាក្រុង និង សាលាខេត្តនឹងធ្វើសេចក្តីណែនាំដោយឡែក ។

**មាត្រា ៣: សំណង់ដែលពុំចំណុះក្រោមលិខិតអនុញ្ញាតសាងសង់**

- សំណង់ជាលំនៅឋានប្រជាពលរដ្ឋដែលស្ថិតនៅទីជនបទ ឬតំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និង ឆ្ងាយពីតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភ័ណ្ឌជាតិ តំបន់រក្សាទុកការពារដោយពុំគិតពីទំហំ ឬ សម្ភារៈសំណង់ប្រើប្រាស់ឡើយ ។

- ការជួសជុល និងថែរក្សាទាំងឡាយដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ឬមិត្តភាពសំណង់ លើលែងតែការជួសជុលនោះអាចបណ្តាលអោយប៉ះពាល់ដល់អ្នកជិតខាង ។

បណ្តាសំណង់ដូចខាងក្រោមនេះ ដោយគ្រាន់តែជូនដំណឹងអំពីគំរោងសាងសង់ទៅអាជ្ញាធរមូលដ្ឋាន ដូចតទៅ :

- ទីសក្ការៈបូជា
- សាលាសំណាក់សាធារណៈ
- បណ្តាការដ្ឋសិល្បៈរបស់រដ្ឋសំរាប់សេវាសាធារណៈ ដែលរដ្ឋជាម្ចាស់កិច្ចការ

## ជំពូក ២

## សមត្ថកិច្ច ដែលចេញលិខិតអនុញ្ញាតសាងសង់

**មាត្រា ៤ : សមត្ថកិច្ចរបស់សាលាខេត្ត និង សាលាក្រុង**

៤.១ ខេត្ត-ក្រុង មានសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាតសាងសង់ ក្រោមការទទួលខុសត្រូវរបស់ខ្លួន ។

៤.២ លិខិតអនុញ្ញាតសាងសង់ ត្រូវបានចុះហត្ថលេខាដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុង ឬ ដោយអភិបាលខេត្ត-ក្រុង ឬ អភិបាលរងដែលបានទទួលសិទ្ធិប្រទាន ។ រាល់ការបដិសេធមិនផ្តល់លិខិតអនុញ្ញាតសាងសង់ ត្រូវមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរ នូវមូលហេតុច្បាស់លាស់ ។

**មាត្រា ៥ : សមត្ថកិច្ចរបស់រាជរដ្ឋាភិបាល**

៥.១ មានលិខិតអនុញ្ញាតសាងសង់មួយចំនួន ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលបានសមត្ថកិច្ចសំរេចផ្តល់ លិខិតអនុញ្ញាតសាងសង់ ចំពោះប្រភេទសំណង់ដូចតទៅ :

- បណ្តាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម និង ឧស្សាហកម្ម ដែលមានផ្ទៃក្រឡាក្រាលលើសពី ៣.០០០ ម៉ែត្រទ្វេគុណ ។

- រាល់សណ្ឋាគារ ត្រូវចាត់ទុកជាអគារមានឧបនិស្ស័យខាងពាណិជ្ជកម្ម ។

- បណ្តាអគារសំរាប់ការបង្កបង្កើនផលកសិកម្ម សំរាប់ធ្វើអាជីវកម្មពី ៥០០ម៉ែត្រ ឡើងទៅ ។

- បណ្តាអាកាសយានដ្ឋាន កំពង់ផែ ស្ថានីយអយស្ម័យយាន និង ស្ថានីយរថយន្ត ។

- បណ្តាសំណង់សាធារណៈ និង ឯកជន ដែលមានផ្ទៃក្រឡាក្រាលលើសពី ៣.០០០

ម៉ែត្រទ្រេគុណ និងផ្នែកពង្រីកបន្ថែមដោយគិតទាំងអគារមានស្រាប់ ដែលលើសពី ៣.០០០ ម៉ែត្រទ្រេគុណ ( វប្បធម៌ អប់រំកីឡា រដ្ឋបាល ទេសចរណ៍ សុខាភិបាល ថាមពលទឹក...) ។

- បណ្ដាសំណង់សំខាន់ ៗ ក្នុងទីផ្សារការពារ និងក្នុងក្របខ័ណ្ឌបរិស្ថាន ទេសភាព បេតិកភ័ណ្ឌ ប្រវត្តិសាស្រ្ត បូរាណវត្ថុ និង វប្បធម៌ ។

- ការកែប្រែបណ្ដាអគារ ជាផលប្រយោជន៍បេតិកភ័ណ្ឌដែលបានកំណត់ទុក ។

- បណ្ដាសំណង់លើទីដីក្នុងភាពមើលឃើញទៅវិញទៅមក ជាមួយប្រាង្គប្រាសាទប្រវត្តិសាស្រ្ត។

- បណ្ដាសំណង់ និង ការ្យ សំរាប់ការពារ និង អគារយោធា ។

៥.២ ក្នុងករណីនេះ លិខិតអនុញ្ញាតសាងសង់ ត្រូវចុះហត្ថលេខា ដោយប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និងសំណង់ បន្ទាប់ពីបានទទួលយោបល់ឯកភាពពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ។

## មាត្រា ៦ : គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់របស់សាលាខេត្ត ឬ សាលាក្រុង

៦.១ សមត្ថកិច្ច

អនុលោមតាមមាត្រា ១៨ នៃច្បាប់រៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់មួយ ត្រូវបានបង្កើតឡើងក្នុងពេលពុំទាន់មានប្លង់ប្រើប្រាស់ដី-ធ្លី និង សំណង់ ។ គណៈកម្មការនេះ ត្រូវដឹកនាំដោយប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬ អភិបាលខេត្ត ។

គណៈកម្មការនេះពិនិត្យរាល់សំណុំលិខិតសុំអនុញ្ញាតសាងសង់ ។

ចំពោះលិខិតអនុញ្ញាតសាងសង់ ដែលជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ក្រោយពីគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ ពិនិត្យសំណុំលិខិតហើយ ប្រតិភូរាជរដ្ឋាភិបាលប្រចាំទីក្រុង និង អភិបាលខេត្ត-ក្រុង បញ្ជូនរបាយការណ៍ និង យោបល់ទៅគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ដើម្បីសំរេច ។

៦.២ សមាសភាពរបស់គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ :

គណៈកម្មការមានសមាសភាពដូចតទៅ :

- ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬ អភិបាលខេត្ត ជាប្រធាន
- មន្ទីរ សុរិយោដី សមាជិក
- មន្ទីរ រៀបចំក្រុង និង សំណង់ ឬ ការិយាល័យសំណង់ ក្នុងករណីដែលមាន សមាជិក
- មន្ទីរ សាធារណការ សមាជិក

- មន្ទីរ បរិស្ថាន សមាជិក
- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- តំណាងស្ថាប័នពាក់ព័ន្ធទៅលើគំរោងសំណង់នោះ សមាជិក
- ការិយាល័យ (មូលដ្ឋាន) កិច្ចការនគរោបនីយកម្ម សមាជិក

គណៈកម្មការមានសិទ្ធិកោះអញ្ជើញដើម្បីសាកសួរ ឬស្តាប់រាល់បុគ្គលដែលបានដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ និង ម្ចាស់កម្មសិទ្ធិ បើម្ចាស់កម្មសិទ្ធិនោះពុំមែនជាអ្នកដាក់ពាក្យសុំ នៅពេលដែលសំណុំលិខិតអនុញ្ញាតសាងសង់នោះ បានចុះបញ្ជីជាផ្លូវការរួចហើយ ។

## . ជំពូក ៣

## ការពិនិត្យមើលលើការចេញលិខិតអនុញ្ញាតសាងសង់

មាត្រា ៧ : គ្មានលិខិតអនុញ្ញាតសាងសង់ណាមួយ អាចចេញអោយបានទេ បើលិខិតអនុញ្ញាតសាងសង់នោះពុំគោរពតាមប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី (ក្នុងករណីដែលមានប្លង់ទាំងពីរនេះ) ឬ ប្រសិនបើពុំមានប្លង់ទាំងពីរនេះទេ នោះការអនុញ្ញាត ត្រូវអនុវត្តតាមបទបញ្ជាទូទៅស្តីពីការប្រើប្រាស់ដីធ្លីវិញ ។

ជនទាំងឡាយក្តីជា នីតិបុគ្គល សាធារណៈ ឬ ឯកជន ត្រូវគោរពវិធានការនេះជាចាំបាច់ ។

មាត្រា ៨ : សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ចំពោះក្រុងភ្នំពេញ និង ទីក្រុងដទៃទៀត ត្រូវដាក់នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីររៀបចំក្រុង និង សំណង់) ហើយ ចំពោះខេត្ត ត្រូវដាក់នៅសាលាស្រុក ឬ សាលាខេត្ត (មន្ទីរសំណង់) ។ បង្កាន់ដៃទទួលពាក្យសុំលិខិតអនុញ្ញាតសាងសង់មួយ ត្រូវបានចេញអោយអ្នកសុំ កាលណាសំណុំលិខិតពាក្យសុំមានគ្រប់គ្រាន់ហើយ ។

មាត្រា ៩ : **បណ្តាឯកសារនៃពាក្យសុំលិខិតអនុញ្ញាតសាងសង់**

ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើលើគំរូលិខិតជាផ្លូវការ ហើយត្រូវមានភ្ជាប់សំណុំលិខិត ដែលមានយ៉ាងតិចបំផុតនូវបណ្តាប្លង់ដូចបញ្ជាក់ខាងក្រោមនេះ ជា១០ច្បាប់ បត់ទំហំ (២១×២៩,៧ស.ម) :

៩.១ វិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ អចលនវត្ថុ ឬលិខិតកាន់កាប់ដីជាបណ្តោះអាសន្ន ។

៩.២ សលាកប័ត្រដីឡូតិ៍ :

ប្លង់ដីនេះធ្វើឡើងដោយភ្នាក់ងារមន្ទីរសុរិយោដី ឬ ដោយមេខាគណិតឯកជន ។ ប្លង់នេះ ត្រូវចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយអ្នកធ្វើ និង អនុម័តដោយមន្ទីរសុរិយោដី ។

នៅលើប្លង់នេះមានបញ្ជាក់អំពី :

- ទីតាំងនៃដីឡូតិ៍ដែលជាកម្មវត្ថុនៃពាក្យសុំ ទីតាំងនៃដីឡូតិ៍ដែលនៅជាប់ផ្លូវចូលទៅដីឡូតិ៍នោះ ហើយនិងលក្ខណៈរបស់ផ្លូវនោះ (សាធារណៈ ឬ ឯកជន ឈ្មោះម្ចាស់កម្មសិទ្ធិ) ។
- ឈ្មោះ ឬ លេខ ផ្លូវធំ និង ផ្លូវតូច

- ផ្ទៃក្រឡាដីឡូតិ៍
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូតិ៍ ( ទីតាំង និង កំពស់ )
- បណ្តាសំណង់ដែលមានស្រាប់នៅលើដីឡូតិ៍ជាប់គ្នា ផ្ទៃបាត និងកំពស់របស់វា
- មាត្រដ្ឋានប្លង់រង្វាស់ជ្រុង និងមុំនីមួយៗ ការកំណត់ទិស
- ចំណុចនឹងថ្លស់សំរាប់ជាគោលសំគាល់កំពស់ ដែលបោះនៅលើដីឡូតិ៍
- បន្ទាត់ជួរតម្រង់ផ្លូវសាធារណៈ

៩.៣ ប្លង់ទីតាំងអគារក្នុងដីឡូតិ៍ :

មាត្រដ្ឋាន ១:២០០ (ឬ ១:៥០០ ក្រោយទទួលការយល់ព្រមពីបណ្តាមន្ទីរទទួលបន្ទុកដីឡូតិ៍ធំ ៗ )។

នៅលើប្លង់នេះមានបញ្ជាក់អំពី :

- ការបោះទីតាំងនៃសំណង់ក្នុងដីឡូតិ៍ដែលជាកម្មវត្ថុនៃពាក្យសុំ ដោយមានការបញ្ជាក់អំពីចម្ងាយ រវាងអគារមួយឬច្រើន និង ព្រំប្រទល់ដីឡូតិ៍ ហើយនិងចំងាយទៅបណ្តាអគារនៅជិតខាងដែលមានស្រាប់ ។

- រាល់ការរៀបចំផ្នែកផ្សេងៗ នៃដីទំនេរ ដោយបញ្ជាក់ប្រភេទដីនិងដំណាំមានស្រាប់ និង ទៅអនាគត បណ្តាកន្លែងចតរថយន្ត និងរបង (កំពស់ និង ទីតាំង) ។

- បំពង់លូក្រៅអគារ (រូបធាតុ វិជ្ជមាត្រ ចំណោត កំរិតកំពស់ រណ្តៅពិនិត្យ) រហូតដល់កន្លែងតភ្ជាប់ទៅបណ្តាញសាធារណៈ សំរាប់បញ្ចេញទឹកស្អុយ និងសំរាប់ទឹកស្អាត អាងបង្គន់អនាម័យ អណ្តូង។

- ចំណុចនឹងថ្លស់នៃកំពស់ដីឡូតិ៍ ក្រោយការងាររៀបចំហើយ ។

៩.៤ ប្លង់អគារគ្រប់ជាន់ : មាត្រដ្ឋាន ១ : ១០០

នៅលើប្លង់នេះមានបញ្ជាក់ពី :

- គោលដៅប្រើប្រាស់រាល់បន្ទប់ និង ផ្ទៃក្រឡារបស់វា
- បណ្តាបរិក្ខារអនាម័យ និង កន្លែងដាក់បំពង់លូ
- ចំពោះការរៀបចំទីតាំងឧស្សាហកម្ម : របៀបរៀបចំទីតាំងគ្រឿងយន្ត

៩.៥ ប្លង់ផ្នែកបណ្តាញក្រោមដីនានា និង អាងបង្គន់អនាម័យ មាត្រដ្ឋាន ១ : ១០០

៩.៦ ប្លង់មុខភាពនៃអគារ : (Façades) មាត្រដ្ឋាន ១ : ១០០

នៅលើបណ្តាប្លង់មុខភាពមានបង្ហាញអំពី :

- កំរិតកំពស់កំរាលនីមួយៗ កំរិតកំពស់ដីនៅជើងអគារ ដោយបញ្ជាក់កំរិតកំពស់ដីធម្មជាតិ ដីចាក់បំពេញ ឬ ដីចូកចេញ ។

- កំរិតកំពស់ដំបូល និង ព្រំដំបូល ឬ កំរិតកំពស់នៅពេលសង់ហើយនៃដំបូលតែរ៉ាស់ និង ក្បាំងក្បាលជញ្ជាំង ។

- កំរិតកំពស់សង់ហើយនៃទ្រូងផ្សារ

- រូបធាតុសំរាប់មុខភាព (Matériaux de façade )

៩.៧ ប្លង់ពុះពីរយ៉ាងតិច : មាត្រដ្ឋាន ១ : ១០០

នៅលើប្លង់ពុះមានការបង្ហាញដូចប្លង់មុខភាព ពុះមួយបង្ហាញអាងបង្គន់អនាម័យ ។

៩.៨ តារាងផ្ទៃក្រឡាមួយសំរាប់ជាន់នីមួយៗ

៩.៩ សលាកបត្រពណ៌នាផ្ទៃបាតថ្កាល់ដី និង សន្ទស្សន៍នៃការប្រើប្រាស់ ។

ចំពោះបណ្តាការផ្លាស់ប្តូរទ្រង់ទ្រាយ ពង្រីកទំហំ ពង្រីកតឡើងលើ ប្លង់ត្រូវបង្ហាញរបៀបខុសពីគ្នាចំពោះផ្នែកមានពីមុន ការរុះរើ និង សភាពគ្រោងធ្វើ ។

សាលាក្រុង និង សាលាខេត្តនីមួយៗ ត្រូវចេញសារាចរបញ្ជាក់អំពីខ្លឹមសារចាំបាច់ និង ឯកសារបន្ថែមពាក់ព័ន្ធនឹងសំណុំលិខិតអនុញ្ញាតសាងសង់ ។

អាចអោយអ្នកសុំសាងសង់ផ្តល់បណ្តាលិខិតស្នាមបន្ថែម ដោយមូលហេតុផ្នែកធារាសាស្រ្ត ផ្នែកការពារប្រឆាំងធាតុរំខានគ្រប់ប្រភេទ ផ្នែកសណ្តាប់ធ្នាប់សាធារណៈ ការពារបេតិកភ័ណ្ឌ និង ទេសភាព ។

៩.១០ ក្រោយពីបានទទួលលិខិតអនុញ្ញាតសាងសង់ហើយ ត្រូវមានប្លង់លំអិតគ្រឿងផ្គុំសំណង់ ដែលត្រូវពិនិត្យដោយក្រសួងសាធារណការ និង ដឹកជញ្ជូនមុនបើកការដ្ឋានសាងសង់ ។

មាត្រា ១០ : ភាសាផ្លូវការ

សំណុំលិខិតពាក្យសុំលិខិតអនុញ្ញាតសាងសង់ទាំងអស់ ត្រូវជាភាសាខ្មែរ ។ អត្ថបទជាភាសាអង់គ្លេស ឬ បារាំងអាចផ្តល់ភ្ជាប់ជាមួយនឹងលិខិតនេះ ។

មាត្រា ១១ : ហត្ថលេខាលើពាក្យសុំ

ពាក្យសុំលិខិតអនុញ្ញាតសាងសង់ និងបណ្តាប្លង់ ត្រូវចុះហត្ថលេខាដោយម្ចាស់ដី និងអ្នកធ្វើគំរោង ។

កាលណាអ្នកសុំពុំមែនជាម្ចាស់កម្មសិទ្ធិ អ្នកសុំដែលបានទទួលសិទ្ធិពីម្ចាស់កម្មសិទ្ធិ ក៏ត្រូវចុះហត្ថលេខាលើសំណុំលិខិតពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ដែរ ។

អ្នកធ្វើគំរោងត្រូវតែជាស្ថាបត្យករខ្មែរ ឬបុគ្គលមានការរួមចំណែកជាមួយស្ថាបត្យករខ្មែរ ហើយដែលត្រូវបានទទួលស្គាល់ពីរាជរដ្ឋាភិបាល ស្នើឡើងដោយអាជ្ញាធរមានសមត្ថកិច្ច ឬដោយគណៈស្ថាបត្យករ បន្ទាប់ពីគណៈស្ថាបត្យករខ្មែរនេះ ត្រូវបានបង្កើតឡើង ។

ក្នុងករណីដែលសំណង់មានទំហំលើសពី ៥០០ ម៉ែត្រទ្វេគុណ គំរោងអាចធ្វើបានដោយស្ថាបត្យករតែប៉ុណ្ណោះ ។

មាត្រា ១២ : ការផ្សព្វផ្សាយលិខិតអនុញ្ញាតសាងសង់ និង តវ៉ាសាធារណៈ

អាជ្ញាធរមានសមត្ថកិច្ចផ្សព្វផ្សាយដំណឹងដល់សាធារណៈជន អំពីការដាក់ពាក្យសុំដោយបិទប្រកាសផ្សាយនៅសាលាខ័ណ្ឌ ស្រុក ខេត្ត និងនៅកន្លែង សាងសង់ គម្រោង ។

រាល់បណ្តឹងតវ៉ាពាក់ព័ន្ធការដាក់ពាក្យស្នើសុំ ត្រូវភ្ជាប់សំណុំលិខិត ហើយជូនដំណឹងដល់អ្នកស្នើសុំ ។

ម៉្យាងទៀតចំពោះអគារ និង បណ្តាការ្យធំៗ ឬ ដែលមានប្រភេទអាចធ្វើអោយរំខានដល់សុវត្ថិភាព សុខមាលភាពសាធារណៈនោះ ត្រូវផ្សព្វផ្សាយដល់សាធារណៈជន ពីការដាក់ពាក្យសុំលិខិតអនុញ្ញាតសាងសង់ ដោយវិធីណាមួយផ្សេងទៀត ដែលគេយល់ឃើញថាមានប្រសិទ្ធិភាពជាង ដោយផ្អែកលើមធ្យោបាយផ្សាយពត៌មាន នៅតាមមូលដ្ឋាន ។

ប្រកាសមួយរបស់គណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ កំណត់បញ្ជីអគារ និង ការ្យដែលពាក់ព័ន្ធ ។

រាល់បុគ្គលពាក់ព័ន្ធអាចសាកសួរសុំមើលសំណុំលិខិត នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (មន្ទីររៀបចំក្រុង និង សំណង់ ) ចំពោះក្រុងភ្នំពេញ និងសាលាស្រុក ឬសាលាខេត្ត (មន្ទីរសំណង់)ចំពោះខេត្ត ក្នុងរយៈពេល ២៥ ថ្ងៃ និងអាចធ្វើការតវ៉ា ឬ ទាមទារទៅអាជ្ញាធរមានសមត្ថកិច្ច ។

បណ្តឹងតវ៉ាទាំងនេះត្រូវដាក់បញ្ចូលទៅក្នុងសំណុំលិខិតពាក្យសុំ ។

អាជ្ញាធរមូលដ្ឋានពិនិត្យមើលការជំទាស់ ដែលទទួលបានក្នុងពេលអង្កេត និង ធ្វើរបាយការណ៍មួយ ជូនទៅសាលាខេត្ត សាលាក្រុង ក្នុងរយៈពេល ៥ ថ្ងៃ ។ សាលាខេត្ត សាលាក្រុង ឬ គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) គណៈកម្មការនេះត្រូវសំរេចអំពីសុពលភាពនៃបណ្តឹងតវ៉ា ។

**មាត្រា ១៣ : អង្កេតនៅតាមបណ្តាមន្ទីរមានសមត្ថកិច្ច**

គណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) ឬ ក្នុងករណីផ្សេងទៀត មន្ទីររៀបចំក្រុង និង សំណង់ នៃបណ្តាខេត្ត-ក្រុង ប្រមូលយោបល់ពីមន្ទីរមានសមត្ថកិច្ច ហើយធ្វើសំយោគមួយ ។

យោបល់ និង សំយោគទាំងនោះជាលាយល័ក្ខអក្សរ ត្រូវដាក់ជូនអភិបាលខេត្ត ឬប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងពិនិត្យ និង សំរេច ។

បណ្តាមន្ទីរដែលត្រូវចូលរួមពិភាក្សាជាចាំបាច់ ក្នុងពេលពុំទាន់មានគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់រួមមាន :-

- មន្ទីរសុរិយោដី
- មន្ទីររៀបចំក្រុង និង សំណង់
- មន្ទីរសាធារណៈការ
- មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ
- មន្ទីរហិរញ្ញវត្ថុ
- មន្ទីរបរិស្ថាន
- និងតំណាងស្ថាប័នពាក់ព័ន្ធ

**មាត្រា ១៤ : រយៈពេលពិនិត្យសំណុំលិខិត**

រយៈពេលសំរាប់ពិនិត្យសំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ត្រូវបានកំណត់ត្រឹម ៤៥ ថ្ងៃធ្វើការ ។ រយៈពេលនេះគិតចាប់ពីថ្ងៃ ដែលរាល់លិខិតស្នាមភ្ជាប់ជាមួយនឹងពាក្យសុំលិខិត អនុញ្ញាតសាងសង់បានបំពេញ

សម្លក្រប់ ។ នៅក្នុងរយៈពេលកំណត់នេះ អ្នកស្នើសុំត្រូវបានទទួលដំណឹងអំពីសេចក្ដីសម្រេច ជាលាយល័ក្ខណ៍អក្សរ ស្ដីពីការអនុញ្ញាត ឬ ការមិនអនុញ្ញាត ឬមួយការអនុញ្ញាតដែរ តែស្នើសុំអោយកែសំរួលបន្ថែម ។

ក្នុងករណីគ្មានចម្លើយណាមួយពីអាជ្ញាធរ នោះត្រូវចាត់ទុកបានចម្លើយជាវិជ្ជមាន ។

កាលបរិច្ឆេទថ្ងៃទី ០១ នេះ ត្រូវបានកំណត់ដោយគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ (ប្រសិនបើមាន) ឬ ដោយមន្ទីររៀបចំក្រុង និង សំណង់ក្នុងករណីផ្សេងទៀត ។

បើអាជ្ញាធរមានសមត្ថកិច្ច បានស្នើដល់អ្នកសុំអោយធ្វើការកែប្រែតម្រូវនោះ រយៈពេល ៤៥ ថ្ងៃធ្វើការថ្មីមួយទៀត នឹងត្រូវគិតចាប់ពីថ្ងៃដាក់ពាក្យសុំមានការកែតម្រូវជាផ្លូវការ ។

ការបដិសេធផ្ដល់លិខិតអនុញ្ញាតសាងសង់ និងការស្នើសុំអោយកែសំរួល ត្រូវបានជូនដំណឹងជាលាយល័ក្ខណ៍អក្សរដល់អ្នកសុំ ដោយអាជ្ញាធរមានសមត្ថកិច្ច ។

## ជំពូក ៤

## ទម្រង់បែបបទបន្ទាប់ពីបានលិខិតអនុញ្ញាតសាងសង់

**មាត្រា ១៥ : ការប្រគល់លិខិតអនុញ្ញាតសាងសង់**

លិខិតអនុញ្ញាតសាងសង់ ត្រូវប្រគល់អោយអ្នកសុំដោយអាជ្ញាធរដែលបានអនុញ្ញាតអោយ ។

លិខិតអនុញ្ញាតសាងសង់មួយច្បាប់ អមដោយសំណុំលិខិតគ្រប់សព្វ (ប្លង់ លិខិតស្លាមជាឧបសម្ព័ន្ធ ជាដើម...) ត្រូវរក្សាទុកជាឯកសារដាច់ខាត ដោយសាលាខេត្ត ឬ សាលាក្រុង ។

ក្នុងករណីដែលលិខិតអនុញ្ញាតសាងសង់ ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល នោះគណៈកម្មាធិការជាតិរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ត្រូវរក្សាទុកជាឯកសារ ១ ច្បាប់ផងដែរ ។

**មាត្រា ១៦ : លិខិតអនុញ្ញាតសាងសង់ផុតកំណត់កាល និង ការងាររបោះបង់ចោល**

១៦.១ លិខិតអនុញ្ញាតសាងសង់អស់សុពលភាព បើការងារពុំដំណើរការក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាចេញលិខិតអនុញ្ញាតសាងសង់ ។

លិខិតនេះ អាចអនុញ្ញាតពន្យារពេលបានមួយដង ។

សំណង់ដែលត្រូវចាត់ទុកថាបានចាប់ផ្ដើមសាងសង់ កាលណាជើងគ្រឹះត្រូវបានធ្វើហើយ ។

ចំពោះការសាងសង់បន្ថែមជាន់ ត្រូវចាត់ទុកថាបានចាប់ផ្ដើម កាលណាសសរទីមួយត្រូវបានធ្វើហើយ។

១៦.២ កាលណាការងារសាងសង់ ត្រូវបានផ្អាកលើសពីមួយឆ្នាំ អាជ្ញាធរក្រុង ឬ ខេត្ត អាចបង្ខំអោយធ្វើបញ្ចប់ ឬបង្ខំអោយរុះរើសំណង់ដែលបានចាប់ផ្ដើម និងអោយរៀបចំទីកន្លែងអោយបានត្រឹមត្រូវដូចដើមវិញ ក្នុងរយៈពេលមួយដែលបានកំណត់ និងដោយសោហ៊ុយរបស់ម្ចាស់លិខិតអនុញ្ញាតសាងសង់ ។

## មាត្រា ១៧ : ការចាប់ដំណើរការការដ្ឋាន

ការដ្ឋាន ពុំត្រូវចាប់ដំណើរការមុនពេលបានទទួលលិខិតអនុញ្ញាតសាងសង់ និងមុនពេលទទួលបានការអនុម័ត លើប្លង់លំអិតគ្រឿងផ្គុំសំណង់ឡើយ ។

រាល់សហគ្រិនទទួលបន្ទុកស្ថាបនាសំណង់ ត្រូវបញ្ជាក់អោយដឹងច្បាស់ថា លិខិតអនុញ្ញាតសាងសង់ត្រូវបានអនុញ្ញាតរួចហើយ ពីព្រោះជាប់ទទួលខុសត្រូវរួមជាមួយម្ចាស់សំណង់ ។

អ្នកកាន់លិខិតអនុញ្ញាតសាងសង់ ត្រូវតំកល់ទុកនៅការដ្ឋាន នូវសេចក្តីចម្លងឯកសាររដ្ឋបាលពីការចេញលិខិតអនុញ្ញាតសាងសង់មួយច្បាប់ សំរាប់មន្ទីរ ក្រុង ឬ ខេត្ត ត្រួតពិនិត្យ ។

ប្លង់អនុវត្តការសាងសង់ និង ប្លង់លំអិតសំណង់មួយច្បាប់ ត្រូវតំកល់ទុកជាប្រចាំនៅការដ្ឋាន សំរាប់មន្ទីរ ក្រុង ឬ ខេត្ត ត្រួតពិនិត្យ ។

## មាត្រា ១៨ : ដំណើរការទៅមុខនៃការងារ

១៨.១ ក្រោយពីបានទទួលលិខិតអនុញ្ញាតសាងសង់ និង ប្លង់លំអិតគ្រឿងផ្គុំសំណង់ ហើយម្ចាស់សំណង់ត្រូវជូនដំណឹងទៅសាលាស្រុក-ខ័ណ្ឌ និង ចុះទិដ្ឋាការនៅមន្ទីរមានសមត្ថកិច្ច ។

មុនចាប់ដំណើរការការដ្ឋាន ម្ចាស់សំណង់ត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋាន ពីមន្ទីររៀបចំក្រុង និងសំណង់ ឬការិយាល័យខេត្ត-ក្រុង ។

ស្ថាប័នសមត្ថកិច្ចបច្ចេកទេស ត្រូវតាមដានការអនុវត្តជាដំហាន ៗដូចតទៅ :

- ក្រោយការបោះបង្គោលកំណត់ទីតាំងសំណង់
- ក្រោយការងារផ្នែកគ្រឹះ និងមុនការធ្វើកម្រាលក្រោមនៃជាន់ផ្ទាល់ដី
- នៅទីបញ្ចប់នៃការងធំៗ (គ្រឹះ-សសរ-ជញ្ជាំង-កម្រាល...) ផ្នែកសំខាន់ៗ នៃសំណង់
- នៅពេលតភ្ជាប់ទៅបណ្តាញលូទឹកស្អុយ ទឹកស្អាត និង បណ្តាញអគ្គីសនី

១៨.២ រាល់ការផ្លាស់ប្តូរម្ចាស់សំណង់ ក្នុងពេលកំពុងដំណើរការសាងសង់ ត្រូវជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច ។

## មាត្រា ១៩ : ការរៀបចំការដ្ឋានសំណង់

ការដាក់គរសំភារៈសំណង់លើផ្លូវសាធារណៈត្រូវហាមឃាត់ :

- កាលណាសំណង់ ត្រូវការកន្លែងតាំងការដ្ឋានលយទៅលើផ្លូវសាធារណៈ កន្លែងលយនោះត្រូវកំណត់ត្រឹម ២ម ទៅលើចិញ្ចើមផ្លូវ ។ កន្លែងនោះត្រូវធ្វើរបងហ៊ុំព័ទ្ធ ក្នុងរយៈពេលដំណើការរបស់ការដ្ឋាន ។

- រាល់កន្លែងតាំងការដ្ឋាន ត្រូវរុះរើចេញក្នុងរយៈពេលមួយសប្តាហ៍ ក្រោយពេលចប់ការដ្ឋាន។

- ជំនរសំភារៈ កាកសំណល់បានមកពីការរុះរើ ឬពីការសាងសង់ ឬការជួសជុលត្រូវយកចេញក្នុងរយៈពេលមួយសប្តាហ៍ ក្រោយពេលចប់ការងារ ។

ក្នុងករណីពុំបានបើយកសំភារៈកាកសំណល់ចេញពីកន្លែងតាំងការដ្ឋានទេ សាលាខណ្ឌ ឬ សាលាស្រុកមានភារកិច្ច កាត់តែងមីកជញ្ជូនចេញដោយស្វ័យប្រវត្តិ ។ ចំណាយជាបន្ទុករបស់ម្ចាស់សំណង់ ។

<u>មាត្រា ២០</u> : ការត្រួតពិនិត្យ និង ការបញ្ឈប់ការងារ

អាជ្ញាធរក្រុង ឬ ខេត្ត អាចចូលមើលនិងត្រួតពិនិត្យការដ្ឋានគ្រប់ពេលវេលា ហើយនិងពិនិត្យប្លង់ដែលបានអនុម័តរួច ។ បើពិនិត្យឃើញភាពមិនត្រឹមត្រូវ អាជ្ញាធរនោះជំរាបជាលាយល័ក្ខណ៍អក្សរទៅម្ចាស់សំណង់ អោយកែតម្រូវក្នុងរយៈពេលកំណត់មួយ ។

ក្នុងករណីពុំបានអនុវត្ត ឬ បានអនុវត្តពុំត្រឹមត្រូវតាមបញ្ជា ការផ្អាកការងារត្រូវចេញបញ្ជាជាបន្ទាន់ ដោយអាជ្ញាធរ ក្រុង ឬ ខេត្ត ។

សាលាក្រុង ឬ សាលាខេត្ត អាចប្តឹងទៅតុលាការមានសមត្ថកិច្ចអោយចេញដីការកិច្ចការប្រញាប់ អោយផ្អាកការសាងសង់ ឬ ផ្លាស់ប្តូរទ្រង់ទ្រាយសំណង់ដែលពុំត្រឹមត្រូវ ឬផ្ទុនច្បាប់នោះ ។ ចំណាយជាបន្ទុករបស់ម្ចាស់សំណង់ ។

អនុលោមទៅតាមសភាពធ្ងន់ធ្ងរនៃការខុសឆ្គង បណ្តាសំភារៈនិងឧបសំភារៈរបស់ការដ្ឋាន អាចត្រូវរឹបអូសតាមបង្គាប់តុលាការ ។

<u>មាត្រា ២១</u> : វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវ

អ្នកសុំលិខិតអនុញ្ញាតសាងសង់ ត្រូវប្រកាសប្រាប់អំពីការចប់ការងារ ដល់សាលាខណ្ឌ ឬសាលាស្រុក។

ពេលបញ្ចប់ការដ្ឋាន សាលាខណ្ឌ ឬសាលាស្រុកជាមួយនិងការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ (បន្ទីរ រៀបចំក្រុង និង សំណង់) អាចត្រួតពិនិត្យភាពត្រឹមត្រូវស្របគ្នា រវាងសំណង់ដែលធ្វើរួចហើយ និង លិខិតអនុញ្ញាតសាងសង់ដែលបានចេញអោយ ។

ត្រូវចាត់ទុកថាពុំត្រឹមត្រូវ បើផ្ទៃបាតសំណង់ ឬ ផ្ទៃក្រឡាកម្រាលបានសាងសង់ លើសពីលិខិតអនុញ្ញាត។

អាចចាត់ទុកថាពុំត្រឹមត្រូវ បើរូបភាពនៃអគារមានភាពងាយឃើញខុសគ្នា ពីលិខិតអនុញ្ញាតសាងសង់ដែលបានចេញអោយ ។

ក្នុងករណីពុំត្រឹមត្រូវទេ អាជ្ញាធរក្រុង ឬ ខេត្តអាចបង្ខំម្ចាស់សំណង់ អោយកែតម្រូវអគារអោយបានត្រឹមត្រូវ ស្របគ្នានឹងលិខិតអនុញ្ញាតសាងសង់ដែលបានចេញអោយ ។

ក្នុងករណីមិនគោរពតាមទេ សាលាក្រុង ឬសាលាខេត្ត ត្រូវប្តឹងទៅតុលាការមានសមត្ថកិច្ច អោយចេញសាលក្រម ឬ សាលដីកា ។

វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវមួយ ដែលចេញអោយដោយអាជ្ញាធរក្រុង ឬ ខេត្ត ត្រូវតែមានជាចាំបាច់ជានិច្ច ចំពោះបណ្តាអគារសំរាប់ទទួលសាធារណៈជន សណ្ឋាគារ ការិយាល័យ ក៏ដូចជាចំពោះបណ្តាកន្លែងធ្វើការរបស់អ្នកមានបៀវត្ស ។ វិញ្ញាបនប័ត្រនេះ ត្រូវបានទទួលមុនការបើកប្រើប្រាស់កន្លែងធ្វើការនោះ ។

វិញ្ញាបនប័ត្របញ្ជាក់ភាពត្រឹមត្រូវមួយ ចេញអោយដោយអាជ្ញាធរក្រុង ឬ ខេត្ត ត្រូវតែមានជាចាំបាច់ខានពុំបាន មុនពេលបើកអោយប្រើប្រាស់ ចំពោះបណ្តាអគារដែលសាងសង់នៅក្នុងរមណីយដ្ឋាន និងទេសភាពធម្មជាតិ ឬ ក្រុង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ បុរាណសាស្ត្រ បេតិកភ័ណ្ឌ ឬនៅកន្លែងមើលឃើញទៅវិញទៅមក ជាមួយប្រាង្គប្រាសាទប្រវត្តិសាស្ត្រណាមួយ ។

## ជំពូក ៥
## លិខិតអនុញ្ញាតរុះរើ

<u>មាត្រា ២២</u> : រាល់ម្ចាស់កម្មសិទ្ធិ ឬ អ្នកទទួលសិទ្ធិតំណាងក្នុងអាណត្តិ ដែលមានបំណងរុះរើអគារណាមួយដែលមានស្រាប់ ក្រៅពីសំណង់បណ្តោះអាសន្នមិនឋិតថេរ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតរុះរើ នៅការិយាល័យសុំលិខិតអនុញ្ញាតសាងសង់ ។

សំណុំពាក្យសុំលិខិតអនុញ្ញាតរុះរើត្រូវមាន :

ប្លង់ដីឡូត៍ និង ប្លង់អគារ រូបថតអគារ ឬឯកសារផ្សេង ៗ ទៀតដែលចាំបាច់ ។

ចំពោះរាល់អគារដែលមានចុះក្នុងបញ្ជីបេតិកភ័ណ្ឌ ពាក្យសុំអនុញ្ញាតរុះរើ ត្រូវឆ្លងតាមគណៈកម្មការចេញលិខិតអនុញ្ញាតសាងសង់ ហើយត្រូវបានអនុញ្ញាតដោយអភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ។

លិខិតអនុញ្ញាតរុះរើ ត្រូវផ្សព្វផ្សាយភ្លាមជាសាធារណៈ ដោយការបិតប្រកាសនៅកន្លែងដែលអាចមើលឃើញពីផ្លូវសាធារណៈ នៅកន្លែងគ្រោងធ្វើការរុះរើ ។ ការងាររុះរើ ពុំអាចចាប់ផ្តើមក្នុងរយៈពេលតិចជាង ១៥ ថ្ងៃ បន្ទាប់ពីការចេញលិខិតអនុញ្ញាតឡើយ ។

លិខិតអនុញ្ញាតរុះរើ ត្រូវចាត់ទុកយល់ព្រម បើពុំមានចំឡើយណាមួយក្រោយពីថ្ងៃដាក់ពាក្យសុំ ៣ខែ ។

រាល់ជំទាស់ ត្រូវផ្តល់ដំណឹងទៅអ្នកសុំជាលាយលក្ខណ៍អក្សរ ។

<u>មាត្រា ២៣</u> : បណ្តាបទបញ្ញត្តិពីសមត្ថកិច្ច និង ការពិនិត្យពាក្យសុំដែលអនុវត្តចំពោះលិខិតអនុញ្ញាតសាងសង់ ត្រូវអនុវត្តបានដូចគ្នាចំពោះពាក្យសុំលិខិតអនុញ្ញាតរុះរើ ។

## ជំពូក ៦
## បទល្មើស និង បណ្តឹងតវ៉ា

<u>មាត្រា ២៤</u> : **ករណីបទល្មើស**

រាល់សំណង់ ដែលបានចាប់ផ្តើមដំណើរមុនចេញលិខិតអនុញ្ញាតសាងសង់ ដោយអាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់ទុកជាល្មើសច្បាប់ ។ ការដ្ឋានត្រូវបញ្ឈប់ជាបន្ទាន់ ។

បណ្តាបុគ្គល ដែលបានប្រព្រឹត្តល្មើសនឹងបញ្ជារបស់មន្ត្រី និង ភ្នាក់ងាររបស់រាជការ ត្រូវជាប់ទោស ហើយឧបករណ៍ទាំងឡាយនៅក្នុងការដ្ឋានត្រូវរឹបអូស ។ ក្នុងករណីមិនរាងចាល ត្រូវពិន័យជាបទលហុ ។ បើពុំព្រមបញ្ឈប់ការងារ ត្រូវបញ្ជូនជនល្មើសទៅតុលាការ ដែលត្រូវវិនិច្ឆ័យតាមច្បាប់ជាធរមាន ។

<u>មាត្រា ២៥</u> : **បណ្តឹងតវ៉ា**

រាល់សេចក្តីសំរេចទាក់ទងនឹងពាក្យសុំលិខិតអនុញ្ញាតសាងសង់ មុនឡើងទៅតុលាការមានសមត្ថកិច្ច អាចជាកម្មវត្ថុនៃបណ្តឹងតវ៉ា ទៅអាជ្ញាធរមានសមត្ថកិច្ច ដូចបានបញ្ជាក់ក្នុងមាត្រា ៤ និង ៥ នៃអនុក្រឹត្យនេះ ដើម្បីធ្វើការពិនិត្យលើបណ្តឹងតវ៉ានេះ ។

អាជ្ញាធរមានសមត្ថកិច្ច មាននីតិសម្បទាសំរបសំរួលជាមួយម្ចាស់បណ្តឹង ។ ក្នុងករណីមិនបានសំរេច អ្នកប្តឹងអាចតវ៉ា ទៅដល់ប្រធានគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ បើអាជ្ញាធរមានសមត្ថកិច្ចជាអភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ឬនឹងទៅដល់នាយករដ្ឋមន្ត្រី បើអាជ្ញាធរមានសមត្ថកិច្ច ជា តំណាងរាជរដ្ឋាភិបាល ។

សំរាប់កិច្ចការនេះ ត្រូវបានបង្កើតផ្នែកវិវាទមួយនៅគ្រប់សាលាខេត្ត ឬសាលាក្រុង និងក្នុងគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ។

## ខណ្ឌទី ២

## <u>បទបញ្ញត្តនៅនៃការប្រើប្រាស់ដី-ធ្លី</u>

<u>មាត្រា ២៦</u> : បទបញ្ញាទូទៅនៃការប្រើប្រាស់ដី-ធ្លីនេះ ត្រូវយកមកអនុវត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ហើយតំរូវអោយរាល់បុគ្គលសាធារណៈ និង ឯកជន ជារូបវន្តបុគ្គលក្តី ឬ នីតិបុគ្គលក្តី គោរពប្រតិបត្តិតាមលិខិតអនុញ្ញាតសាងសង់ ក្នុងរយៈពេលដែលពុំទាន់មានប្លង់ប្រើប្រាស់ដី-ធ្លី និង ប្លង់គោលនៅឡើយនោះ ។

### ជំពូក ១

### ប្រភេទ ការកំណត់ទីតាំង និង ផ្លូវចាក់ចេញចូលរបស់ទីតាំងសំណង់

<u>មាត្រា ២៧</u> : **សុវត្ថិភាព និង សុខមាលភាពសាធារណៈ**

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះសំណង់ទាំងឡាយណាដែលទីតាំង ប្រភេទ ឬ ទំហំ មានលក្ខណៈនាំអោយប៉ះពាល់ដល់សុខមាលភាព ឬ ដល់សុវត្ថិភាពសាធារណៈ នាំអោយរំខាន ឬ បណ្តាលអោយមានមហន្តរាយ ។

២៧.១ ទីដីគ្រោះថ្នាក់ ( ទីដីដែលអាចមានគ្រោះថ្នាក់ )

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះទីដីដែលអាចមានមហន្តរាយ ៖ តំបន់ជាប់ស្រុតឈើ តំបន់ដីសើមដែលត្រូវការពារ តាមមាត់ច្រាំង ទន្លេ ព្រែក ស្ទឹង បឹងបួរ ដែលពុំមានភាពរឹងមាំគ្រប់គ្រាន់

ហើយអាចបណ្តាលអោយមានគ្រោះថ្នាក់ ចំពោះសុវត្ថិភាពរបស់មនុស្ស និងសម្បត្តិទ្រព្យ លើកលែងតែភូមិដ្ឋាន ទាំងនោះបានអនុម័តតាមប្លង់គោល ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះដីអាចលិចទឹក កាលណាសំណង់នោះស្ថិតតាមមាត់ច្រាំងទន្លេ លើព្រែក ស្ទឹង ឬបឹង បណ្តាលអោយថយចុះលទ្ធភាពរក្សាទឹកទុក ឬ លទ្ធភាពបង្ហូរទឹកពីទីដីនោះ និង ទីដីជិតខាង និងប៉ះពាល់ដល់គុណភាពទឹក ។

២៧.២ ធាតុរំខានដោយសម្លេង

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ឬអាចអនុញ្ញាតអោយតែក្នុងករណីក្រោមបញ្ញត្តិពិសេស បើសំណង់នោះអាចត្រូវទទួលរងធាតុរំខានដោយសំលេងខ្លាំង ៗ ឬ បើសំណង់នោះអាចបង្កធាតុរំខានដោយសំលេងខ្លាំង ៗ ។

មាត្រា ២៨ : **ការការពាររមណីយដ្ឋាន**

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់នោះមានប្រភេទ ទំហំ ឬ ទីតាំង អាចបណ្តាលអោយអន្តរាយដល់ការអភិរក្ស ឬ អន្តរាយដល់ការលើកតំលៃនៃរមណីយដ្ឋានធម្មជាតិ ឬក្រុង ឬ កេរ្តិ៍ដំណែលប្រវត្តិសាស្ត្រ និងបុរាណវត្ថុ ឬ អាចអនុញ្ញាតអោយតែក្នុងករណីក្រោមបញ្ញត្តិពិសេស ។

មាត្រា ២៩ : **បណ្តាញផ្លូវទាក់ព័ន្ធ និង ចំណត**

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ ចំពោះដីដែលពុំមានផ្លូវចេញ-ចូល ដូចជា : ផ្លូវសាធារណៈ ផ្លូវឯកជន ច្រកផ្លូវ ឬ ផ្លូវឆ្លងកាត់ ដែលទទឹងត្រូវសមាមាត្រសមស្របទៅនឹងទំហំ និង ការប្រើប្រាស់នៃអគារ ។

រាល់ផ្លូវ ផ្លូវឆ្លងកាត់ ច្រកផ្លូវ សំរាប់ប្រើប្រាស់ចំពោះសំណង់មួយ ឬ ច្រើន ពុំអាចមានទទឹងតិចជាង ៣,៥០ម ដែលជាទំហំចាំបាច់សំរាប់អោយរថយន្តពន្លត់អគ្គីភ័យចូលបាន ។

ចំណតរថយន្ត ត្រូវមានគ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់អគារ ហើយត្រូវស្ថិតនៅក្រៅពីផ្លូវសាធារណៈ។

បទដ្ឋានចំណតរថយន្តត្រូវបានកំណត់ដោយបណ្ណាសាលាក្រុង និងសាលាខេត្ត ប៉ុន្តែពុំអាចតិចជាង :

- ចំពោះសណ្ឋាគារ :
  . ចំណតរថយន្តតូច ១កន្លែង សំរាប់ ៥ បន្ទប់
  . ចំណតរថយន្តធំ ១កន្លែង សំរាប់ ៣០ បន្ទប់
- ចំពោះការិយាល័យឯកជន និង រដ្ឋបាលសាធារណៈ:
  . ចំណតរថយន្ត ១កន្លែង សំរាប់ផ្ទៃក្រឡាកម្រាលសរុបទំហំ ២៥០ម៉ែត្រទ្វេគុណ

- ចំពោះបណ្តាសកម្មភាព ឧស្សាហកម្ម សិប្បកម្ម និងឃ្លាំងស្តុកទំនិញ ចំនួនចំណតរថយន្តត្រូវមានគ្រប់គ្រាន់សំរាប់ការលើកដាក់ ផ្ទុក និង ផ្ទេរទំនិញនៅក្រៅពីផ្លូវសាធារណៈ និងចំណតរថយន្តគ្រប់ប្រភេទនៅក្នុងបរិវេណដីឡូត៍ ។

**មាត្រា ៣០: ការបោះទីតាំងសំណង់ តាមបងផ្លូវសាធារណៈ**

៣០.១ ការបោះទីតាំងសំណង់នៅតាមបងផ្លូវជាតិ និង ផ្លូវទំនប់ព័ទ្ធជុំវិញទីក្រុង អភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងនានា និង រាជធានីភ្នំពេញ ត្រូវកំណត់ដោយមានការយល់ព្រម ពីគណៈកម្មាធិការជាតិរៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ ទូរពីចំណីសាធារណៈ និងច្បាតម្ចាតនៃផ្លូវជាតិ ផ្លូវសំខាន់ៗដែលពាក់ព័ន្ធនឹងការរៀបចំទីក្រុង និង នគរូបនីយកម្ម ជាអាទិផ្លូវទំនប់ ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ នៅក្នុងតំបន់ដែលបានរៀបរាប់ខាងលើ ។

៣០.២ ការបោះទីតាំងសំណង់ នៅតាមបងផ្លូវសាធារណៈក្នុងក្រុង

សំណង់ទាំងឡាយ ត្រូវបោះទីតាំងលើជួរតម្រង់ផ្លូវសាធារណៈ ឬឃ្លាតឆ្ងាយពីជួរតម្រង់យ៉ាងតិច ៤ម ។

នៅតាមច្រកផ្លូវ បណ្តាសំណង់អាចបោះទីតាំងលើជួរតម្រង់ផ្លូវច្រក ។

អភិបាលខេត្ត ឬ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុងនានា និង រាជធានីភ្នំពេញ កំណត់ជួរតម្រង់នៃផ្លូវសាធារណៈ និង ច្បាតម្ចាតលើប្លង់មួយហៅថា ប្លង់ជួរតម្រង់ ។ ប្លង់ជួរតម្រង់នេះ ត្រូវទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ចំពោះក្រុងទាំងឡាយណាដែលមានប្រជាជនលើសពី ២០.០០០នាក់ ។ ប្លង់ទាំងនោះ ត្រូវផ្សព្វផ្សាយអោយសាធារណៈជនបានដឹង ។

**មាត្រា ៣១ : ការផ្គត់ផ្គង់ទឹកស្អាត និង ការបញ្ចេញចោលទឹកកខ្វក់**

៣១.១ ការផ្គត់ផ្គង់ទឹកស្អាត ត្រូវធានាអោយបានចំពោះរាល់សំណង់ ដែលតំរូវអោយមានលិខិតអនុញ្ញាតសាងសង់ ។

ក្នុងករណីដែលបណ្តាញទឹកស្អាត ពុំផ្គត់ផ្គង់អោយទៅដល់ដីដែលនៅលើទីដីនោះ មានសំណង់មួយត្រូវបានគ្រោងទុកនោះ អ្នកស្នើសុំត្រូវបង្ហាញភស្តុតាងថា ខ្លួនអាចនឹងផ្គត់ផ្គង់ទឹកស្អាតក្នុងបរិមាណគ្រប់គ្រាន់ដល់អគាររបស់ខ្លួន និងបញ្ជាក់ថាតាមមធ្យោបាយអ្វី ទោះបីតាមការបន្តភ្ជាប់ទៅនឹងបណ្តាញទឹកស្អាតណាមួយដែលនៅជិត ឬជាអណ្តូងទឹកដែលមានស្រាប់នៅជិតនោះ ឬដែលត្រូវជីកថ្មីក្តី ។

អ្នកស្នើសុំត្រូវបញ្ជាក់អំពីលក្ខណៈបច្ចេកទេសរបស់អណ្តូង និងគុណភាពទឹក ។ ក្នុងករណីការប្រើប្រាស់អណ្តូងសមូហភាព សំណុំលិខិតនៃលិខិតអនុញ្ញាតសាងសង់ ត្រូវមានសេចក្តីយល់ព្រមឱ្យប្រើប្រាស់ទឹកជាលាយលក្ខណ៍អក្សរ ។

៣១.២ បណ្តាឌីឡូតិ៍ ឬសំណុំលំនៅដ្ឋាន ត្រូវតែមានការផ្គត់ផ្គង់ដោយបណ្តាញចែកចាយទឹកស្អាត និងមានប្រព័ន្ធលូទឹកស្អុយ ដែលនាំបង្ហូរចេញដល់ទីដៅតែម្តង ដោយគ្មានកន្លែងណាមួយអាចអោយទឹកស្អុយដក់នៅបាន ។

៣១.៣ – ក្នុងករណីគ្មានប្រព័ន្ធលូទឹកស្អុយ ម្ចាស់សំណង់មានកាតព្វកិច្ចត្រូវគ្រោងសំអាត និងបញ្ចេញទឹកដែលប្រើប្រាស់ហើយទៅទីធម្មជាតិ តាមរយៈអាងបង្គន់អនាម័យ និងបណ្តាញបំពង់មានប្រហោងរាយកប់ក្នុងដី ។

បណ្តាញនេះបែងចែកទឹកដែលចេញពីបង្គន់អនាម័យ នៅក្រោមដីធ្វើអោយជ្រាប និង ជម្រះបាន ។

ម្ចាស់កម្មសិទ្ធនៅក្នុងក្រុង ចាំបាច់ត្រូវធ្វើអាងបង្គន់អនាម័យ ហើយបន្តភ្ជាប់ទៅប្រព័ន្ធលូ ។

បទដ្ឋានអាងបង្គន់អនាម័យ កំណត់ដូចតទៅ :

ទំហំប្រើប្រាស់នៃអាងបង្គន់អនាម័យ ដោយគិតពីបាតអាងឡើងមកដល់បំពង់បង្ហូរចេញ :

- ជាអប្បបរមា ៣ម៉ែត្រគ្រីគុណសំរាប់លំនៅដ្ឋានមួយ ឬ ៣ម៉ែត្រគ្រីគុណក្នុងមួយជាន់នៃផ្ទះល្វែង ឬនៃភូមិគ្រឹះ ឬ ៣ម៉ែត្រគ្រីគុណសំរាប់ផ្ទៃក្រឡាកំរាលសរុបទំហំ ៨០ម៉ែត្រទ្វេគុណ ។

ចំពោះសណ្ឋាគារ ២ ម៉ែត្រគ្រីគុណ បូកបន្ថែម ០,៥ម៉ែត្រគ្រីគុណក្នុងមួយបន្ទប់ :

- កំពស់អាងបង្គន់អនាម័យពុំអាចទាបជាង ១,៥០ម ។

- អាងបង្គន់អនាម័យត្រូវមានរន្ធបង្ហុយបន្តខ្ពស់ទៅលើ ។

- មិនត្រូវអោយទឹកភ្លៀងហូរចូលទៅក្នុងអាងបង្គន់អនាម័យជាដាច់ខាត ។

៣១.៤ – សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ត្រូវមានគំនូរអាងបង្គន់អនាម័យ និង ប្រព័ន្ធបន្តភ្ជាប់ទៅលូបង្ហូរទឹកស្អុយ ។

លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើពុំបង្ហាញការធានាគ្រប់គ្រាន់អំពីអនាម័យ និងសុខមាលភាពចំពោះសំណង់ដែលបានគ្រោង និងបណ្តាសំណង់នៅជុំវិញដែលមានស្រាប់ ។

<u>មាត្រា ៣២</u> : **តំបន់មិនអាចសាងសង់បាន**

ខេត្ត និង ក្រុង នីមួយៗ ត្រូវកំណត់ជាបន្ទាន់នូវប្លង់តំបន់មិនអាចសាងសង់បាន ។

ប្លង់នេះ ត្រូវមានបញ្ចូលតំបន់ការពារធម្មជាតិ តំបន់កសិកម្ម តំបន់ព្រៃឈើ និង ដី ដែលជាគោលដៅប្រើប្រាស់ពុំអាចផ្លាស់ប្តូរបានដោយមូលហេតុផលប្រយោជន៍សេដ្ឋកិច្ច និង បរិស្ថាន ។

ប្លង់នេះ ត្រូវមានបញ្ចូលរមណីយដ្ឋានធម្មជាតិ ដូចជា ឆ្នេរសមុទ្រ មាត់ទន្លេ ព្រែក ស្ទឹង បឹងបួរ ដោយមូលហេតុផលប្រយោជន៍បេតិកភ័ណ្ឌ និង បរិស្ថាន ។

ប្លង់នេះ ត្រូវមានបញ្ចូលគ្រប់តំបន់អាចលិចទឹក ដែលត្រូវការពារដោយមូលហេតុជាផលប្រយោជន៍ សំរាប់បង្ហូរទឹកភ្លៀងចេញ និង ការប្រយុទ្ធប្រឆាំងនឹងទឹកជំនន់ ។

អាជ្ញាធរដែនដីមូលដ្ឋានត្រូវចាត់វិធានការសមស្រប ដើម្បីការពារ និងបង្កើនគុណសម្បត្តិតំបន់មិនអាចសាងសង់បានទាំងនោះ ។

រាល់លិខិតអនុញ្ញាតសាងសង់ មិនផ្តល់ជូនឡើយក្នុងតំបន់ទាំងនោះ ។

ក្នុងករណីមានការសាងសង់ដោយល្មើសច្បាប់ ក្នុងតំបន់ហាមឃាត់ទាំងនេះ អាជ្ញាធរដែនដីត្រូវបង្ខំឱ្យជនល្មើសរុះរើដោយខ្លួនឯង ហើយធ្វើអោយកន្លែងនោះមានសភាពដូចដើមវិញ ក្នុងរយៈកាលមួយកំណត់ ។

ក្នុងករណីមិនអនុវត្តតាមការកំណត់ អាជ្ញាធរដែនដីត្រូវធ្វើការផាកពិន័យ និង ចាត់អោយរុះរើ និងធ្វើអោយកន្លែងនោះមានសភាពដូចដើមវិញ ដោយចាប់បង្ខំអោយអ្នកល្មើសច្បាប់ ត្រូវតែចេញសោហ៊ុយចំណាយទាំងអស់នោះ ឬ ក្នុងករណីចាំបាច់ អាជ្ញាធរមូលដ្ឋានត្រូវប្តឹងទៅតុលាការ ដើម្បីអោយចេញដីការកិច្ចការប្រញាប់បញ្ជាអោយរុះរើ ។

ប្លង់នេះ ត្រូវទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ និងត្រូវផ្សព្វផ្សាយជាសាធារណៈដល់មន្ត្រីរាជការ ផ្នែករាជ្ញាធរដែនដីមូលដ្ឋាន និងមន្ត្រីជំនាញទទួលខុសត្រូវលើ << តំបន់មិនអាចសាងសង់បាន >> ដែលពុំបានចាត់វិធានការចាំបាច់ ដើម្បីអោយមានការគោរពតំបន់ទាំងនោះទេ ត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់ជាធរមាន ។

## មាត្រា ៣៣ : ផលប៉ះពាល់ពីសំណង់ឧស្សាហកម្ម

សំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់សំណង់ឧស្សាហកម្ម ត្រូវបញ្ជាក់អំពីការបំពុលបណ្តាលមកពីសកម្មភាពឧស្សហកម្ម និងវិធីដែលបានគ្រោងទុក ដើម្បីលុបបំបាត់ការបំពុលទាំងនោះ ។

គំរោងស្ថានីយសំរាប់ធ្វើសំអាតតាមយថាប្រភេទ ត្រូវមានបញ្ចូលក្នុងសំណុំលិខិតសុំលិខិតអនុញ្ញាតសាងសង់ ។

រាល់កាកសំណល់ពីឧស្សាហកម្ម ត្រូវតែបានទទួលការសំអាតជាមុន ដើម្បីបង្ការកុំអោយប៉ះពាល់ដល់សណ្តាប់ធ្នាប់ ឬ សុខភាពសាធារណៈ ។ ទឹកកខ្វក់សំណល់ឧស្សាហកម្ម ពុំត្រូវឱ្យលាយឡំជាមួយទឹកភ្លៀង និងជាមួយទឹកកខ្វក់ដទៃទៀត ហើយក៏ពុំត្រូវបង្ហូរចូលត្រង់ៗទៅកន្លែងធម្មជាតិ ដោយពុំបានធ្វើការសំអាតជាមុនឡើយ ។

ចម្ងាយអប្បបរមា ដែលត្រូវគោរពរវាងសំណង់ឧស្សាហកម្មមួយដែលមានធាតុកខ្វក់ និង លំនៅដ្ឋាននៅជិតបំផុត ត្រូវបានរដ្ឋអំណាចមូលដ្ឋានអនុវត្ត ស្របទៅតាមការណែនាំផ្ទាល់របស់រាជរដ្ឋាភិបាល ។

ចំពោះឃ្លាំងស្តុកឧបទ្ទវ និង អាងប្រេងឥន្ធនៈទាំងឡាយ ត្រូវគោរពបទបញ្ញត្តិអន្តរជាតិ អនុម័តដោយរាជរដ្ឋាភិបាល ។

រាល់អំពើល្មើសនឹងបណ្តាបទបញ្ញត្តិខាងលើនេះ រដ្ឋអំណាចមូលដ្ឋានអាចបញ្ឈប់សកម្មភាពជាបន្ទាន់ ហើយត្រូវរាយការណ៍ជូនស្ថាប័នជំនាញ ។ រដ្ឋអំណាច ត្រូវជូនដំណឹងតាមផ្លូវច្បាប់ដល់ម្ចាស់សំណង់ នូវបណ្តាបទបញ្ញត្តិដែលត្រូវគោរពតាម ។

## ជំពូក ២

## ការបោះទីតាំង និង ទំនាក់ទំនាក់

### មាត្រា ៣៤ : ការបោះទីតាំងធៀបនឹងព្រំដីឡូត៍ជិតខាង

ធៀបនឹងព្រំដីឡូត៍ សំណង់ទាំងឡាយនឹងត្រូវសាងសង់ ឬមួយនៅជាប់នឹងព្រំ ឬមួយជាជញ្ជាំងអឌ្ឍសិទ្ធិ ឬមួយនៅចម្ងាយអប្បបរមា ២ម ពីព្រំ ។ ចន្លោះ ២ម នេះ ត្រូវទុកអោយនៅទំនេរពុំមានសំណង់អ្វីឡើយ ។

ហាមមិនអោយចោះទ្វារ ឬ បង្អួច នៅលើជញ្ជាំងអឌ្ឍសិទ្ធិ ឬជញ្ជាំងជាប់ព្រំ ។

ចំពោះសំណង់ជាប់ព្រំ ឬ សំណង់ជាជញ្ជាំងអឌ្ឍសិទ្ធិ នឹងមានកំណត់ក្នុងសេចក្តីណែនាំអនុវត្ត របស់គណៈ-កម្មាធិការជាតិរៀបចំទឹកដី នគរោបនីយកម្ម និង សំណង់ តាមសំណើរបស់ខេត្ត-ក្រុង ។

ត្រូវបានចាត់ទុកថាជាបន្ទប់រស់នៅ រាល់បន្ទប់ទាំងអស់លើកលែងតែផ្ទះបាយ បន្ទប់អនាម័យ បន្ទប់សេវាផ្សេងៗ និង ចន្លោះដើរក្នុងអគារ ។ បទបញ្ញត្តិនេះ ត្រូវដាក់អោយអនុវត្តផងដែរចំពោះសណ្ឋាគារ ។

ក្នុងករណីនេះ រាល់បន្ទប់ដេក ក៏ដូចជារាល់បន្ទប់ទទួលភ្ញៀវ សុទ្ធតែត្រូវចាត់ទុកថាជាបន្ទប់រស់នៅ ។

បទបញ្ញត្តិនេះ ក៏ត្រូវដាក់អោយអនុវត្តផងដែរ ចំពោះកន្លែងធ្វើការ ។ ក្នុងករណីនេះ រាល់បន្ទប់ដែលមានមុខងារជាការិយាល័យ ឬ រោងជាងប្រើប្រាស់ជាទម្លាប់ ឬជាប្រចាំថ្ងៃ ត្រូវចាត់ទុកដូចជាបន្ទប់រស់នៅដែរ លើកលែងតែបន្ទប់មិនត្រូវការជាចាំបាច់នូវពន្លឺថ្ងៃ តាមមុខងារយថាប្រភេទរបស់វា ដូចជាបន្ទប់កុំព្យូទ័រ បន្ទប់ពិសោធន៍ សូន្យឹយោភាពយន្ត ។ ល ។

សាលាក្រុង ឬ សាលាខេត្ត អាចមានសិទ្ធិអោយបិទរាល់ច្រកប្រហោងណា ដែលពុំគោរពតាមចម្ងាយដូចបានរៀបរាប់ខាងលើនេះ ។

ចំពោះអគារមានពីមុនស្រាប់ ដែលពុំគោរពតាមបទបញ្ញត្តិដូចបានរៀបរាប់ខាងលើនេះទេ សាលាក្រុង ឬ សាលាខេត្ត អាចទាមទារអោយបង្កើតរបាំងការពារ កុំអោយមានគំហើញត្រង់ទៅលើដីឡូត៍អ្នកជិតខាង ។

របាំងការពារទាំងនេះ អាចជាជញ្ជាំងមានប្រឡោះខ្យល់ ផ្ទាំងឈើ ឬអ្វីៗផ្សេងទៀត ដែលពុំរាំងខ្ទប់ដំណើរខ្យល់បក់ចេញចូលក្នុងបន្ទប់រស់នៅ ។

ចាត់ទុកជាបង្អួច រាល់ប្រហោងនានាដែលបណ្តាលអោយមានគំហើញត្រង់ ឆ្ពោះទៅលើអ្នកជិតខាង ។ ក្នុងករណីណាក៏ដោយ គេអាចប្រើប្រាស់បានរាល់របាំងធ្វើពីឈើ ឬបេតុង ស្លាបព្រីលចាក់ប៉ើក ធ្វើពីឈើ ឬកញ្ចក់ស្រអាប់ និង ស្លាបព្រីលនៅនឹងថ្កល់ ។

### មាត្រា ៣៥ : ផ្ទៃបាត

ចំពោះផ្ទះល្វែង និង អគារលំនៅឋានសមូហភាព ផ្ទៃបាតសំណង់ធៀបទៅនឹងផ្ទៃក្រឡារបស់ដីឡូត៍ ពុំអាចលើសពី ៧៥% ឡើយ ។

ចំពោះផ្ទះជាលំនៅដ្ឋាន ផ្ទៃបាតសំណង់នោះពុំអាចលើសពី ៥០% នៃផ្ទៃក្រឡាដីឡូត៍ឡើយ ។

ផ្ទៃក្រឡាដីឡូត៍ ដែលនៅសល់ពីការសាងសង់ ត្រូវរៀបចំជាសួនដោយដីជ្រាបទឹក អោយបានយ៉ាងតិចពាក់កណ្ដាលផ្ទៃក្រឡានេះ ។

ចំពោះអគារដែលមានយ៉ាងតិច ១៥លំនៅ សណ្ឋាគារ អគារការិយាល័យ និង អគារឧស្សាហកម្ម ផ្ទៃបាតសំណង់ពុំអាចលើសពី ៥០% នៃផ្ទៃក្រឡាដីឡូត៍ឡើយ ។

ផ្ទៃក្រឡាដែលនៅសល់ពីសំណង់ នឹងត្រូវរៀបចំជាសួនដោយដីជ្រាបទឹក អោយបានយ៉ាងតិចពាក់កណ្ដាលផ្ទៃក្រឡានេះ ។

សាលាក្រុង និង សាលាខេត្ត ត្រូវកំណត់តំបន់រៀបចំក្រុង ដែលត្រូវយកបទបញ្ញាខាងលើនេះមកអនុវត្ត ហើយនិងត្រូវកំណត់បទបញ្ញត្តិពិសេស ចំពោះស្ថានភាពជាក់ស្ដែង ។

**មាត្រា ៣៦ : ប្លង់កំពស់**

សាលាក្រុង និង សាលាខេត្តនីមួយៗ នឹងលើកគំរោងប្លង់កំពស់ក្នុងរយៈពេលមួយឆ្នាំ ក្រោយពីបានការអនុម័តលើអនុក្រឹត្យនេះរួច ដោយកំណត់អោយតំបន់នីមួយៗនៃក្រុងនូវកំពស់អតិបរិមានៃសំណង់ ។

ប្លង់កំពស់នេះត្រូវគិតដល់ :

. កំពស់មធ្យមបច្ចុប្បន្នតាមសង្កាត់នីមួយ ៗ ។

. លក្ខណៈសំខាន់នៃតំបន់ (ពាណិជ្ជកម្ម លំនៅដ្ឋាន ឧស្សាហកម្មនៅកណ្ដាលក្រុង ឬជាយក្រុង ដីចាក់បំពេញ ឬរង់ ការប្រើប្រាស់ទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធ ។ ល ។) ។

. ប្រភេទនៃសំណង់ (ផ្ទះល្វែង ភូមិគ្រឹះ គ្រឹះស្ថាន ឃ្លាំងស្តុកទំនិញ និង អគារឧស្សាហកម្ម...។ ល ។) ។

ប្លង់កំពស់នេះ ត្រូវបានទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ហើយផ្សព្វផ្សាយជាសាធារណៈ ។

**មាត្រា ៣៧ : ការការពារប្រាង្គប្រាសាទ និង ទេសភាព**

សាលាក្រុង និង សាលាខេត្តនីមួយ ៗ អាចកំណត់កំពស់អតិបរិមាទាបជាងកំពស់អតិបរិមាក្នុង << ប្លង់កំពស់ >> ដើម្បីការពារបូជនីយស្ថានប្រវត្តិសាស្ត្រ រមណីយដ្ឋានធម្មជាតិ ក៏ដូចជាកន្លែងនៅជិត ៗ ប្រាង្គប្រាសាទប្រវត្តិសាស្ត្រ ឬ ដើម្បីរក្សាទុកនូវទស្សនីយភាព នៃប្រាង្គប្រាសាទ និង ទស្សនីយភាពពិសេសផ្សេងៗ ។

ការបន្ថយកំពស់នេះ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈ និង ប្រាប់ដល់អ្នកសុំលិខិតអនុញ្ញាតសាងសង់មុនពេលដាក់សំណុំលិខិតស្នើសុំ ។

## ជំពូក ៣

## ទិដ្ឋភាពនៃសំណង់

មាត្រា ៣៨ : លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់ដែលគ្រោងនោះមានទីតាំង ស្ថាបត្យកម្ម (Architecture) ទំហំ ឬ ទិដ្ឋភាពក្រៅអាចនាំអោយប៉ះពាល់ដល់លក្ខណៈ ឬ ផលប្រយោជន៍របស់ទីតាំងនៅជុំវិញ ប៉ះពាល់ដល់ទេសភាពធម្មជាតិ ឬទីក្រុង ភាពស្ងប់របស់ទីសក្ការបូជា រមណីយដ្ឋានប្រវត្តិសាស្ត្រ ឬ បុរាណសាស្ត្រ រាជវាំង និង រាជព្រះបរមរាជវាំង ។

មាត្រា ៣៩ : លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើង បើលក្ខណៈសំណង់នោះមិនធានាសុខមាលភាព បន្ទប់ស្នាក់នៅ ឬ បន្ទប់ធ្វើការនិមួយ ៗ ត្រូវអោយមានខ្យល់ចេញ-ចូល ហើយត្រូវមានបង្អួចមួយយ៉ាងតិច ។

ផ្ទៃក្រឡាបញ្ចូលពន្លឺថ្ងៃសំរាប់បន្ទប់នីមួយ ៗ ត្រូវមានយ៉ាងតិច ១,៥០ម $^{២}$ ។

មាត្រា ៤០ : បណ្តាសំណង់ឧស្សាហកម្ម អាចតម្រូវអោយគោរពល័ក្ខខ័ណ្ឌពិសេសចំពោះការរៀបចំ ឬការពោះទីតាំង ដើម្បីធានាការបញ្ចូលឱ្យបានល្អទៅក្នុងទេសភាព និង រមណីយដ្ឋានធម្មជាតិ ឬ ទីក្រុង ។

មាត្រា ៤១ : នៅតាមឆ្នេរសមុទ្រ តាមមាត់បឹង ស្ទឹង និងទន្លេ លិខិតអនុញ្ញាតសាងសង់នឹងមិនផ្តល់ជូនឡើយ បើសំណង់នោះធ្វើអោយខូចទ្រង់ទ្រាយសោភ័ណភាពរបស់ទេសភាព និង រមណីយដ្ឋាន ដោយសារទិដ្ឋភាព ឬ កំពស់របស់សំណង់ បើមើលពីមាត់ឆ្នេរ ពីមាត់ច្រាំង ពីសមុទ្រ ស្ទឹង ទន្លេ ឬបឹងបួរ និង ប៉ះពាល់ដល់គុណភាពទឹក ។

## ជំពូក ៤

## សន្ទភាព ( ដង់ស៊ីតេ ) : កំរិតស្របច្បាប់នៃសន្ទស្សន៍ប្រើប្រាស់

មាត្រា ៤២ : ការស្ថាបនាសំណង់មួយមានសន្ទភាព លើសពីកំរិតអតិបរមាស្របច្បាប់ តម្រូវអោយអ្នកទទួលលិខិតអនុញ្ញាតសាងសង់ បង់ប្រាក់ស្មើនឹងតំលៃដីដែលចាំបាច់ ដើម្បីអោយ << សន្ទស្សន៍ប្រើប្រាស់ >> សំណង់មិនលើស ពីកំរិតនេះ ។

មាត្រា ៤៣ : << សន្ទស្សន៍ប្រើប្រាស់ >> ត្រូវបានកំណត់ដោយអនុបាតរវាងផ្ទៃក្រឡាកម្រាលសរុបជាផ្លូវការ ( Hors oeuvre nette ) នៃសំណង់នោះ និងផ្ទៃក្រឡាដីដែលសំណង់នោះនឹងត្រូវ ឬបានតាំងនៅលើ ។

កាលណាសំណង់ថ្មីមួយ បានត្រូវសាងសង់លើដីមួយកន្លែងដែលមានអគារចាស់មួយ ឬច្រើន ហើយគ្មានគម្រោងរុះរើពេលនោះទេ សន្ទភាពត្រូវគណនាដោយថែមផ្ទៃក្រឡាកម្រាលនៃសំណង់ចាស់ ទៅលើផ្ទៃក្រឡាកំរាលនៃសំណង់ថ្មី ។

មាត្រា ៨៤ : កំរៃតវិធានរាជរដ្ឋាភិបាលក្នុងការប្រើប្រាស់ ត្រូវកំណត់ដោយ (១) សំរាប់ទូទាំងដែនដីក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៨៥ : ការផ្តល់លិខិតអនុញ្ញាតសាងសង់ នាំមកអោយអ្នកបានទទួលលិខិតអនុញ្ញាតសាងសង់ ជាកាតព្វកិច្ចអោយបង់ប្រាក់នោះ ។ ការបង់ប្រាក់ត្រូវធ្វើជាបីភាគស្មើគ្នា ភាគទី ១ នៅពេលបានទទួលលិខិតអនុញ្ញាតសាងសង់ ភាគទី ២ នៅពេលបើកការដ្ឋាន ភាគទី ៣ នៅពេលបញ្ចប់សំណង់ ។

មាត្រា ៨៦ : តំលៃបីសំរាប់ការគណនាចំនួនទឹកប្រាក់ដែលត្រូវបង់ ត្រូវបានកំណត់ដោយក្រសួងហិរញ្ញវត្ថុ ។

មាត្រា ៨៧ : កំរៃស្របច្បាប់នៃ << សន្ទស្សន៍ប្រើប្រាស់ >> ពុំត្រូវអនុវត្តឡើយ ចំពោះសំណង់ដែលពុំតម្រូវអោយមានលិខិតអនុញ្ញាតសាងសង់ ចំពោះគ្រឹះស្ថានសាធារណៈ និង ចំពោះអគាររដ្ឋបាលសាធារណៈសំរាប់បំរើផ្ទាល់មុខ ជាកន្លែងធ្វើការសំរាប់ស្ថាប័នសាធារណៈ ។

នាយករដ្ឋមន្ត្រី អាចសំរេចលើកលែងការអនុវត្តកំរៃស្របច្បាប់នៃ << សន្ទស្សន៍ប្រើប្រាស់ >> ចំពោះបណ្តាតំបន់រៀបចំពិសេស បន្ទាប់ពីបានយោបល់ពីគណៈកម្មាធិការជាតិ រៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ។

<< វាលទន្លេសាប >> ទាំងឡាយអាចទទួលនូវការលើកលែងមិនអោយបង់ពន្ធអាករ តាមសេចក្តីសំរេចរបស់អភិបាលខេត្ត-ក្រុង បន្ទាប់ពីបានទទួលការយល់ព្រមពីគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ ។

## ជំពូក ៩

## បទបញ្ញត្តិពិសេស សំរាប់អនុវត្តលើភាគខ្លះ នៃដែនដី

មាត្រា ៨៨ : ជាការបន្ថែមលើបទបញ្ញត្តទូទៅនៃការប្រើប្រាស់ដី-ធ្លី ការណែនាំមួយចំនួនសំរាប់ការរៀបចំតំបន់ និង បទបញ្ញាត្តនគរូបនីយកម្មពិសេសមួយចំនួន អាចត្រូវដាក់តែងឡើងដោយអនុក្រឹត្យដែលអាច មានរហូតដល់ការហាមមិនអោយសាងសង់នៅក្នុង << តំបន់ទាប់អារម្មណ៍ >> ដូចជា ឆ្នេរសមុទ្រ មាត់ច្រាំងទន្លេ និង បឹងធំ ៗ ។ រាល់ឯកសារ << នគរូបនីយកម្មមូលដ្ឋាន >> និង ប្លង់ខេត្តនៃ តំបន់ហាមមិនអោយមានសំណង់ ដែលចែងក្នុងមាត្រា ៣២ វគ្គទី ២ នៃអនុក្រឹត្យនេះត្រូវទុកជាការណែនាំ ទាំងនេះ និង ការហាមជាយថាហេតុមិនអោយសាងសង់ ។

មាត្រា ៨៩ : បទបញ្ញត្តិទាំងឡាយណាពីមុនដែលផ្ទុយនឹងអនុក្រឹត្យនេះ ចាត់ទុកជានិរាករណ៍ ។

មាត្រា ៥០ : ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និង វិចិត្រសិល្បៈ រៀបចំទឹកដីនគរូបនីយកម្ម និង សំណង់ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង អភិបាលខេត្ត សមាជិកគណៈកម្មាធិការជាតិរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមតួនាទីចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ១៩ ខែ ៨ ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

អ៊ឹង ហួត ហ៊ុន សែន

កន្លែងទទួល :
- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យឯកឧត្តមនាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រីទី ២
- ដូចមាត្រា ៥០
- ឯកសារ-កាលប្បវត្តិ

ជំរាបជូន :
ឯកឧត្តមនាយករដ្ឋមន្ត្រីទី ១
សម្ដេចនាយករដ្ឋមន្ត្រីទី ២
ទេសរដ្ឋមន្ត្រីទទួលបន្ទុកវប្បធម៌ និងវិចិត្រសិល្បៈ
រៀបចំទឹកដី នគរូបនីយកម្ម និង សំណង់

ចន្ទ មុ៉លីចន្ទ

---

លេខ 059 សក.ចល
ថតចម្លងតាមច្បាប់ដើម
- ជូន ឯកឧត្តម រដ្ឋមន្ត្រី ស្ដីទី
- - ឯកឧត្តម អគ្គនាយករដ្ឋបាល
- - លេខាធិការ ដ្ឋ. នាយករដ្ឋមន្ត្រី
- - រៀបចំដែនដី នគររូបនីយកម្ម និង សំណង់
ដើម្បីជូនជ្រាបជាព័ត៌មាន
ភ្នំពេញ ថ្ងៃទី 12 ខែ មករា ឆ្នាំ 1998
រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន
ប្រធានខុទ្ទកាល័យ

យី សុខខន

(៥៥១) ៤៤១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ ៣៤ ប្រក/សណ.

៦.៦.០១

# ប្រកាស

## ស្តីពី

## ការគ្រប់គ្រងការដ្ឋានសំណង់

រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩ /០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញព្រះរាជក្រម លេខ ០៤ /នស /៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ /បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានឃើញអនុក្រឹត្យ លេខ ៨៦ / អនក្រ / បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤៣ អនុក្រ / បក ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ស្តីពីសណ្តាប់ធ្នាប់សាធារណៈនៅរាជធានីភ្នំពេញ និង ខេត្ត ក្រុង
- បានឃើញប្រកាស លេខ ៧៥ ប្រក / ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស ក្រុមហ៊ុន សិក្សាគំរោងប្លង់ និង សាងសង់
- បានឃើញប្រកាស លេខ ៧៦ ប្រក / ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីតួនាទី ភារកិច្ចបេសកកម្មរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង និង តួនាទី ភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- ផ្អែកលើសភាពការណ៍នៃស្ថានភាពសំណង់បច្ចុប្បន្ន ។

សម្រេច

ប្រកាសនេះ មានគោលបំណងរក្សាសណ្តាប់ធ្នាប់ សន្តិសុខសាធារណៈ និង សុវត្ថិភាព ក្នុងការដ្ឋានសំណង់ ព្រមទាំងពង្រឹងការអនុវត្តបទប្បញ្ញត្តិនានាដែលទាក់ទងនឹងការសាងសង់សំដៅបង្កើនគុណភាព និង សោភ័ណភាព ។

ប្រការ ២.-

អាចអនុញ្ញាតឱ្យបើកការដ្ឋានដំណើរការបានចំពោះតែសំណង់ណាដែល សហគ្រាស ក្រុមហ៊ុន ឬ ក្រុមជាងម៉ៅការសាងសង់ មានលិខិតអនុញ្ញាតប្រកបអាជីវកម្មសាងសង់ចេញឱ្យដោយ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬមន្ទីរ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ។

ប្រការ ៣.-

ការដ្ឋាននីមួយៗ អាចដំណើរការបានលុះត្រាតែមានលិខិតអនុញ្ញាតបើកការដ្ឋាន ។

លិខិតអនុញ្ញាតបើកការដ្ឋានត្រូវសុំទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង ក្នុងរយៈពេលមួយខែយ៉ាងយូរបន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ ។

សំណុំឯកសារដើម្បីសុំលិខិតអនុញ្ញាតបើកការដ្ឋានមាន :

១-ពាក្យសុំរបស់ម្ចាស់សំណង់

២-លិខិតអនុញ្ញាតសាងសង់

៣-កិច្ចសន្យារវាងម្ចាស់សំណង់ និង សហគ្រាស ក្រុមហ៊ុន ឬ ក្រុមជាងម៉ៅការសាងសង់

៤-លិខិតអនុញ្ញាតប្រកបអាជីវកម្មសាងសង់ របស់សហគ្រាស ក្រុមហ៊ុន ឬក្រុមជាងម៉ៅការសាងសង់ ដែលទទួលសំណង់នោះ ។

ប្រការ ៤.-

ការដ្ឋានសំណង់នីមួយៗត្រូវ :

-តំកល់ជាប្រចាំ លិខិតបើកការដ្ឋាន . គំនូរប្លង់តាមមុខជំនាញការងារសំណង់ . ផែនការអនុវត្តការងារក្នុងដំណាក់កាលនីមួយៗនៃការសាងសង់ និង ឯកសារ ពាក់ព័ន្ធ ទុកសម្រាប់ភ្នាក់ងារសំណង់តាមដានត្រួតពិនិត្យ

-មានអ្នកបច្ចេកទេសសំណង់សម្រាប់ទទួលខុសត្រូវក្នុងការងារសាងសង់ ហើយមានកាតព្វកិច្ចឆ្លើយបំភ្លឺ ផ្តល់ព័ត៌មានជូនដល់ភ្នាក់ងារមានសមត្ថកិច្ចត្រួតពិនិត្យ

-ដាក់ផ្ទាំងគំនូរសំណង់ ដែលមានឈ្មោះសំណង់ នៃអគារត្រូវសាងសង់ . ក្រុមហ៊ុនសំណង់ . ម្ចាស់សំណង់ . ស្ថាបត្យករ . វិស្វករ . ថ្ងៃក្រឡាសំណង់ . លេខទូរស័ព្ទទាក់ទង និងកន្លែងការដ្ឋានតាំងនៅ

-មានភ្លើងដើម្បីបំភ្លឺ និង ត្រូវមានប្រដាប់សម្រាប់ពន្លត់អគ្គិភ័យជាប្រចាំ

-បន្ថយការរំខានដោយសូរសំលេង រំជួយ ធូលី និង ផលប៉ះពាល់ដទៃទៀត ឱ្យស្ថិតនៅក្នុងកំរិត និង ពេល

វេលាមួយដែលអ្នករស់នៅជុំវិញការដ្ឋានអាចទទួលបាន ។

ប្រការ ៥.-

ការដ្ឋានទីមួយៗ ត្រូវហ៊ុមព័ទ្ធដោយរបងមានកម្ពស់ ២ម៉ែត្រ យ៉ាងទាបបំផុត ហើយមិនអនុញ្ញាតឱ្យធ្វើលើចិញ្ចើមថ្នល់ ។ ក្នុងករណីទីតាំងការដ្ឋានចង្អៀត ការធ្វើរបងបិទបាំងបណ្ដោះអាសន្នលើចិញ្ចើមថ្នល់សាធារណៈ ត្រូវរក្សាឱ្យមានចន្លោះផ្លូវដើរលើចិញ្ចើមថ្នល់ និង ធ្វើរបាំងការពារតាមទំហំដែលអនុញ្ញាត ឬ កំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។ ចំពោះសំណង់ដែលមានកម្ពស់ចាប់ពី ៥ម៉ែត្រឡើងទៅ ត្រូវហ៊ុមព័ទ្ធដោយក្រណាត់កៅស៊ូ ឬសំណាញ់សុវត្ថិភាព ។

ប្រការ ៦.-

ការដ្ឋានត្រូវមានសណ្ដាប់ធ្នាប់ និង អនាម័យ ជាប្រចាំ តាំងពីពេលចាប់ផ្ដើមដំណើរការរហូតដល់ពេលបញ្ចប់ការដ្ឋាន ។ ម្ចាស់សំណង់ជាអ្នកទទួលខុសត្រូវចំពោះការ រៀបចំសណ្ដាប់ធ្នាប់ និង អនាម័យដែលបណ្ដាលមកពីការទុកដាក់សម្ភារៈ ឬ កាកសំណល់ឱ្យប៉ះពាល់ផ្លូវសាធារណៈ ឬ ហូរធ្លាក់ចូលក្នុងអាងត្រួតពិនិត្យ នៃបណ្ដាញលូ និង ប្រឡាយទឹក ។

ប្រការ ៧.-

ការិយាល័យការងារ ឃ្លាំងផ្ទុកសម្ភារៈ ជម្រកកម្មករ គ្រឿងចក្រ និង សកម្មភាពសាងសង់ត្រូវរៀបចំ និងប្រព្រឹត្តទៅនៅក្នុងរបងហ៊ុមព័ទ្ធនៃការដ្ឋាន ឬ ការដ្ឋានរណប ឬទីកន្លែងដែលធានាបានសណ្ដាប់ធ្នាប់ និង សន្តិសុខសាធារណៈ ។

ប្រការ ៨.-

ចំពោះសំណង់ដែលត្រូវប្រើគ្រឿងចក្របរិក្ខារលើកស្ទូច ហើយអាចធ្វើឱ្យប៉ះពាល់ដល់ការធ្វើដំណើរលើផ្លូវសាធារណៈ ម្ចាស់សំណង់ត្រូវ :

-សុំការអនុញ្ញាតពីអាជ្ញាធរដែនដី ដើម្បីបិទផ្លូវសម្រាប់ការដំឡើងគ្រឿងផ្គុំសំណង់ ហើយធ្វើផ្លូវវាងជាបណ្ដោះអាសន្ន

-បំពាក់ភ្លើងសញ្ញាសម្គាល់ លើផ្លូវដែលបិទ ដើម្បីសុវត្ថិភាព និង សណ្ដាប់ធ្នាប់សាធារណៈនៅពេលយប់ ។

ប្រការ ៩.-

ក្នុងករណីការសាងសង់មានបុគសសរគ្រឹះ ម្ចាស់សំណង់ និង អ្នកម៉ៅការសាងសង់ត្រូវ :

-មានកាតព្វកិច្ចអនុញ្ញាតឱ្យមន្ត្រីបច្ចេកទេស ដែលមានសមត្ថកិច្ចចូលពិនិត្យក្នុងការដ្ឋាន

-ជៀសវាងការប៉ះពាល់ដល់គ្រឿងផ្គុំផ្នែកក្រោមដី

-ធានាសុវត្ថិភាពអគារដែលស្ថិតនៅជុំវិញបរិវេណការដ្ឋាន

-រៀបចំសណ្ដាប់ធ្នាប់ការងារឱ្យបានសមស្រប តាមលក្ខណៈបច្ចេកទេស ។

មិនព្រមអនុវត្តតាមការណែនាំ អាជ្ញាធរមានសមត្ថកិច្ចត្រូវរុះរើ រឹបអូសសម្ភារៈសាងសង់ទាំងអស់ ហើយប្តឹងទៅតុលាការ ។

ការដ្ឋានដែលល្មើសនឹងករណីដូចមានចែងក្នុងប្រការ ៥ . ៦ និងប្រការ ៨ អាជ្ញាធរមានសមត្ថកិច្ចត្រូវជាកពិន័យ ហើយបង្គាប់ឱ្យម្ចាស់ការដ្ឋានអនុវត្តតាមការណែនាំអំពីរបៀបរៀបចំសណ្តាប់ធ្នាប់សន្តិសុខសាធារណៈ ។ ក្នុងករណីម្ចាស់សំណង់នៅតែមិនគោរពតាមការណែនាំ អាជ្ញាធរមានសមត្ថកិច្ចត្រូវរឹបអូសសម្ភារៈសំណង់ទាំងនោះ ។

ប្រការ ១៥._

ការដ្ឋានដែលត្រូវបានផ្អាកជាបណ្តោះអាសន្ន ដូចមានចែងក្នុងវាក្យខណ្ឌទី១ និងវាក្យខណ្ឌទី២ក្នុងប្រការទី ១៤ នៃប្រកាសនេះត្រូវបានអនុញ្ញាតឱ្យបើកតាមផ្លូវច្បាប់ជាថ្មីឡើងវិញ លុះត្រាតែបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់តាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច ។

សំណុំបែបបទនៃការបើកការដ្ឋានឡើងវិញ មានដូចខាងក្រោម :

១-ពាក្យសុំរបស់ម្ចាស់សំណង់

២-លិខិតអនុញ្ញាតបើកការដ្ឋានចាស់

៣-លិខិតផ្អាកការដ្ឋាន

៤-លិខិតបញ្ជាក់អំពីការបំពេញបានសព្វគ្រប់ នៃ លក្ខខណ្ឌខ្វះខាត ។

ប្រការ ១៦._

ម្ចាស់សំណង់ និងអ្នកម៉ៅការសាងសង់ ត្រូវគោរពច្បាប់ការងារ នៃ ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ១៧._

នាយកខុទ្ទកាល័យ អគ្គនាយក នៃ គ្រប់អគ្គនាយកដ្ឋាន ប្រធាន មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្ត ក្រុង និង ប្រធានការិយាល័យ រៀបចំដែនដី នគរូបនីយកម្ម សំណង់ និង ភូមិបាល ស្រុក ខណ្ឌ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ. ថ្ងៃទី......ខែ.........ឆ្នាំ ២០០១

រដ្ឋមន្ត្រី

ចម្លងជូន

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- គ្រប់សាលាខេត្ត ក្រុង
- ដូចប្រការ ១៧
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ..៩៣......ប្រក.ដនស/អសណ

# ប្រកាស

## ស្តីពី

## ការកែសម្រួលប្រការ២ និងប្រការ៣ នៃប្រកាសលេខ ៣២ប្រក/សណ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីការការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យ លេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-បានឃើញអនុក្រឹត្យ លេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

-យោងប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

-យោងតាមការចាំបាច់របស់ក្រសួង

<u>សម្រេច</u>

ប្រការ ១.-

ត្រូវបានកែសំរួលប្រការ ២ និងប្រការ ៣ នៃប្រកាសលេខ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ដូចខាងក្រោម :

<u>ប្រការ២(ថ្មី)</u>: អាចផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់បានចំពោះតែម្ចាស់សំណង់ណា ដែលមានលិខិតអនុញ្ញាតសាងសង់ ចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬសាលារាជធានី-ខេត្ត ។

<u>ប្រការ៣(ថ្មី)</u> : ការដ្ឋាននីមួយៗអាចដំណើរការបានលុះត្រាតែមានលិខិតអនុញ្ញាតបើកការដ្ឋាន ។ លិខិតអនុញ្ញាតបើកការដ្ឋាន ត្រូវសុំនៅអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតសាងសង់ស្របតាមសមត្ថកិច្ចចេញលិខិតអនុញ្ញាតសាងសង់ ។ សុំណុំឯកសារដើម្បីសុំលិខិតអនុញ្ញាតបើកការដ្ឋានរួមមាន :

១-សំណុំឯកសារពាក្យសុំរបស់ម្ចាស់សំណង់ ។

២-លិខិតអនុញ្ញាតសាងសង់ ។

៣-ប្លង់ស្ថាបត្យកម្មដែលបានអនុញ្ញាត ។

៤-ប្លង់គ្រឿងផ្គុំសំណង់ ។

ប្រការ ២.-

បទប្បញ្ញត្តិណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣.-

នាយកខុទ្ទកាល័យ អគ្គនាយកគ្រប់អគ្គនាយកដ្ឋាន គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។ 

ភ្នំពេញ.ថ្ងៃទី២៦.ខែ.មីនា..ឆ្នាំ២០០៩

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អ៊ឹម ឈុនលឹម

<u>កន្លែងទទួល</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់សាលារាជធានី-ខេត្ត

-ដូចប្រការ៣

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៣៥៦ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

| | |
|---|---|
| **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** | **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី** |
| **ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** | **ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** |

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៤៣០ ២២៥ ទូរសារ : ៨៥៥-២៣-៤៣០ ៧៩៩
Phone : 855-23-430 225 / Fax : 855-23-430 799

- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០, មាត្រា ៣៤, មាត្រា ៣៨, មាត្រា ៥០, មាត្រា ៦៦, មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ. បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលតារាងពន្ធតែមប្រិ៍សារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- យោងតាមគោលការណ៍ឯកភាពរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ៣ ខែមករា ឆ្នាំ២០១៩ លើលិខិតលេខ ១២០៣១ សហវ.អខច ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីសំណើសុំគោលការណ៍អនុញ្ញាត ដើម្បីលើកលែងការបង់កម្រៃសេវាសាធារណៈ គ្រប់ដំណាក់កាលនៃការចុះបញ្ជីដីតាំងពីដើមរហូតដល់ចប់ ចំពោះការចុះបញ្ជីលើដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ និងគុរុភណ្ឌជាដីរបស់វត្ត លើកលែងតែដីដែលជាទ្រព្យសម្បត្តិរបស់សហគ្រាសសាធារណៈត្រូវបង់កម្រៃសេវាសាធារណៈជាធម្មតា
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ១ .–**

អនុញ្ញាតឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .–**

សេវាសាធារណៈដែលផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាពទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធ ភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

**ប្រការ១១ ._**

កម្រងសេវាសាធារណៈ ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃប្រកាសអន្តរក្រសួងនេះ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១២ ._**

ប្រកាសអន្តរក្រសួងនេះ មានអានុភាពជំនួស ប្រកាសរួមលេខ ៦៤៨ សហវ.ប្រក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣ ._**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី.០១..... ខែ.កក្កដា.. ឆ្នាំ២០១៩ តទៅ។

ថ្ងៃអង្គារ ៦កើត ខែ ផល្គុន ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

កន្លែងទទួល÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ

ភ្ជាប់នឹងប្រកាសរួមលេខ ៣៥៦...... សហវ.ប្រក ចុះថ្ងៃទី ២៦.... ខែ មីនា.... ឆ្នាំ២០១៩

ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

ក. សេវាសាធារណៈដែលផ្តល់ដោយរដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

| លេខរៀង ចំនួនសេវា | បរិយាយ | | តម្លៃសេវា (ជារៀល) | | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | ខណ្ឌក្នុងរាជធានី និងក្នុងក្រុង | ខណ្ឌជាយរាជធានី និងក្រៅក្រុង | | | |
| | I. សេវាសំណង់ | | | | | | |
| | ១ | លិខិតអនុញ្ញាតសាងសង់ | | | | | |
| | ១.១ | សំណង់លំនៅឋាន ÷ ភូមិគ្រឹះ ពាក់កណ្តាលភូមិគ្រឹះ ផ្ទះល្វែង ផ្ទះថ្មក្រោមឈើលើ | | | | | |
| ១ | | - ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² ដល់ ៤ ០០០ ម² | ១០ ០០០ ០០០ | ៩ ៨០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ២ | | - ផ្ទៃក្រឡាសំណង់ លើសពី ៤ ០០០ ម² ដល់ ៥ ០០០ ម² | ១០ ២០០ ០០០ | ១០ ០០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៣ | | - ផ្ទៃក្រឡាសំណង់ លើសពី ៥ ០០០ ម² ដល់ ៦ ០០០ ម² | ១០ ៥០០ ០០០ | ១០ ៣០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៤ | | - ផ្ទៃក្រឡាសំណង់ លើសពី ៦ ០០០ ម² ដល់ ៨ ០០០ ម² | ១០ ៧០០ ០០០ | ១០ ៥០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៥ | | - ផ្ទៃក្រឡាសំណង់ លើសពី ៨ ០០០ ម² ដល់ ១០ ០០០ ម² | ១១ ០០០ ០០០ | ១០ ៧០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៦ | | - ផ្ទៃក្រឡាសំណង់ លើសពី ១០ ០០០ ម² ដល់ ២០ ០០០ ម² | ១១ ២០០ ០០០ | ១០ ៩០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៧ | | - ផ្ទៃក្រឡាសំណង់ លើសពី ២០ ០០០ ម² ដល់ ៣០ ០០០ ម² | ១១ ៣០០ ០០០ | ១១ ០០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៨ | | - ផ្ទៃក្រឡាសំណង់ លើសពី ៣០ ០០០ ម² ដល់ ៤០ ០០០ ម² | ១១ ៤០០ ០០០ | ១១ ១០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៩ | | - ផ្ទៃក្រឡាសំណង់ លើសពី ៤០ ០០០ ម² ដល់ ៥០ ០០០ ម² | ១១ ៥០០ ០០០ | ១១ ២០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ១០ | | - ផ្ទៃក្រឡាសំណង់ លើសពី ៥០ ០០០ ម² ដល់ ៦០ ០០០ ម² | ១១ ៦០០ ០០០ | ១១ ៣០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ១១ | | - ផ្ទៃក្រឡាសំណង់ លើសពី ៦០ ០០០ ម² ដល់ ៧០ ០០០ ម² | ១១ ៦៥០ ០០០ | ១១ ៣៥០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ១២ | | - ផ្ទៃក្រឡាសំណង់ លើសពី ៧០ ០០០ ម² ដល់ ៨០ ០០០ ម² | ១១ ៧០០ ០០០ | ១១ ៤០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |

| លេខរៀង ចំនួនសេវា | បរិយាយ | តម្លៃសេវា (ជារៀល) | | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| | | ខណ្ឌក្នុងរាជធានី និងក្នុងក្រុង | ខណ្ឌជាយរាជធានី និងក្រៅក្រុង | | | |
| ១៣ | - ផ្ទៃក្រឡាសំណង់ លើសពី ៨០ ០០០ ម² ដល់ ៩០ ០០០ ម² | ១១ ៧៥០ ០០០ | ១១ ៤៥០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ១៤ | - ផ្ទៃក្រឡាសំណង់ លើសពី ៩០ ០០០ ម² ដល់ ១០០ ០០០ ម² | ១១ ៨០០ ០០០ | ១១ ៥០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ១៥ | - ផ្ទៃក្រឡាសំណង់ លើសពី ១០០ ០០០ ម² | បូកបន្ថែមក្នុង ១ម² ស្មើ ១១៨រៀល | បូកបន្ថែមក្នុង ១ម² ស្មើ ១១៥រៀល | ៤៥ថ្ងៃ | ១ឆ្នាំ | |
| | ១.២ សំណង់ចិរុះ ÷ លំនៅឋាន+ ការិយាល័យ+ ពាណិជ្ជកម្ម+ រោងចក្រ+ អប់រំ+ ពេទ្យ ........... | | | | | |
| ១៦ | - ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² ដល់ ៤ ០០០ ម² | ១៥ ០០០ ០០០ | ១៤ ៨០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ១៧ | - ផ្ទៃក្រឡាសំណង់ លើសពី ៤ ០០០ ម² ដល់ ៥ ០០០ ម² | ១៥ ៧០០ ០០០ | ១៥ ៥០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ១៨ | - ផ្ទៃក្រឡាសំណង់ លើសពី ៥ ០០០ ម² ដល់ ៦ ០០០ ម² | ១៦ ៥០០ ០០០ | ១៦ ៣០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ១៩ | - ផ្ទៃក្រឡាសំណង់ លើសពី ៦ ០០០ ម² ដល់ ៨ ០០០ ម² | ១៧ ២០០ ០០០ | ១៧ ០០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ២០ | - ផ្ទៃក្រឡាសំណង់ លើសពី ៨ ០០០ ម² ដល់ ១០ ០០០ ម² | ១៨ ០០០ ០០០ | ១៧ ៧០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ២១ | - ផ្ទៃក្រឡាសំណង់ លើសពី ១០ ០០០ ម² ដល់ ២០ ០០០ ម² | ១៩ ៥០០ ០០០ | ១៩ ២០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ២២ | - ផ្ទៃក្រឡាសំណង់ លើសពី ២០ ០០០ ម² ដល់ ៣០ ០០០ ម² | ១៩ ៦៥០ ០០០ | ១៩ ៣៥០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ២៣ | - ផ្ទៃក្រឡាសំណង់ លើសពី ៣០ ០០០ ម² ដល់ ៤០ ០០០ ម² | ១៩ ៨០០ ០០០ | ១៩ ៦០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ២៤ | - ផ្ទៃក្រឡាសំណង់ លើសពី ៤០ ០០០ ម² ដល់ ៥០ ០០០ ម² | ១៩ ៩៥០ ០០០ | ១៩ ៦៥០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ២៥ | - ផ្ទៃក្រឡាសំណង់ លើសពី ៥០ ០០០ ម² ដល់ ៦០ ០០០ ម² | ២០ ១០០ ០០០ | ១៩ ៨០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ២៦ | - ផ្ទៃក្រឡាសំណង់ លើសពី ៦០ ០០០ ម² ដល់ ៧០ ០០០ ម² | ២០ ១៧៥ ០០០ | ១៩ ៨៧៥ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ២៧ | - ផ្ទៃក្រឡាសំណង់ លើសពី ៧០ ០០០ ម² ដល់ ៨០ ០០០ ម² | ២០ ២៥០ ០០០ | ១៩ ៩៥០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ២៨ | - ផ្ទៃក្រឡាសំណង់ លើសពី ៨០ ០០០ ម² ដល់ ៩០ ០០០ ម² | ២០ ៣២៥ ០០០ | ២០ ០២៥ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ២៩ | - ផ្ទៃក្រឡាសំណង់ លើសពី ៩០ ០០០ ម² ដល់ ១០០ ០០០ ម² | ២០ ៤០០ ០០០ | ២០ ១០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៣០ | - ផ្ទៃក្រឡាសំណង់ លើសពី ១០០ ០០០ ម² | បូកបន្ថែមក្នុង ១ម² ស្មើ ២១០រៀល | បូកបន្ថែមក្នុង ១ម² ស្មើ ២០០រៀល | ៤៥ថ្ងៃ | ១ឆ្នាំ | |

| លេខរៀងចំនួនសេវា | | បរិយាយ | តម្លៃសេវា (ជារៀល) | | រយៈពេលអតិបរមានៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | ខណ្ឌក្នុងរាជធានីនិងក្រុងខេត្ត | ខណ្ឌជាយរាជធានីនិងក្រុងខេត្ត | | | |
| | ១.៣ | ក. សំណង់ដែលមាននុបនិស្ស័យខាងឧស្សាហកម្ម÷ អគារឃ្លាំង រោងចក្រកាត់ដេរគ្រប់ប្រភេទ វារីអគ្គិសនី រោងចក្រអគ្គិសនី រោងចក្រស៊ីម៉ងត៍ ចំណតរថភ្លើង អាកាសយានដ្ឋាន និងប្រភេទសំណង់ឧស្សាហកម្មផ្សេងៗទៀត | | | | | |
| | | ខ. សំណង់ដែលមាននុបនិស្ស័យខាងពាណិជ្ជកម្ម ÷ ស្ថានីយ៍ប្រេងឥន្ធនៈ កន្លែងស្តុកហ្គាស ផ្សារអគារលក់ទំនិញ ភោជនីយដ្ឋាន អគារការិយាល័យ ធនាគារ បុរី ផ្ទះស្នាក់នៅរួម អគារសហកម្មសិទ្ធ និងប្រភេទសំណង់ពាណិជ្ជកម្មផ្សេងៗទៀត | | | | | |
| | | គ. សំណង់ដែលមាននុបនិស្ស័យខាងសេវាកម្ម÷ ផ្ទះជួល ផ្ទះសំណាក់ ផ្ទះស្នាក់នៅគ្រួសារ ម៉ូតែល សណ្ឋាគារ គ្រប់ប្រភេទ វីឡា កាស៊ីណូ ក្លឹបកំសាន្ត សួនសត្វ រមណីយដ្ឋាន មណ្ឌលកំសាន្ត កំពង់ផែ ចំណតរថយន្ត និងប្រភេទសំណង់សេវាកម្មផ្សេងៗទៀត | | | | | |
| | | ឃ. សំណង់វិនិយោគ ÷ តំបន់សេដ្ឋកិច្ចពិសេស តំបន់អភិវឌ្ឍន៍មានលក្ខណៈជាក្រុង ឬ ក្រុងរណប ការអភិវឌ្ឍកោះ អង់តែនទូរស័ព្ទ អង់តែនទូរទស្សន៍និងវិទ្យុ ស្ថានីយ៍វិទ្យុ-ទូរទស្សន៍ ស្ថានីយ៍ផ្ទាយរលក និងប្រភេទសំណង់វិនិយោគផ្សេងៗទៀត | | | | | |
| ៣១ | | - ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² ដល់ ៤ ០០០ ម² | ១៤ ៨០០ ០០០ | ១៤ ៦០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៣២ | | - ផ្ទៃក្រឡាសំណង់ លើសពី ៤ ០០០ ម² ដល់ ៥ ០០០ ម² | ១៥ ៥០០ ០០០ | ១៥ ៣០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៣៣ | | - ផ្ទៃក្រឡាសំណង់ លើសពី ៥ ០០០ ម² ដល់ ៦ ០០០ ម² | ១៦ ៣០០ ០០០ | ១៦ ១០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៣៤ | | - ផ្ទៃក្រឡាសំណង់ លើសពី ៦ ០០០ ម² ដល់ ៨ ០០០ ម² | ១៧ ០០០ ០០០ | ១៦ ៨០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៣៥ | | - ផ្ទៃក្រឡាសំណង់ លើសពី ៨ ០០០ ម² ដល់ ១០ ០០០ ម² | ១៧ ៧០០ ០០០ | ១៧ ៤០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៣៦ | | - ផ្ទៃក្រឡាសំណង់ លើសពី ១០ ០០០ ម² ដល់ ២០ ០០០ ម² | ១៩ ២០០ ០០០ | ១៨ ៩០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៣៧ | | - ផ្ទៃក្រឡាសំណង់ លើសពី ២០ ០០០ ម² ដល់ ៣០ ០០០ ម² | ១៩ ៣៥០ ០០០ | ១៩ ០៥០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៣៨ | | - ផ្ទៃក្រឡាសំណង់ លើសពី ៣០ ០០០ ម² ដល់ ៤០ ០០០ ម² | ១៩ ៦០០ ០០០ | ១៩ ៣០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៣៩ | | - ផ្ទៃក្រឡាសំណង់ លើសពី ៤០ ០០០ ម² ដល់ ៥០ ០០០ ម² | ១៩ ៦៥០ ០០០ | ១៩ ៣៥០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៤០ | | - ផ្ទៃក្រឡាសំណង់ លើសពី ៥០ ០០០ ម² ដល់ ៦០ ០០០ ម² | ១៩ ៨០០ ០០០ | ១៩ ៥០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៤១ | | - ផ្ទៃក្រឡាសំណង់ លើសពី ៦០ ០០០ ម² ដល់ ៧០ ០០០ ម² | ១៩ ៨៧៥ ០០០ | ១៩ ៥៧៥ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៤២ | | - ផ្ទៃក្រឡាសំណង់ លើសពី ៧០ ០០០ ម² ដល់ ៨០ ០០០ ម² | ១៩ ៩៥០ ០០០ | ១៩ ៦៥០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៤៣ | | - ផ្ទៃក្រឡាសំណង់ លើសពី ៨០ ០០០ ម² ដល់ ៩០ ០០០ ម² | ២០ ០២៥ ០០០ | ១៩ ៧២៥ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |

| លេខរៀងចំនួនសេវា | | បរិយាយ | តម្លៃសេវា (ជារៀល) | | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | ខណ្ឌក្នុងរាជធានី និងក្នុងក្រុង | ខណ្ឌជាយរាជធានី និងក្រៅក្រុង | | | |
| ៤៤ | | - ផ្ទៃក្រឡាសំណង់ លើសពី ៩០ ០០០ ម² ដល់ ១០០ ០០០ ម² | ២០ ១០០ ០០០ | ២០ ០៩៧ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៤៥ | | - ផ្ទៃក្រឡាសំណង់ លើសពី ១០០ ០០០ ម² | បូកបន្ថែមក្នុង ១ម² ស្មើ ២០០រៀល | បូកបន្ថែមក្នុង ១ម² ស្មើ ១៨០រៀល | ៤៥ថ្ងៃ | ១ឆ្នាំ | |
| | ១.៤ | សំណង់ដែលមានឧបនិស្ស័យខាងអប់រំ វប្បធម៌ និងសុខាភិបាល ÷ កីឡដ្ឋាន អគារកីឡា មហោស្រព រោងកុន សាលពិពណ៌ សាលសន្និសីទ រោងល្ខោន រោងសៀក គ្រឹះស្ថានអប់រំ គ្រប់ប្រភេទ មណ្ឌលសុខភាព សម្ភព គ្លីនិក ប្រភេទសំណង់អប់រំវប្បធម៌ និងសុខាភិបាលផ្សេងទៀត | | | | | |
| ៤៦ | | - ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² ដល់ ៤ ០០០ ម² | ៧ ៤០០ ០០០ | ៧ ០០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៤៧ | | - ផ្ទៃក្រឡាសំណង់ លើសពី ៤ ០០០ ម² ដល់ ៥ ០០០ ម² | ៧ ៧៥០ ០០០ | ៧ ៣៥០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៤៨ | | - ផ្ទៃក្រឡាសំណង់ លើសពី ៥ ០០០ ម² ដល់ ៦ ០០០ ម² | ៨ ១៥០ ០០០ | ៧ ៧៥០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៤៩ | | - ផ្ទៃក្រឡាសំណង់ លើសពី ៦ ០០០ ម² ដល់ ៨ ០០០ ម² | ៨ ៥០០ ០០០ | ៨ ១០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៥០ | | - ផ្ទៃក្រឡាសំណង់ លើសពី ៨ ០០០ ម² ដល់ ១០ ០០០ ម² | ៨ ៨៥០ ០០០ | ៨ ៤៥០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៥១ | | - ផ្ទៃក្រឡាសំណង់ លើសពី ១០ ០០០ ម² ដល់ ២០ ០០០ ម² | ៩ ៦០០ ០០០ | ៩ ២០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៥២ | | - ផ្ទៃក្រឡាសំណង់ លើសពី ២០ ០០០ ម² ដល់ ៣០ ០០០ ម² | ៩ ៦៧០ ០០០ | ៩ ២៧០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៥៣ | | - ផ្ទៃក្រឡាសំណង់ លើសពី ៣០ ០០០ ម² ដល់ ៤០ ០០០ ម² | ៩ ៨០០ ០០០ | ៩ ៤០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៥៤ | | - ផ្ទៃក្រឡាសំណង់ លើសពី ៤០ ០០០ ម² ដល់ ៥០ ០០០ ម² | ៩ ៨៣០ ០០០ | ៩ ៤៣០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៥៥ | | - ផ្ទៃក្រឡាសំណង់ លើសពី ៥០ ០០០ ម² ដល់ ៦០ ០០០ ម² | ៩ ៩០០ ០០០ | ៩ ៥០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៥៦ | | - ផ្ទៃក្រឡាសំណង់ លើសពី ៦០ ០០០ ម² ដល់ ៧០ ០០០ ម² | ៩ ៩៣០ ០០០ | ៩ ៥៣០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៥៧ | | - ផ្ទៃក្រឡាសំណង់ លើសពី ៧០ ០០០ ម² ដល់ ៨០ ០០០ ម² | ៩ ៩៧០ ០០០ | ៩ ៥៧០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៥៨ | | - ផ្ទៃក្រឡាសំណង់ លើសពី ៨០ ០០០ ម² ដល់ ៩០ ០០០ ម² | ១០ ០០០ ០០០ | ៩ ៦០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៥៩ | | - ផ្ទៃក្រឡាសំណង់ លើសពី ៩០ ០០០ ម² ដល់ ១០០ ០០០ ម² | ១០ ១០០ ០០០ | ៩ ៧០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៦០ | | - ផ្ទៃក្រឡាសំណង់ លើសពី ១០០ ០០០ ម² | បូកបន្ថែមក្នុង ១ម² ស្មើ ៩៨រៀល | បូកបន្ថែមក្នុង ១ម² ស្មើ ៩៦រៀល | ៤៥ថ្ងៃ | ១ឆ្នាំ | |

| លេខរៀងចំនួនសេវា | បរិយាយ | តម្លៃសេវា (ជារៀល) | | រយៈពេលអតិបរមា នៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|---|
| | | ខណ្ឌក្នុងរាជធានី និងក្នុងក្រុង | ខណ្ឌជាយរាជធានី និងក្រៅក្រុង | | | |
| | ១.៥ សំណង់ដែលមានឧបនិស្ស័យខាងកសិកម្ម÷ កសិដ្ឋានចិញ្ចឹមសត្វ រោងចិញ្ចឹមសត្វ រោងម៉ាស៊ីនកិនស្រូវ ឃ្លាំងដាក់កសិផល ឃ្លាំងជី អគារបំពីរពងពាសម្ព័ន្ធកសិកម្ម និងប្រភេទសំណង់កសិកម្មផ្សេងទៀត | | | | | |
| ៦១ | - ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² ដល់ ៤ ០០០ ម² | ៥ ៥០០ ០០០ | ៥ ៣០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៦២ | - ផ្ទៃក្រឡាសំណង់ លើសពី ៤ ០០០ ម² ដល់ ៥ ០០០ ម² | ៥ ៧០០ ០០០ | ៥ ៥០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៦៣ | - ផ្ទៃក្រឡាសំណង់ លើសពី ៥ ០០០ ម² ដល់ ៦ ០០០ ម² | ៥ ៩០០ ០០០ | ៥ ៧០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៦៤ | - ផ្ទៃក្រឡាសំណង់ លើសពី ៦ ០០០ ម² ដល់ ៨ ០០០ ម² | ៦ ១០០ ០០០ | ៥ ៩០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៦៥ | - ផ្ទៃក្រឡាសំណង់ លើសពី ៨ ០០០ ម² ដល់ ១០ ០០០ ម² | ៦ ៣០០ ០០០ | ៦ ១០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៦៦ | - ផ្ទៃក្រឡាសំណង់ លើសពី ១០ ០០០ ម² ដល់ ២០ ០០០ ម² | ៦ ៨០០ ០០០ | ៦ ៦០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៦៧ | - ផ្ទៃក្រឡាសំណង់ លើសពី ២០ ០០០ ម² ដល់ ៣០ ០០០ ម² | ៧ ០០០ ០០០ | ៦ ៨០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៦៨ | - ផ្ទៃក្រឡាសំណង់ លើសពី ៣០ ០០០ ម² ដល់ ៤០ ០០០ ម² | ៧ ៤០០ ០០០ | ៧ ២០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៦៩ | - ផ្ទៃក្រឡាសំណង់ លើសពី ៤០ ០០០ ម² ដល់ ៥០ ០០០ ម² | ៧ ៨០០ ០០០ | ៧ ៦០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៧០ | - ផ្ទៃក្រឡាសំណង់ លើសពី ៥០ ០០០ ម² ដល់ ៦០ ០០០ ម² | ៨ ២០០ ០០០ | ៨ ០០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៧១ | - ផ្ទៃក្រឡាសំណង់ លើសពី ៦០ ០០០ ម² ដល់ ៧០ ០០០ ម² | ៨ ៦០០ ០០០ | ៨ ៤០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៧២ | - ផ្ទៃក្រឡាសំណង់ លើសពី ៧០ ០០០ ម² ដល់ ៨០ ០០០ ម² | ៩ ០០០ ០០០ | ៨ ៨០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៧៣ | - ផ្ទៃក្រឡាសំណង់ លើសពី ៨០ ០០០ ម² ដល់ ៩០ ០០០ ម² | ១០ ០០០ ០០០ | ៩ ៦០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៧៤ | - ផ្ទៃក្រឡាសំណង់ លើសពី ៩០ ០០០ ម² ដល់ ១០០ ០០០ ម² | ១០ ១០០ ០០០ | ៩ ៧០០ ០០០ | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៧៥ | - ផ្ទៃក្រឡាសំណង់ លើសពី ១០០ ០០០ ម² | បូកបន្ថែមក្នុង ១ម² ស្មើ ៩៨រៀល | បូកបន្ថែមក្នុង ១ម² ស្មើ ៩៦រៀល | ៤៥ថ្ងៃ | ១ឆ្នាំ | |
| | ១.៦ លិខិតអនុញ្ញាតរុះរើ | | | | | |
| ៧៦ | - ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² | គិត ២០% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ នៅតាមទំហំដែល រុះរើជាក់ស្ដែង | | ២០ថ្ងៃ | ១ឆ្នាំ | |

| លេខរៀង ចំនួន សេវា | បរិយាយ | | តម្លៃសេវា (ជារៀល) ចំណុះក្នុងរាជធានី និងក្នុងក្រុង | ចំណុះជាយរាជធានី និងក្រៅក្រុង | រយៈពេលអតិបរមា នៃការផ្ដល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|---|---|
| | ១.៧ | លិខិតអនុញ្ញាតជួសជុល | | | | | |
| ៧៧ | - | ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² | គិត ៥០% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ នៅតាមទំហំដែល ជួសជុលជាក់ស្ដែង | | ២០ថ្ងៃ | ១ឆ្នាំ | |
| | ១.៨ | លិខិតអនុញ្ញាតរុះរើ និងជួសជុល | | | | | |
| ៧៨ | - | ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² | គិត ៥០% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ នៅតាមទំហំ ដែលរុះរើ ឬ/និងជួសជុលជាក់ស្ដែង | | ២០ថ្ងៃ | ១ឆ្នាំ | |
| | ១.៩ | លិខិតអនុញ្ញាតរុះរើ ជួសជុល និងសាងសង់ពង្រីកបន្ថែម | | | | | |
| ៧៩ | - | ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² | គិត ៥០% នៃតម្លៃសេវាអនុញ្ញាតសាងសង់ នៅតាមទំហំ ដែលរុះរើ ឬ/និង ជួសជុលជាក់ស្ដែង និង ១០០% នៃតម្លៃសេវាអនុញ្ញាតសាងសង់ នៅតាមទំហំដែលពង្រីកបន្ថែម | | ៤៥ថ្ងៃ | ១ឆ្នាំ | |
| ៨០ | ១.១០ | លិខិតអនុញ្ញាតសាងសង់ពង្រីកបន្ថែម ឬ បន្ថែមជាន់ | គិត ១០០% (ដូចលិខិតអនុញ្ញាតសាងសង់) | | ៤៥ថ្ងៃ | ១ឆ្នាំ | |
| | ១.១១ | លិខិតស្នើសុំកែសម្រួលប្លង់សរុប ឬ ប្លង់ស្ថាបត្យកម្ម ឬ ប្ដូរសោភ័ណភាព ឬ ប្ដូរមុខងារប្រើប្រាស់អគារ (ករណីរក្សាក្រឡាផ្ទៃសំណង់សរុបដដែល) | | | | | |
| ៨១ | - | ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² | គិត ២០% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ | | ៤៥ថ្ងៃ | ១ឆ្នាំ | |
| | ១.១២ | លិខិតស្នើសុំកែសម្រួលប្លង់សរុប ឬ ប្លង់ស្ថាបត្យកម្ម ឬ ប្ដូរសោភ័ណភាព ឬ ប្ដូរមុខងារប្រើប្រាស់អគារ (ករណីមានបន្ថែមក្រឡាផ្ទៃសំណង់) | | | | | |
| ៨២ | - | ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² | គិត ៥០% នៃតម្លៃលិខិតអនុញ្ញាតសាងសង់នៅតាមទំហំដែលកែសម្រួលប្លង់សរុប ឬ ប្លង់ស្ថាបត្យកម្ម ឬ ប្ដូរសោភ័ណភាព ឬ ប្ដូរមុខងារប្រើប្រាស់អគារ និង ១០០% នៃតម្លៃសុំលិខិតអនុញ្ញាតសាងសង់ នៅតាមទំហំសំណង់បន្ថែម | | ៤៥ថ្ងៃ | ១ឆ្នាំ | |

| លេខរៀងចំនួនសេវា | | បរិយាយ | តម្លៃសេវា (ជារៀល) | | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | | តំបន់ក្នុងរាជធានី និងក្នុងក្រុង | តំបន់ជាយរាជធានី និងក្រៅក្រុង | | | |
| | ១.១៣ | លិខិតស្នើសុំធ្វើនិយ័តកម្ម ចំពោះសំណង់ដែលបានសាងសង់រួច | | | | | |
| ៨៣ | | - ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² | គិតដូចតម្លៃសេវាស្នើសុំលិខិតអនុញ្ញាតសាងសង់ (មិនរាប់បញ្ចូលការពិន័យអន្តរកាល និងទណ្ឌកម្មផ្សេងៗដែលអាចមាន) | | ៤៥ថ្ងៃ | | |
| | ១.១៤ | លិខិតអនុញ្ញាតបើកការដ្ឋាន | | | | | |
| ៨៤ | | - ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² | គិត ២០% នៃតម្លៃស្នើសុំលិខិតអនុញ្ញាតសាងសង់ | | ៧ថ្ងៃ | | |
| | ១.១៥ | វិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ និងបិទការដ្ឋាន | | | | | |
| ៨៥ | | - ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម² | គិត ២០% នៃតម្លៃស្នើសុំលិខិតអនុញ្ញាតសាងសង់ | | ៧ថ្ងៃ | | |
| ៨៦ | ១.១៦ | ប្តូរឈ្មោះក្នុងលិខិតអនុញ្ញាតសាងសង់ និងប្តូរស្លាកសញ្ញាពាណិជ្ជកម្ម | ៤ ០០០ ០០០ | | ៤៥ថ្ងៃ | | |
| ៨៧ | ១.១៧ | ប្តូរឈ្មោះក្នុងលិខិតអនុញ្ញាតបើក ឬ បិទការដ្ឋានសាងសង់ | ១ ០០០ ០០០ | | ៧ថ្ងៃ | | |
| ៨៨ | ១.១៨ | បន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ (ក្នុងករណីមិនចាប់ផ្តើមសាងសង់បន្ទាប់ពីការអនុញ្ញាតបាន ១ឆ្នាំ និងក្នុងករណីមិនមានលិខិតអនុញ្ញាតបើកការដ្ឋានសាងសង់) | គិត ៥០% នៃតម្លៃស្នើសុំលិខិតអនុញ្ញាតសាងសង់ | | ២០ថ្ងៃ | | |
| ៨៩ | ១.១៩ | បន្តសុពលភាពលិខិតអនុញ្ញាត ដូចមានចែងក្នុងចំណុច ១.៦, ១.៧, ១.៨, ១.៩, ១.១០, ១.១១, ១.១២, ១.១៣ និង ១.១៤ (ក្នុងករណីមិនចាប់ផ្តើមដំណើរការ បន្ទាប់ពីការអនុញ្ញាតបាន ០១ឆ្នាំ) | គិត ២០% នៃតម្លៃស្នើសុំលិខិតអនុញ្ញាតសាងសង់ | | ២០ថ្ងៃ | | |
| ៩០ | ១.២០ | សំណង់ដែលមានឧបនិស្ស័យខាងជំនឿសាសនា (ព្រះវិហារ វត្តអារាម ទីសក្ការៈបូជា..... មិនគិតថ្លៃទាំងសុំលិខិតអនុញ្ញាត ទាំងបើកការដ្ឋាន ទាំងវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវ និងបិទការដ្ឋាន) | | | | | |
| ៩១ | ១.២១ | សំណង់អគារដែលបំពេញសេវាសាធារណៈរបស់រដ្ឋ សំណង់រដ្ឋ សំណង់សម្បទានសង្គមកិច្ច សប្បុរសជន អង្គការមនុស្សធម៌ អំណោយជូនសហគមន៍ ឬ ជនក្រីក្រ សហគមន៍ អង្គការវេសនដ្ឋានសង្គម........ (មិនគិតថ្លៃទាំងសុំលិខិតអនុញ្ញាត ទាំងបើកការដ្ឋាន ទាំងវិញ្ញាបនបត្របញ្ជាក់ភាពត្រឹមត្រូវនិងបិទការដ្ឋាន) | | | | | |

| លេខរៀងចំនួនសេវា | | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលអតិបរមានៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| | ២ | សេវាផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្លូវការ | | | | |
| ៩២ | - | ថ្លៃក្រឡាសំណង់ ចាប់ពី ១០០ ម$^{២}$ ចុះក្រោម | ២ 000 000 | ៣០ថ្ងៃ | | |
| ៩៣ | - | ថ្លៃក្រឡាសំណង់ លើសពី ១០០ ម$^{២}$ ដល់ ២០០ ម$^{២}$ | ៤ 000 000 | ៣០ថ្ងៃ | | |
| ៩៤ | - | ថ្លៃក្រឡាសំណង់ លើសពី ២០០ ម$^{២}$ ដល់ ៣០០ ម$^{២}$ | ៦ 000 000 | ៣០ថ្ងៃ | | |
| ៩៥ | - | ថ្លៃក្រឡាសំណង់ លើសពី ៣០០ ម$^{២}$ ដល់ ៤០០ ម$^{២}$ | ៨ 000 000 | ៣០ថ្ងៃ | | |
| ៩៦ | - | ថ្លៃក្រឡាសំណង់ លើសពី ៤០០ ម$^{២}$ ដល់ ៥០០ ម$^{២}$ | ១០ 000 000 | ៣០ថ្ងៃ | | |
| ៩៧ | - | ថ្លៃក្រឡាសំណង់ លើសពី ៥០០ ម$^{២}$ ដល់ ៦០០ ម$^{២}$ | ១២ 000 000 | ៣០ថ្ងៃ | | |
| ៩៨ | - | ថ្លៃក្រឡាសំណង់ លើសពី ៦០០ ម$^{២}$ ដល់ ៧០០ ម$^{២}$ | ១៤ 000 000 | ៣០ថ្ងៃ | | |
| ៩៩ | - | ថ្លៃក្រឡាសំណង់ លើសពី ៧០០ ម$^{២}$ ដល់ ៨០០ ម$^{២}$ | ១៦ 000 000 | ៣០ថ្ងៃ | | |
| ១០០ | - | ថ្លៃក្រឡាសំណង់ លើសពី ៨០០ ម$^{២}$ ដល់ ៩០០ ម$^{២}$ | ១៨ 000 000 | ៣០ថ្ងៃ | | |
| ១០១ | - | ថ្លៃក្រឡាសំណង់ លើសពី ៩០០ ម$^{២}$ ដល់ ១ 000 ម$^{២}$ | ២០ 000 000 | ៣០ថ្ងៃ | | |
| ១០២ | - | ថ្លៃក្រឡាសំណង់ លើសពី ១ 000 ម$^{២}$ ដល់ ១ ៥០០ ម$^{២}$ | ៣០ 000 000 | ៣០ថ្ងៃ | | |
| ១០៣ | - | ថ្លៃក្រឡាសំណង់ លើសពី ១ ៥០០ ម$^{២}$ ដល់ ២ 000 ម$^{២}$ | ៤០ 000 000 | ៣០ថ្ងៃ | | |
| ១០៤ | - | ថ្លៃក្រឡាសំណង់ លើសពី ២ 000 ម$^{២}$ ដល់ ២ ៥០០ ម$^{២}$ | ៥០ 000 000 | ៣០ថ្ងៃ | | |
| ១០៥ | - | ថ្លៃក្រឡាសំណង់ លើសពី ២ ៥០០ ម$^{២}$ ដល់ ៣ 000 ម$^{២}$ | ៦០ 000 000 | ៣០ថ្ងៃ | | |
| ១០៦ | - | ថ្លៃក្រឡាសំណង់ លើសពី ៣ 000 ម$^{២}$ ដល់ ៣ ៥០០ ម$^{២}$ | ៧០ 000 000 | ៣០ថ្ងៃ | | |
| ១០៧ | - | ថ្លៃក្រឡាសំណង់ លើសពី ៣ ៥០០ ម$^{២}$ ដល់ ៤ 000 ម$^{២}$ | ៨០ 000 000 | ៣០ថ្ងៃ | | |
| ១០៨ | - | ថ្លៃក្រឡាសំណង់ លើសពី ៤ 000 ម$^{២}$ ដល់ ៤ ៥០០ ម$^{២}$ | ៩០ 000 000 | ៣០ថ្ងៃ | | |
| ១០៩ | - | ថ្លៃក្រឡាសំណង់ លើសពី ៤ ៥០០ ម$^{២}$ ដល់ ៥ 000 ម$^{២}$ | ១០០ 000 000 | ៣០ថ្ងៃ | | |
| ១១០ | - | ថ្លៃក្រឡាសំណង់ លើសពី ៥ 000 ម$^{២}$ ដល់ ៥ ៥០០ ម$^{២}$ | ១១០ 000 000 | ៣០ថ្ងៃ | | |

| | | | | | | |
|---|---|---|---|---|---|---|
| ១១១ | | - ផ្ទៃក្រឡាសំណង់ លើសពី ៥ ៥០០ ម² ដល់ ៦ ០០០ ម² | ១២០ ០០០ ០០០ | ៣០ថ្ងៃ | | |
| លេខរៀង ចំនួន សេវា | | បរិយាយ | តម្លៃសេវា (ជារៀល) | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
| ១១២ | | - ផ្ទៃក្រឡាសំណង់ លើសពី ៦ ០០០ ម² ដល់ ៦ ៥០០ ម² | ១៣០ ០០០ ០០០ | ៣០ថ្ងៃ | | |
| ១១៣ | | - ផ្ទៃក្រឡាសំណង់ លើសពី ៦ ៥០០ ម² ដល់ ៧ ០០០ ម² | ១៤០ ០០០ ០០០ | ៣០ថ្ងៃ | | |
| ១១៤ | | - ផ្ទៃក្រឡាសំណង់ លើសពី ៧ ០០០ ម² ដល់ ៧ ៥០០ ម² | ១៥០ ០០០ ០០០ | ៣០ថ្ងៃ | | |
| ១១៥ | | - ផ្ទៃក្រឡាសំណង់ លើសពី ៧ ៥០០ ម² ដល់ ៨ ០០០ ម² | ១៦០ ០០០ ០០០ | ៣០ថ្ងៃ | | |
| ១១៦ | | - ផ្ទៃក្រឡាសំណង់ លើសពី ៨ ០០០ ម² ដល់ ៨ ៥០០ ម² | ១៧០ ០០០ ០០០ | ៣០ថ្ងៃ | | |
| ១១៧ | | - ផ្ទៃក្រឡាសំណង់ លើសពី ៨ ៥០០ ម² ដល់ ៩ ០០០ ម² | ១៨០ ០០០ ០០០ | ៣០ថ្ងៃ | | |
| ១១៨ | | - ផ្ទៃក្រឡាសំណង់ លើសពី ៩ ០០០ ម² ដល់ ៩ ៥០០ ម² | ១៩០ ០០០ ០០០ | ៣០ថ្ងៃ | | |
| ១១៩ | | - ផ្ទៃក្រឡាសំណង់ លើសពី ៩ ៥០០ ម² ដល់ ១០ ០០០ ម² | ២០០ ០០០ ០០០ | ៣០ថ្ងៃ | | |
| ១២០ | | - ផ្ទៃក្រឡាសំណង់ លើសពី ១០ ០០០ ម² ដល់ ១៥ ០០០ ម² | ៣០០ ០០០ ០០០ | ៣០ថ្ងៃ | | |
| ១២១ | | - ផ្ទៃក្រឡាសំណង់ លើសពី ១៥ ០០០ ម² ដល់ ២០ ០០០ ម² | ៤០០ ០០០ ០០០ | ៣០ថ្ងៃ | | |
| ១២២ | | - ផ្ទៃក្រឡាសំណង់ លើសពី ២០ ០០០ ម² | ៥០០ ០០០ ០០០ | ៣០ថ្ងៃ | | |
| | ៣ | ការផ្តល់គោលការណ៍សាងសង់ និងអភិវឌ្ឍដី | | | | |
| ១២៣ | ៣.១ | គោលការណ៍សាងសង់អង់តែនក្នុង ០១កន្លែង | ២ ០០០ ០០០ | ៤៥ថ្ងៃ | | |
| ១២៤ | ៣.២ | គោលការណ៍បញ្ចូនខ្សែកាបអុបទិចកប់ក្នុងដី (ក្នុង ១ករណី) | ២០ ០០០ ០០០ | ២០ថ្ងៃ | | |
| ១២៥ | ៣.២ | គោលការណ៍សាងសង់អគារក្នុងដីឡូតិ៍ (តាមការស្នើសុំ) | ៤ ០០០ ០០០ | ២៥ថ្ងៃ | | |
| | ៣.៣ | លិខិតអនុញ្ញាតជាគោលការណ៍ ឬ លិខិតអនុញ្ញាតអភិវឌ្ឍដី ពីដីកសិកម្ម ទៅដីសាងសង់ (សម្រាប់លំនៅឋានក្នុងគោលបំណងពាណិជ្ជកម្ម ពាណិជ្ជកម្ម និងឧស្សាហកម្ម ...) | | | | |
| ១២៦ | | - ទំហំក្រោម ១០ហិកតា (ក្នុងដី ១ម²) | ២០០ | ៤៥ថ្ងៃ | | |
| ១២៧ | | - ទំហំចាប់ពី ១០ហិកតាឡើង (គិតសរុប) | ២០ ០០០ ០០០ | ៤៥ថ្ងៃ | | |
| | ៤ | ការចុះត្រួតពិនិត្យ និងបញ្ជាក់សុវត្ថិភាពសំណង់ហេងចក្រផ្ទៃកវាយនភ័ណ្ឌកាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង | | | | |
| ១២៨ | | - ផ្ទៃក្រឡាសំណង់ ចាប់ពី ៣ ០០០ ម² ចុះក្រោម | ៨ ០០០ ០០០ | ១៥ថ្ងៃ | | |

| លេខរៀង ចំនួន សេវា | | បរិយាយ | ទំហំ ម$^2$ | តម្លៃសេវា (ជារៀល) | | | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|---|---|---|
| | | | | ខណ្ឌក្នុងរាជធានី និងក្រុង | ខណ្ឌជាយរាជធានី និងទីរួមស្រុក | ក្រៅក្រុង និង ក្រៅទីរួមស្រុក | | | |
| ១២៩ | - | ផ្ទៃក្រឡាសំណង់ លើសពី ៣ ០០០ ម$^2$ ដល់ ១០ ០០០ ម$^2$ | | ១២ ០០០ ០០០ | | | ១៥ថ្ងៃ | | |
| ១៣០ | - | ផ្ទៃក្រឡាសំណង់ លើសពី ១០ ០០០ ម$^2$ | | ១៦ ០០០ ០០០ | | | ១៥ថ្ងៃ | | |
| | ៥ | ការផ្តល់លិខិតបញ្ជាក់ពីការត្រួតពិនិត្យ និងធ្វើកោសល្យវិច័យសំណង់អគារ (សម្រាប់សំណើមានលក្ខណៈជាឯកជន) (តាមការស្នើសុំ) | | | | | | | |
| ១៣១ | ៥.១ | សំណង់គ្រប់ប្រភេទ | តូចជាង ឬ ស្មើ ៣០០ ម$^2$ | ២ ០០០ ០០០ | ២ ៥០០ ០០០ | ៣ ០០០ ០០០ | ១៥ថ្ងៃ | | |
| ១៣២ | | ពិនិត្យជាផ្នែកៗ (១ផ្នែក) | | ៤០០ ០០០ | ៥០០ ០០០ | ៦០០ ០០០ | ៥ថ្ងៃ | | |
| ១៣៣ | ៥.២ | សំណង់គ្រប់ប្រភេទ | តូចជាង ឬ ស្មើ ១ ០០០ ម$^2$ | ៤ ០០០ ០០០ | ៤ ៥០០ ០០០ | ៥ ០០០ ០០០ | ១៥ថ្ងៃ | | |
| ១៣៤ | | ពិនិត្យជាផ្នែកៗ (១ផ្នែក) | | ៦០០ ០០០ | ៧០០ ០០០ | ៨០០ ០០០ | ៥ថ្ងៃ | | |
| ១៣៥ | ៥.៣ | សំណង់គ្រប់ប្រភេទ | តូចជាង ឬ ស្មើ ៣ ០០០ ម$^2$ | ៦ ០០០ ០០០ | ៦ ៥០០ ០០០ | ៧ ០០០ ០០០ | ២០ថ្ងៃ | | |
| ១៣៦ | | ពិនិត្យជាផ្នែកៗ (១ផ្នែក) | | ៨០០ ០០០ | ១ ០០០ ០០០ | ១ ២០០ ០០០ | ៥ថ្ងៃ | | |
| ១៣៧ | ៥.៤ | សំណង់គ្រប់ប្រភេទ | តូចជាង ឬ ស្មើ ៦ ០០០ ម$^2$ | ៨ ០០០ ០០០ | ១០ ០០០ ០០០ | ១២ ០០០ ០០០ | ៣០ថ្ងៃ | | |
| ១៣៨ | | ពិនិត្យជាផ្នែកៗ (១ផ្នែក) | | ១ ០០០ ០០០ | ១ ២០០ ០០០ | ១ ៤០០ ០០០ | ១៥ថ្ងៃ | | |
| ១៣៩ | ៥.៥ | សំណង់គ្រប់ប្រភេទ | តូចជាង ឬ ស្មើ ១០០០០ម$^2$ | ១០ ០០០ ០០០ | ១២ ០០០ ០០០ | ១៤ ០០០ ០០០ | ៣៥ថ្ងៃ | | |
| ១៤០ | | ពិនិត្យជាផ្នែកៗ (១ផ្នែក) | | ១ ២០០ ០០០ | ១ ៤០០ ០០០ | ១ ៦០០ ០០០ | ១៧ថ្ងៃ | | |
| ១៤១ | ៥.៦ | សំណង់គ្រប់ប្រភេទ | លើសពី ១០០០០ម$^2$ | ១២ ០០០ ០០០ | ១៤ ០០០ ០០០ | ១៦ ០០០ ០០០ | ៤០ថ្ងៃ | | |
| ១៤២ | | ពិនិត្យជាផ្នែកៗ (១ផ្នែក) | | ១ ៦០០ ០០០ | ១ ៨០០ ០០០ | ២ ០០០ ០០០ | ២០ថ្ងៃ | | |

 [illegible]

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

លេខ: ០២៥៥ ដ.នស/គ.ដ.នជ

ថ្ងៃអង្គារ ៩ កើត ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០១៨

**ជម្រាបជូន**

**ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្ត និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ**

**កម្មវត្ថុ:** សេចក្តីណែនាំបន្ថែមស្តីពីការរៀបចំការដ្ឋានសាងសង់សំណង់អគារគ្រប់ប្រភេទ នៅខេត្តព្រះសីហនុ

**យោង:** - ព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

- អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- សារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- ប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម** អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ ជ្រាបថា ដើម្បីធានាបានការអភិវឌ្ឍប្រកបដោយចីរភាព ផាសុកភាព សោភ័ណភាព និងសុវត្ថិភាព នៅខេត្តព្រះសីហនុ រាល់ការដ្ឋានសាងសង់សំណង់អគារគ្រប់ប្រភេទ ត្រូវ÷

១. ធ្វើរបងហ៊ុំព័ទ្ធការដ្ឋានសំណង់កម្ពស់យ៉ាងតិច ២ (ពីរ) ម៉ែត្រ ពីនីវ៉ូ ០ (សូន្យ) នៃគម្រោង ដែលក្នុងនេះត្រូវរៀបជើងរបងអំពីថ្មកម្ពស់យ៉ាងតិច ៨០ (ប៉ែតសិប) សង់ទីម៉ែត្រ ដើម្បីកុំឱ្យដី សំណល់រឹងនិងរាវ ហៀរចេញពីការដ្ឋានទៅលើផ្លូវ ចិញ្ចើមផ្លូវ ដីចំណីឆ្នេរ ឆ្នេរសមុទ្រ សមុទ្រ ព្រែក អូរ បឹង និងទីតាំងសាធារណៈ ក្នុងគោលដៅធានាសុវត្ថិភាព សណ្តាប់ធ្នាប់ អនាម័យ សោភ័ណភាព និងបរិស្ថានសាធារណៈ។

២. រក្សាទុកចញ្ចើមផ្លូវឱ្យបានទូលាយយ៉ាងតិចស្មើនឹងពីរភាគបីនៃប្រវែងទទឹងចិញ្ចើមផ្លូវ សម្រាប់ឱ្យអ្នកថ្មើរជើងធ្វើដំណើរប្រកបដោយសុវត្ថិភាព។

៣. រៀបចំទុកដាក់សំភារៈសំណង់ គ្រឿងចក្រ ឧបករណ៍សាងសង់ ការិយាល័យការងារ រោងជាង កន្លែងស្នាក់នៅរបស់កម្មករ ក្នុងបរិវេណរបងហ៊ុំព័ទ្ធការដ្ឋានសាងសង់។

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ ១
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

៤.គ្រប់គ្រងសំណល់រឹងនិងរាវ ដោយរៀបចំអាងប្រព្រឹត្តកម្មទឹកកខ្វក់ អាងបង្គន់អនាម័យ និងប្រព័ន្ធលូសម្រាប់ការដ្ឋានសាងសង់មុននឹងបង្ហូរចេញទៅប្រព័ន្ធលូសាធារណៈ ស្របតាមបទដ្ឋានបច្ចេកទេសសំណង់ និងបរិស្ថាន។

៥.រក្សាសុវត្ថិភាព សណ្ដាប់ធ្នាប់ អនាម័យ សោភ័ណភាព បរិស្ថានល្អ និងសុខដុមរមនាជាមួយនឹងអ្នកជិតខាង និងសាធារណៈ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តម** អភិបាលនៃគណៈអភិបាលខេត្ត ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

សូម **ឯកឧត្តម** អភិបាលនៃគណៈអភិបាលខេត្ត ទទួលនូវការរាប់អានពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**
**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

ជា សុផារ៉ា

**<u>ចម្លងជូន៖</u>**
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងទេសចរណ៍
- ក្រសួងបរិស្ថាន
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ០០៥ សសរ

## សេចក្ដីសម្រេច
## ស្ដីពី
## ការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសំណង់
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្ដីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦ ស្ដីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្ដីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ ២០១៥ ស្ដីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- យោងប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០១ ស្ដីពីការគ្រប់គ្រងការដ្ឋានសំណង់
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**ប្រការ ១** : ចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ ដែលមានសមាសភាពដូចមានរាយនាមខាងក្រោម÷

**១. មន្ត្រីត្រួតពិនិត្យសំណង់ទទួលបន្ទុករួម**

| | | |
|---|---|---|
| ១. ឯកឧត្តម **ឆេព ធន** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ឡៅ ឆិញសីហា** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **លាង មុនីរិទ្ធ** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៤. ឯកឧត្តម **ឌុច ចនធីតូ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៥. ឯកឧត្តម **ឆា ចំនួលីដា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៦. ឯកឧត្តម **កើត សារ៉េត** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៧. ឯកឧត្តម **ប៊ិន សម្បត្តិថារ័ត្ន** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៨. ឯកឧត្តម **លី ចណ្ណាសុត្រ** | អនុរដ្ឋលេខាធិការ | សមាជិក |
| ៩. ឯកឧត្តម **ខ្លូត រតនា** | អនុរដ្ឋលេខាធិការ | សមាជិក |
| ១០. លោកជំទាវ **សេរី សុរិយា** | អនុរដ្ឋលេខាធិការ | សមាជិកា |
| ១១. ឯកឧត្តម **សេង ឡុត** | អគ្គនាយករដ្ឋបាល | សមាជិក |
| ១២. ឯកឧត្តម **ឆាយ ឫទ្ធិសែន** | អគ្គនាយករៀបចំដែនដី និងនគរូបនីយកម្ម | សមាជិក |
| ១៣. ឯកឧត្តម **ឡោ ដាទុន** | អគ្គនាយកសុរិយោដី និងភូមិសាស្ត្រ | សមាជិក |
| ១៤. ឯកឧត្តម **បេងហុង សុជាតិខេមរ៉ូ** | អគ្គនាយកលំនៅឋាន | សមាជិក |
| ១៥. ឯកឧត្តម **ឆាន់ សូរ្យផល** | អគ្គនាយកសំណង់ | សមាជិកអចិន្ត្រៃយ៍ |
| ១៦. លោក **អ៊ុត សំអាន** | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន | សមាជិក |
| ១៧. លោក **អេ ប៊ុនធឿន** | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |

**២. មន្ត្រីត្រួតពិនិត្យសំណង់រាជធានី ខេត្ត**

**ក. ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ និងខេត្តក្រចេះ**

| | | |
|---|---|---|
| ១. ឯកឧត្តម **កើត សារ៉េត** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **សាយ និដ្ឋា** | ទីប្រឹក្សាក្រសួង | អនុប្រធាន |
| ៣. លោក **ជា ផលរី** | អគ្គនាយករង | អនុប្រធាន |
| ៤. លោក **ផល សុគំណា** | អនុប្រធានមន្ទីរពិសោធន៍ | សមាជិក |
| ៥. លោក **ចាន់ គុគអូច** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦. លោក **ហ៊ុន សត្យា** | អនុប្រធានការិយាល័យ | សមាជិក |
| ៧. លោក **ជួន ស៊ីទុន** | អនុប្រធានការិយាល័យ | សមាជិក |

| | | |
|---|---|---|
| ៨. លោក **កែច ដាវីន** | អនុប្រធានការិយាល័យ | សមាជិក |
| ៩. លោក **ហ៊ី ចន្ថា** | អនុប្រធានការិយាល័យ | សមាជិក |
| ១០. លោក **ហុង ស្រ៊ុន** | អនុប្រធានការិយាល័យ | សមាជិក |
| ១១. លោក **ចាន់ ធម្ម** | អនុប្រធានការិយាល័យ | សមាជិក |
| ១២. លោក **ឈង សុគ័ណា** | អនុប្រធានការិយាល័យ | សមាជិក |
| ១៣. លោក **ឥន ធរី** | អនុប្រធានការិយាល័យ | សមាជិក |
| ១៤. លោក **ផាត់ បូរី** | មន្ត្រី | សមាជិក |
| ១៥. លោក **នឿម ច្បាក់តូ** | មន្ត្រី | សមាជិក |
| ១៦. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ | | សមាជិកអចិន្ត្រៃយ៍ |
| ១៧. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ | | លេខាធិការ |

**ខ.ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង**

| | | |
|---|---|---|
| ១. ឯកឧត្តម **លាង មុនីរិទ្ធ** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ហាង ប៊ុណ្ណាក់** | ទីប្រឹក្សាក្រសួង | អនុប្រធាន |
| ៣. លោក **ឆេង ទ៉ាន់ថា** | អគ្គនាយករង | អនុប្រធាន |
| ៤. លោក **ហាយ ពន្លក** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥. លោក **ប៉ុល ថាច័ន្ទ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦. លោក **ប៊ុន ធារមី** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧. លោក **យ៉ង់ សុបញ្ញា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៨. លោក **ហេង សុតា** | អនុប្រធានការិយាល័យ | សមាជិក |
| ៩. លោក **ប៊ុល រ៉ានី** | អនុប្រធានការិយាល័យ | សមាជិក |
| ១០. លោក **វ៉ែន កែវខ្សៀ** | អនុប្រធានការិយាល័យ | សមាជិក |
| ១១. លោក **សូរ សាមី** | អនុប្រធានការិយាល័យ | សមាជិក |
| ១២. លោក **ហេង ហាក់** | អនុប្រធានការិយាល័យ | សមាជិក |
| ១៣. លោក **ខួន សុខវិសាល** | អនុប្រធានការិយាល័យ | សមាជិក |
| ១៤. លោក **អ៊ុង ខួនសុខ** | មន្ត្រី | សមាជិក |
| ១៥. លោក **ម៉ាច ហ៊ួ** | មន្ត្រី | សមាជិក |
| ១៦. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ | | សមាជិកអចិន្ត្រៃយ៍ |
| ១៧. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ | | លេខាធិការ |

**គ.រាជធានីភ្នំពេញ**

| | | |
|---|---|---|
| ១. ឯកឧត្តម **ឌុច ធនធីតូ** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **អ៊ឹម ចំរុង** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

| | | |
|---|---|---|
| ៣. ឯកឧត្តម **ម៉ម សុផាណា** | ទីប្រឹក្សាក្រសួង | អនុប្រធាន |
| ៤. ឯកឧត្តម **ម៉ិញ សំអឿន** | ទីប្រឹក្សាក្រសួង | សមាជិក |
| ៥. លោក **ឆាន់ សុជាតិ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦. លោក **ម៉ីប៉ុក ពន្លឺ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧. លោក **ឈុត សៅ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៨. លោក **ឃី ទុត្ថា** | អនុប្រធានការិយាល័យ | សមាជិក |
| ៩. លោក **គង់ សុគន្ធា** | អនុប្រធានការិយាល័យ | សមាជិក |
| ១០. លោក **កែវ វណ្ណារិន** | អនុប្រធានការិយាល័យ | សមាជិក |
| ១១. លោក **តាំង ប៊ុណ្ណារិទ្ធ** | អនុប្រធានការិយាល័យ | សមាជិក |
| ១២. លោក **ថន ទិត្យា** | មន្ត្រី | សមាជិក |
| ១៣. លោក **តាំង ទីណា** | មន្ត្រី | សមាជិក |
| ១៤. លោក **ខួន សុតបុណ្ណមី** | មន្ត្រី | សមាជិក |
| ១៥. លោក **ពៅ បណ្ឌុល** | មន្ត្រី | សមាជិក |
| ១៦. លោក **សៅ សារពន្លម** | មន្ត្រី | សមាជិក |
| ១៧. លោក **ថាច់ មនោរក្ស** | មន្ត្រី | សមាជិក |
| ១៨. លោក **ខឹម ពិសី** | មន្ត្រី | សមាជិក |
| ១៩. លោក **ច្រាក់ សុផល** | មន្ត្រី | សមាជិក |
| ២០. លោក **ពៅ សុខនី** | មន្ត្រី | សមាជិក |
| ២១. លោក **រឹម រាជ** | កម្មសិក្សាការី | សមាជិក |
| ២២. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ | | សមាជិកអចិន្ត្រៃយ៍ |
| ២៣. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ខណ្ឌគោលដៅ | | លេខាធិការ |

**ឃ. ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ**

| | | |
|---|---|---|
| ១. ឯកឧត្តម **ឆា ច័ន្ទលីដា** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ញ៉ឹន ស៊ុំ** | ទីប្រឹក្សាក្រសួង | អនុប្រធាន |
| ៣. លោក **រ័ត្ន ពិសិដ្ឋ** | អគ្គនាយករង | អនុប្រធាន |
| ៤. លោក **ចាប់ ច័ន្ទថេរា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥. លោក **សេក ច័ន្ទមុន្នី** | អនុប្រធានការិយាល័យ | សមាជិក |
| ៦. លោក **គីម សុគន្ធា** | អនុប្រធានការិយាល័យ | សមាជិក |
| ៧. លោក **សាន សុគី** | អនុប្រធានការិយាល័យ | សមាជិក |
| ៨. លោក **មាស ថន** | អនុប្រធានការិយាល័យ | សមាជិក |

៩. លោក ស្ងួន ឌី មន្ត្រី សមាជិក
១០. លោក ធិ គុណាទិចិត្រ មន្ត្រី សមាជិក
១១. លោក គិត នាគសែន មន្ត្រី សមាជិក
១២. លោក កាំង កោសល្យ មន្ត្រី សមាជិក
១៣. លោក គង់ ចាន់ថន មន្ត្រី សមាជិក
១៤. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ សមាជិកអចិន្ត្រៃយ៍
១៥. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ លេខាធិការ

## ង. ខេត្តព្រះសីហនុ

១. ឯកឧត្តម ឡៅ ធិព្វសីហា រដ្ឋលេខាធិការ ប្រធាន
២. ឯកឧត្តម យស់ ឆោមណារ៉ាឌី អនុរដ្ឋលេខាធិការ អនុប្រធាន
៣. ឯកឧត្តម ហាង្ស សុគសំគារ អនុរដ្ឋលេខាធិការ អនុប្រធាន
៤. លោក លី រស្មី អគ្គនាយករង សមាជិក
៥. លោក ម៉ៅ ត្រឹង អនុប្រធាននាយកដ្ឋាន សមាជិក
៦. លោក លឹម ប៊ុ អនុប្រធាននាយកដ្ឋាន សមាជិក
៧. លោក ឃួន សេរី អនុប្រធាននាយកដ្ឋាន សមាជិក
៨. លោក ឃួន ចាន់ អនុប្រធានការិយាល័យ សមាជិក
៩. លោក គោគ សេរីវុធ អនុប្រធានការិយាល័យ សមាជិក
១០. លោក វ៉ុយ ច៊ា អនុប្រធានការិយាល័យ សមាជិក
១១. លោក សាន ស៊ីវត្ថា អនុប្រធានការិយាល័យ សមាជិក
១២. លោក អន ស៊ីថន អនុប្រធានការិយាល័យ សមាជិក
១៣. លោក នូ សុផុន មន្ត្រី សមាជិក
១៤. លោក ប៊ុយ ម៉ាច មន្ត្រី សមាជិក
១៥. លោក មិន សារមេន មន្ត្រី សមាជិក
១៦. លោក ធូច ហ្វូសេង មន្ត្រី សមាជិក
១៧. លោក ដែក ជឿន មន្ត្រី សមាជិក
១៨. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ សមាជិកអចិន្ត្រៃយ៍
១៩. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ លេខាធិការ

## ច. ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តពោធិ៍សាត់ និងខេត្តប៉ៃលិន

១. ឯកឧត្តម ចិន សម្បត្តិថារ័ត្ន អនុរដ្ឋលេខាធិការ ប្រធាន
២. ឯកឧត្តម ហ៊ុយ ណារ៉ា ទីប្រឹក្សាក្រសួង អនុប្រធាន

| | | |
|---|---|---|
| ៣. ឯកឧត្តម **ជា ស្រ៊ុន** | ទីប្រឹក្សាក្រសួង | អនុប្រធាន |
| ៤. លោក **ជា សំអាត** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥. លោក **ឡេង សេដ្ឋា** | អនុប្រធានការិយាល័យ | សមាជិក |
| ៦. លោក **ម៉ុន សីហាមានី** | អនុប្រធានការិយាល័យ | សមាជិក |
| ៧. លោក **សុក ធី** | អនុប្រធានការិយាល័យ | សមាជិក |
| ៨. លោក **តូច សុផាន់ណារ៉ាក់** | មន្ត្រី | សមាជិក |
| ៩. លោក **ទើ សុថា** | មន្ត្រី | សមាជិក |
| ១០. លោក **ម៉ុច វ៉ូណារ៉ាល់** | មន្ត្រី | សមាជិក |
| ១១. លោក **នី សុបញ្ញា** | មន្ត្រី | សមាជិក |
| ១២. លោក **ឈី សុចណ្ណា** | មន្ត្រី | សមាជិក |
| ១៣. លោក **រស់ សារ៉ាក់មុនី** | មន្ត្រី | សមាជិក |
| ១៤. លោក **ម៉ុម ថារ៉ូ** | មន្ត្រី | សមាជិក |
| ១៥. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ | | សមាជិកអចិន្ត្រៃយ៍ |
| ១៦. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ | | លេខាធិការ |

## ឆ. ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី

| | | |
|---|---|---|
| ១. ឯកឧត្តម **ឈី ចណ្ណាសុត្រា** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. លោក **សាររេត បូរាមី** | អគ្គនាយករង | អនុប្រធាន |
| ៣. លោក **យី យ៉ាណារតន៍** | អគ្គនាយករង | អនុប្រធាន |
| ៤. លោក **ញ៉ៅ ហេង** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥. លោក **អ៊ុំ សារុំ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦. លោក **ជួរ ជិនសុធា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧. លោក **មុង ថារិទ្ធ** | អនុប្រធានការិយាល័យ | សមាជិក |
| ៨. លោក **ជាង ផល្លាយ** | អនុប្រធានការិយាល័យ | សមាជិក |
| ៩. លោក **សិទ្ធ សុភា** | អនុប្រធានការិយាល័យ | សមាជិក |
| ១០. លោក **ហោ ផាន់នី** | អនុប្រធានការិយាល័យ | សមាជិក |
| ១១. លោក **អ៊ុំ ម៉ុនថន** | មន្ត្រី | សមាជិក |
| ១២. លោក **យក់ សំណាង** | មន្ត្រី | សមាជិក |
| ១៣. លោក **អ៊ី ឆទីរ៉ា** | មន្ត្រី | សមាជិក |
| ១៤. លោក **ឃុន សុធី** | មន្ត្រី | សមាជិក |
| ១៥. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ | | សមាជិកអចិន្ត្រៃយ៍ |
| ១៦. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ | | លេខាធិការ |

ជ. ខេត្តតាកែវ ខេត្តកែប ខេត្តកំពត និងខេត្តកោះកុង

| | | |
|---|---|---|
| ១. ឯកឧត្តម **ខ្លូត រតនា** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. លោក **លឹម អ៊ីច** | អគ្គនាយករង | អនុប្រធាន |
| ៣. លោក **ឈឹម សុគន្ធ** | អគ្គនាយករង | អនុប្រធាន |
| ៤. លោក **តាន់ហ៊ាង ហានីដា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥. លោក **ជិន ខៀប** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦. លោក **អ៊ីង វដ្ឋា** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧. លោក **អ៊ុំ សុពុត្រា** | អនុប្រធានការិយាល័យ | សមាជិក |
| ៨. លោក **ម៉ែន បូរ៉ាត** | អនុប្រធានការិយាល័យ | សមាជិក |
| ៩. លោក **យិន គីមហុង** | អនុប្រធានការិយាល័យ | សមាជិក |
| ១០. លោក **ស៊ាង គីមលាង** | អនុប្រធានការិយាល័យ | សមាជិក |
| ១១. លោក **ខៀវ ចិន្ត្រា** | អនុប្រធានការិយាល័យ | សមាជិក |
| ១២. លោក **ម៉ុច ច័ន្ទម៉ារ៉ា** | អនុប្រធានការិយាល័យ | សមាជិក |
| ១៣. លោក **ម៉េង អាន** | អនុប្រធានការិយាល័យ | សមាជិក |
| ១៤. លោក **យន់ លីហួរ** | មន្ត្រី | សមាជិក |
| ១៥. លោក **លី លីណា** | មន្ត្រី | សមាជិក |
| ១៦. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ | | សមាជិកអចិន្ត្រៃយ៍ |
| ១៧. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ | | លេខាធិការ |

ឈ. ខេត្តព្រៃវែង ខេត្តស្វាយរៀង និងខេត្តកំពង់ស្ពឺ

| | | |
|---|---|---|
| ១. លោកជំទាវ **សោរី សូរិយា** | អនុរដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ជី ស៊ីថា** | ទីប្រឹក្សាក្រសួង | អនុប្រធាន |
| ៣. លោក **ម៉ាក់ ចាន់ផល** | អគ្គនាយករង | អនុប្រធាន |
| ៤. លោក **ទិ ឧឡារ:** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៥. លោក **អ៊ុង ណារ៉េត** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៦. លោក **អ៊ុំ បូរិទ្ធ** | អនុប្រធាននាយកដ្ឋាន | សមាជិក |
| ៧. លោក **សេក ច័ន្ទមុនី** | អនុប្រធានការិយាល័យ | សមាជិក |
| ៨. លោក **ញ៉ែម ចាន់តារ៉ា** | មន្ត្រី | សមាជិក |
| ៩. លោក **ភៅ ថ្នូក** | មន្ត្រី | សមាជិក |
| ១០. លោក **នង ម៉ាយូរ៉ា** | មន្ត្រី | សមាជិក |
| ១១. លោក **ទូន សម្ផស្ស** | មន្ត្រី | សមាជិក |
| ១២. លោក **យាង ទិច្ចរ:** | មន្ត្រី | សមាជិក |

១៣. លោក ឌៀវ សេដ្ឋី មន្ត្រី សមាជិក

១៤. ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តគោលដៅ សមាជិកអចិន្ត្រៃយ៍

១៥. ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុង ស្រុកគោលដៅ លេខាធិការ

**ប្រការ ២** : មន្ត្រីត្រួតពិនិត្យសំណង់នេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម÷

**១. មន្ត្រីត្រួតពិនិត្យសំណង់ទទួលបន្ទុករួម**

- ដឹកនាំកំណត់ទិសដៅអនុវត្តដល់មន្ត្រីត្រួតពិនិត្យសំណង់រាជធានី ខេត្ត បន្ទាប់ពីទទួលបានគោលការណ៍ពីថ្នាក់ដឹកនាំក្រសួង
- តាមដាន និងត្រួតពិនិត្យការអនុវត្តការងាររបស់មន្ត្រីត្រួតពិនិត្យសំណង់រាជធានី ខេត្ត
- ធ្វើរបាយការណ៍គោរពស្នើសុំការពិនិត្យ និងសម្រេចពីថ្នាក់ដឹកនាំក្រសួងលើការផ្អាក ការកែតម្រូវ ការបញ្ឈប់ ការតម្រូវឱ្យរុះរើ និងចាត់វិធានការចាំបាច់ផ្សេងទៀត ក្នុងករណីការងារសាងសង់ ឬរុះរើ មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំក្រសួង
- បំពេញការងារផ្សេងទៀតដែលក្រសួងប្រគល់ជូន។

**២. មន្ត្រីត្រួតពិនិត្យសំណង់រាជធានី ខេត្ត**

- ពិនិត្យ និងផ្តល់យោបល់ទាំងលើទិដ្ឋភាពច្បាប់និងបច្ចេកទេសលើគម្រោងសាងសង់ និងតាមដានត្រួតពិនិត្យការសាងសង់
- ចុះត្រួតពិនិត្យ និងបោះបង្គោលព្រំកំណត់ទីតាំងស្នើសុំសាងសង់ ឬរុះរើ
- ចុះត្រួតពិនិត្យការងារសាងសង់ឬរុះរើ និងធ្វើរបាយការណ៍អំពីលទ្ធផលនៃការចុះត្រួតពិនិត្យជូនថ្នាក់ដឹកនាំក្រសួងពិនិត្យនិងសម្រេចលើការផ្អាក ការកែតម្រូវ ការបញ្ឈប់ ការតម្រូវឱ្យរុះរើ ចាត់វិធានការចាំបាច់ផ្សេងទៀត ឬលើកសំណើសុំធ្វើអធិការកិច្ចសំណង់ ក្នុងករណីរកឃើញថាការងារសាងសង់ ឬរុះរើ មិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- សហការជាមួយរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គោលដៅ ដើម្បីចុះតាមដាន និងត្រួតពិនិត្យការអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិនគរូបនីយកម្មចំពោះគម្រោងសាងសង់រហូតដល់បញ្ចប់ការដ្ឋាន
- ប្រមូលនិងចងក្រងទិន្នន័យ និងធ្វើរបាយការណ៍តាមការដ្ឋាននីមួយៗ ដែលបានចុះត្រួតពិនិត្យបោះបង្គោលព្រំកំណត់ទីតាំងស្នើសុំសាងសង់ ឬរុះរើ
- បំពេញការងារផ្សេងទៀតដែលក្រសួងប្រគល់ជូន។

**ប្រការ ៣** : មន្ត្រីត្រួតពិនិត្យសំណង់នេះអាចប្រើប្រាស់មន្ត្រីក្រោមឱវាទ ឱ្យជួយបំពេញភារកិច្ចតាមការចាំបាច់។

**ប្រការ ៤** : សេចក្តីសម្រេចលេខ ០២០ សសរ ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ ២០១៩ ស្តីពីការបង្កើតក្រុមការងារចុះពិនិត្យតាមដានការដ្ឋានសំណង់ និងចុះដោះស្រាយវិវាទសំណង់, សេចក្តីសម្រេចលេខ ០៩១ សសរ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០១៨ ស្តីពីការកែសម្រួលក្រុមការងារចុះពិនិត្យទីតាំងស្នើសុំសាងសង់ និងចុះបោះបង្គោលព្រំកំណត់ទីតាំងសាងសង់អគារនៅតាមភូមិសាស្ត្ររាជធានីខេត្ត, សេចក្តីសម្រេចលេខ ០៦៧ សសរ ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ ២០១៨ ស្តីពីការបង្កើតក្រុមការងារចំពោះកិច្ចចុះតាមដាន និងត្រួតពិនិត្យការដ្ឋានសំណង់ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តព្រះសីហនុ និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៥** : នាយកខុទ្ទកាល័យ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងសាមីខ្លួនដូចមាននាយនាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។ ន្ធ្វុំ

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមករា ឆ្នាំ ២០២០

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់** 6

ជា សុផារ៉ា

**<u>កន្លែងទទួល</u>** ÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ០០២ ដនស/សណន

# សេចក្តីណែនាំ
# ស្តីពី
# ការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំសំដៅពង្រឹងការអនុវត្តច្បាប់ស្តីពីសំណង់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដល់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ អគ្គនាយកដ្ឋានសំណង់ អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម៖

- ហាមដាច់ខាតការសាងសង់សំណង់ដែលគ្មានលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។
- ហាមដាច់ខាតការអនុវត្តការងារសាងសង់ឬរុះរើ ដោយអ្នកសាងសង់ដែលគ្មានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- ហាមដាច់ខាតការដ្ឋានសំណង់ដែលដំណើរការសាងសង់ឬរុះរើដោយគ្មានវិស្វករប្រចាំការដ្ឋានជាអ្នកទទួលខុសត្រូវ។
- ហាមដាច់ខាតការស្នាក់នៅក្នុងអគារដែលកំពុងសាងសង់ ទោះបីជាលក្ខណៈបណ្តោះអាសន្នក៏ដោយ និងហាមដាច់ខាតអ្នកគ្មានភារកិច្ចចូលក្នុងការដ្ឋានសំណង់។
- ហាមការប្រើប្រាស់សំណង់គ្រប់ប្រភេទ ដោយគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ឬលិខិតបិទការដ្ឋានផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីពិនិត្យឃើញអំពើល្មើសនឹងបម្រាមខាងលើ អាជ្ញាធរមានសមត្ថកិច្ចត្រូវចេញលិខិតផ្អាកការសាងសង់ជាបន្ទាន់។ ក្នុងករណីការសាងសង់នៅតែបន្ត អាជ្ញាធរមានសមត្ថកិច្ចត្រូវកសាងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធីជាធរមាន។

ដើម្បីធានាសន្តិសុខនិងសុវត្ថិភាពនៃការដ្ឋានសំណង់ អាជ្ញាធរមានសមត្ថកិច្ច ត្រូវយកចិត្តទុកដាក់អនុវត្តគោលការណ៍និងវិធានការដូចខាងក្រោម÷

**១) លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ**

- គម្រោងប្លង់ស្ថាបត្យកម្មត្រូវសិក្សានិងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាស្ថាបត្យករ និងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- គម្រោងប្លង់រុះរើត្រូវសិក្សានិងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាវិស្វករនិងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- ការប្រើប្រាស់ ការប្រកបអាជីវកម្ម ការចាត់ចែង និងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់គ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីគម្រោងប្លង់អនុញ្ញាត មិនត្រូវបានអនុញ្ញាតឡើយក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

**២) លិខិតអនុញ្ញាតបើកការដ្ឋានសំណង់**

- គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀតត្រូវសិក្សា និងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាវិស្វករនិងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀត ត្រូវមានការបញ្ជាក់អនុលោមភាពតាមបទដ្ឋានបច្ចេកទេសសំណង់ ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលទទួលស្គាល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវមានបញ្ជាក់អំពីអត្តសញ្ញាណរបស់អ្នកសាងសង់ វិស្វករប្រចាំការដ្ឋាន វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន និងគម្រោងប្លង់រៀបចំការដ្ឋានសំណង់ដែលមានហត្ថលេខារបស់នាយកបច្ចេកទេស។

**៣) ការរៀបចំការដ្ឋាន**

- មន្ត្រីត្រួតពិនិត្យសំណង់ត្រូវចុះវាស់វែងនិងបោះបង្គោលព្រំកំណត់ទីតាំងដែលត្រូវសាងសង់ស្របតាមគម្រោងប្លង់ស្ថាបត្យកម្មដែលទទួលបានការយល់ព្រមតាមរយៈលិខិតអនុញ្ញាតសាងសង់។
- ការដ្ឋានសំណង់ត្រូវមានផ្ទាំងព័ត៌មានអំពីគម្រោងសាងសង់នៅពីមុខការដ្ឋានសំណង់ ជាអាទិ៍ ឈ្មោះគម្រោងសាងសង់ ឈ្មោះក្រុមហ៊ុនសាងសង់ ឈ្មោះមេក្រុមជាង ឈ្មោះម្ចាស់សំណង់ ឈ្មោះរបស់វិស្វករប្រចាំការដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ រូបភាពនេត្រាទស្សន៍នៃគម្រោងសាងសង់ និងអាសយដ្ឋានទីតាំងសំណង់។
- ត្រូវយកចិត្តទុកដាក់ប្រតិបត្តិតាមវិធានសុវត្ថិភាពដូចមានកំណត់ក្នុងប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់ និងសៀវភៅណែនាំអំពីសុវត្ថិភាពក្នុងការដ្ឋានសំណង់ (ឆ្នាំ២០១៨) របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ៤) ដំណើរការការដ្ឋានសំណង់

- មានតែក្រុមហ៊ុនសាងសង់ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ទើបអាចទទួលម៉ៅការសាងសង់បាន។ ក្រុមហ៊ុនសាងសង់អាចចុះកិច្ចសន្យាបន្តដើម្បីប្រគល់ការងារមួយផ្នែកឬច្រើនទៅឱ្យក្រុមជាងសំណង់។ ក្នុងករណីនេះ ក្រុមជាងសំណង់ត្រូវអនុវត្តការងារក្រោមការទទួលខុសត្រូវរបស់ក្រុមហ៊ុននោះ។ វិស្វករប្រចាំការដ្ឋានត្រូវចាត់តាំងដោយក្រុមហ៊ុនសាងសង់។
- ក្រុមជាងដែលមានវិញ្ញាបនបត្រក្រុមជាងសំណង់ ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត អាចទទួលម៉ៅការសាងសង់សំណង់ស្ថិតក្រោមសមត្ថកិច្ចអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។ ការងាររបស់ក្រុមជាងសំណង់ត្រូវស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់វិស្វករប្រចាំការដ្ឋានយ៉ាងតិច ០១ (មួយ) រូប ដែលមានអាជ្ញាបណ្ណឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងដែលបានចុះកិច្ចសន្យាជាមួយម្ចាស់សំណង់។
- គ្រប់ការដ្ឋានសំណង់ ត្រូវមានសៀវភៅតាមដានការងារសាងសង់ដើម្បីកត់ត្រាអំពីការងារសាងសង់ឬរុះរើជាប្រចាំ និងត្រូវដាក់ជូនមន្ត្រីត្រួតពិនិត្យសំណង់រាល់ពេលចុះត្រួតពិនិត្យ។
- អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់មន្ត្រីត្រួតពិនិត្យសំណង់ឱ្យចុះបំពេញការងារត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ជាប្រចាំ។ មន្ត្រីត្រួតពិនិត្យសំណង់មាន មន្ត្រីជំនាញនៃអគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ។
- ក្រុមហ៊ុនសាងសង់ឬវិស្វករប្រចាំការដ្ឋាន ត្រូវជូនដំណឹងមកមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះពិនិត្យលើការងារសាងសង់តាមដំណាក់កាលដូចខាងក្រោម÷
    - ក្នុងពេលកំណត់ទីតាំងសាងសង់
    - ក្នុងពេលអនុវត្តការងារគ្រឹះ
    - ក្នុងពេលអនុវត្តការងារសសរជាន់ផ្ទាល់ដី
    - ក្នុងពេលអនុវត្តការងារគ្រឿងផ្គុំបន្តបន្ទាប់ទៀត។
- នៅរាល់ពេលចុះត្រួតពិនិត្យការដ្ឋាន មន្ត្រីត្រួតពិនិត្យសំណង់ត្រូវចុះហត្ថលេខាលើសៀវភៅតាមដានការងារសាងសង់ និងធ្វើកំណត់ហេតុត្រួតពិនិត្យសំណង់ដោយមានហត្ថលេខារបស់មន្ត្រីត្រួតពិនិត្យសំណង់ និងវិស្វករប្រចាំការដ្ឋាន និងស្នាមមេដៃរបស់ម្ចាស់សំណង់ និងអ្នកជាក់ព័ន្ធ។
- ក្នុងករណីពិនិត្យឃើញថា ការងារសាងសង់ឬរុះរើមិនអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់ គម្រោងប្លង់ស្ថាបត្យកម្មដែលបានអនុញ្ញាតហើយ និងបទប្បញ្ញត្តិជាធរមានដទៃទៀត អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឱ្យរុះរើឬវិធានការចាំបាច់ផ្សេងទៀត។

- អគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុក ខណ្ឌ ត្រូវចងក្រងនិងរក្សារាល់កំណត់ហេតុ របាយការណ៍ត្រួតពិនិត្យសំណង់ រូបថត និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការដ្ឋានសំណង់នីមួយៗ ទាំងជាឯកសាររឹងនិងទាំងជាឯកសារអេឡិចត្រូនិក សម្រាប់ប្រើប្រាស់ក្នុងករណីចាំបាច់។

**៥) ការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់**

- គម្រោងប្លង់គ្រឿងផ្គុំសំណង់និងការងារសាងសង់ ត្រូវមានការត្រួតពិនិត្យនិងបញ្ជាក់អនុលោមភាពតាមបទដ្ឋានបច្ចេកទេសសំណង់ ដែលអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ ដែលជាក្រុមហ៊ុនសិក្សាគម្រោងប្លង់ឬក្រុមហ៊ុនសាងសង់ដែលកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួង។
- ការត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់គ្រឿងផ្គុំសំណង់ ត្រូវអនុវត្តដាច់ខាតលើគម្រោងប្លង់ផ្នែកគ្រឹះ ជើងតាង សសរ ធ្នឹម កម្រាលខណ្ឌ និងជញ្ជាំងទ្រទម្ងន់។ ការត្រួតពិនិត្យនិងបញ្ជាក់លើការងារសាងសង់ ត្រូវអនុវត្តដាច់ខាតនៅតាមដំណាក់កាលសំខាន់ៗនៃការងារគ្រឿងផ្គុំ ជាអាទិ៍ ផ្នែកគ្រឹះ សសរ ធ្នឹម កម្រាលខណ្ឌ និងជញ្ជាំងទ្រទម្ងន់។
- វិញ្ញាបនបត្រត្រួតពិនិត្យនិងបញ្ជាក់សំណង់ចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ គឺជាឯកសារដែលអាជ្ញាធរមានសមត្ថកិច្ចប្រើប្រាស់ក្នុងការសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដែលមានតម្លៃសម្រាប់ការចូលប្រើប្រាស់ ការដាក់ជួល ការលក់ ឬប្រតិបត្តិការពាណិជ្ជកម្មផ្សេងទៀតពាក់ព័ន្ធនឹងសំណង់។
- ក្នុងករណីពិនិត្យឃើញការងារសាងសង់មិនអនុវត្តតាមបទដ្ឋានបច្ចេកទេសសំណង់ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវជូនដំណឹងជាបន្ទាន់ទៅមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចាត់វិធានការសមស្រប។

ទទួលបានសេចក្តីណែនាំនេះ អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ អគ្គនាយកដ្ឋានសំណង់ អគ្គនាយកដ្ឋានរៀបចំដែនដីនិងនគរូបនីយកម្ម មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ១ រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមករា ឆ្នាំ ២០២០

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ជា សុផារ៉ា

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យ **សម្តេចតេជោនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ